**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**សារណាបញ្ចប់ការសិក្សា**

# បញ្ហាសមុទ្រចិនខាងត្បូងក្នុងក្របខណ្ឌ អាស៊ាន

ស្រាវជ្រាវពីថ្ងៃទី ០១ ខែមេសា ២០១៤ ដល់ថ្ងៃទី ៣១ ខែឧសភា ២០១៤

រៀបរៀងដោយ
និស្សិតឈ្មោះ **សេង ម៉េងគុង**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ចំរើន**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០
ឆ្នាំសរសេរសារណា ២០១៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមលំអោនកាយសំដែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ  និងដោយសេចក្តីគោរព
យ៉ាង
ខ្ពង់ខ្ពស់បំផុតស្មើនឹងជីវិតកូនចំពោះលោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ទូន្មាន ប្រៀនប្រដៅអប់រំគ្រប់បែបយ៉ាង និងការខិតខំព្យាយាមតស៊ូលះបង់អ្វី ៗគ្រប់បែបយ៉ាង ចាប់តាំង ពីតូចរហូតមកដល់ពេលកូនរៀនបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ លោក លោកស្រីសាស្ត្រាចារ្យទាំង
អស់  ដែលបានផ្តល់ចំណេះវិជ្ជាដែលមិនអាចកាត់ថ្លៃបានសម្រាប់រូបខ្ញុំ  តាំងពីបឋមសិក្សារហូតដល់មហាវិទ្យាល័យ  ដើម្បីអាចឱ្យរូបខ្ញុំបាទមានឱកាស  ក្នុងការនាំយកចំណេះវិជ្ជាដែលមិនអាចកាត់ថ្លៃបានទាំងនេះ យកទៅប្រើប្រាស់ក្នុងបុព្វហេតុជាតិ មាតុភូមិសព្វថ្ងៃ។

ខ្ញុំបាទសូមថ្លែងអំណរគុណដោយក្តីគោរពយ៉ាងស្មោះអស់ពីចិត្ត  ជូនចំពោះអ្នកស្នេហាជាតិទាំង
អស់ដែលបានបូជាកំលាំងកាយ កំលាំងចិត្ត និងជីវិត ក្នុងបុព្វហេតុជាតិ មាតុភូមិ និងជាពិសេសចំពោះមេដឹកនាំដែលមានឆន្ទៈក្នុងការកសាងជាតិពិតប្រាកដទាំងអស់។

ខ្ញុំបាទសូមថ្លែងអំណរគុណ  យ៉ាងជ្រាលជ្រៅចំពោះ លោកសាស្ត្រាចារ្យ ជួន ចំរើន ដែលបានចំ ណាយពេលវេលាដ៏មានតម្លៃរបស់លោក ក្នុងការណែនាំរូបខ្ញុំបាទ រៀបចំសរសេរនូវសារណាក្រោមប្រ ធានបទ “ បញ្ហាសមុទ្រចិនខាងត្បូងក្នុងក្របខ័ណ្ឌអាស៊ាន ” នេះធ្វើឡើង ប្រកបដោយជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំគោរពជូនពរ ចំពោះលោកទាំងអស់ខាងលើ  ឱ្យជួបប្រទះនូវពុទ្ធពរទាំងប្រាំប្រការគឺ៖ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមក នៅក្នុងមហាវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ខ្ញុំបាទមានចំណាប់អារម្មណ៍ទៅលើមុខវិជ្ជាទំនាក់ទំនងអន្តរជាតិ និងវិទ្យាសាស្រ្តនយោបាយ ហើយក៏បានធ្វើការសិក្សាស្រាវជ្រាវជាច្រើនអំពីច្បាប់នានា ជាពិសេសអំពីទំនាក់ទំនងអន្តរជាតិរវាងរដ្ឋនិងរដ្ឋ នយោបាយអន្តរជាតិរបស់សមាគមអាស៊ាន ជម្លោះនយោបាយអន្តរជាតិរវាងរដ្ឋ និងរដ្ឋ។ ដោយមើលឃើញនូវជម្លោះរវាងរដ្ឋ និងរដ្ឋ ទាក់ទងនឹងផលប្រយោជន៍ពីអធិបតេយ្យភាពរបស់បណ្តាប្រទេសនានានៅលើពិភពលោករាល់ថ្ងៃនេះ ហើយដោយហេតុថា ក្នុងតំបន់អាស៊ីអាគ្នេយ៍
យើងនេះ អាស៊ានក៏បានពើបប្រទះបញ្ហាទាំងនេះផងដែរ ខ្ញុំបាទសម្រេចចិត្តជ្រើសយកនូវប្រធានបទមួយមកចងក្រងធ្វើជាសារណាបញ្ចប់ការសិក្សាឆ្នាំទី៤ នេះ គឺប្រធានបទ៖ “ បញ្ហាសមុទ្រចិនខាងត្បូងក្នុងក្របខ័ណ្ឌអាស៊ាន”។

សារណានេះ មិនមែនជាការសិក្សាស្រាវជ្រាវដែលមានលក្ខណៈត្រឹមត្រូវឥតខ្ចោះនោះទេ គឺខ្ញុំបានធ្វើឡើងតាមកម្រិតចំណេះដឹងរបស់ខ្ញុំ ហើយវាក៏ជាជំហ៊ានដំបូងនៃការរៀបចំសារណានេះក្នុងការស្រាវជ្រាវ។ ខ្ញុំសង្ឃឹមថា សារណាដ៏តូចតានេះ នឹងអាចជាឯកសារជំនួយស្មារតីទៅដល់និស្សិតជំនាន់ក្រោយៗទៀត ដើម្បីអាចពង្រីកនូវចំណេះដឹង ឱ្យកាន់តែមានលក្ខណៈច្បាស់លាស់ឡើង និងមានការរីកចម្រើនទៅមុខថែមទៀតផង។

សារណាដែលខ្ញុំបាទបានចងក្រងនេះ ពិតជាមានកំហុសខ្វះចន្លោះត្រង់កន្លែងណាមួយជាមិនខាន ដូច្នេះខ្ញុំបាទរង់ចាំទទួលការរិះគន់គ្រប់បែបយ៉ាង ក្នុងន័យស្ថាបនាដើម្បីកែលម្អឱ្យកាន់តែប្រសើរឡើងថែមទៀត ពីលោកអ្នកដោយសេចក្តីរីករាយបំផុត។

# មាតិកា

ទំព័រ


❖ សេចក្ដីផ្ដើម……………………………………………………………….១


## ជំពូកទី ១
## សមុទ្រចិនខាងត្បូង


❖ ផ្នែកទី១៖ ប្រវត្តិរបស់សមុទ្រចិនខាងត្បូង……………………………………………...….៣
  - ការហៅឈ្មោះទៅតាមប្រទេសដែលមានអធិបតេយ្យភាព……………...…..៤
  - អត្ថប្រយោជន៍នៃសមុទ្រចិនខាងត្បូង……………………………………៤
  - ចិន និងសមុទ្រចិនខាងត្បូង…………………………………………….....៥

❖ ផ្នែកទី២៖ អាមេរិក និងអាស៊ានខ្លះ រួមគ្នាកើតជំងឺខ្លាចរអា ចំពោះការរីកធំធាត់របស់ចិនប្រជាមានិត………………………………………...…………………………………៧
  - អាមេរិក និងអាស៊ាន ក្នុងកិច្ចប្រជុំកំពូលលើកទី២……………………......៧
  - ត្រីងៀតឆ្អៀតពង……………...………………………………………...….៨

❖ ផ្នែកទី៣៖ ប្រតិកម្មក្រោយពីកិច្ចប្រជុំកំពូលលើកទី២អាស៊ាន-អាមេរិក និងសភាពការណ៍នយោបាយទាក់ទិនដល់តំបន់សមុទ្រចិនខាងត្បូង……………………………១០
  - កាច់ចង្កូតមករកអាស៊ាន…………..……………………………………១០
  - រៀនពីសត្រូវ……………………………………………………………...១០
  - ការជះឥទ្ធិពលដល់បណ្ដាប្រទេសផ្សេងអំពីនយោបាយថ្មីរបស់អាមេរិក..១២

❖ ផ្នែកទី៤៖ ចិន និងក្រុមប្រទេសអាស៊ាន ចាប់ដំណើរការពិភាក្សាអំពីក្រមប្រតិបត្តិស្ដីពីតំបន់សមុទ្រចិនខាងត្បូងដោយអាមេរិកចង់បានក្រមនេះចងទៅដោយច្បាប់……..១៥
  - ក្រមប្រតិបត្តិស្ដីពីសមុទ្រចិនខាងត្បូង……………………………………១៥
  - អាមេរិកជ្រៀតជ្រែកក្នុងក្រមប្រតិបត្តិស្ដីពីសមុទ្រចិនខាងត្បូង…………..១៦
  - ហ្វីលីពីន និងចិនប្រឈមមុខដាក់គ្នា………………………………….....១៦

❖ ផ្នែកទី៥៖ ប្រតិកម្មអន្តរជាតិជុំវិញខ្លឹមសារ ក្នុងសេចក្តីថ្លែងការណ៍រួមកិច្ចប្រជុំកំពូលលើកទី២ អាស៊ាន-អាមេរិក និងទស្សនវិស័យឈានទៅដល់ ការកកើតសហប្រតិបត្តិការយោធា អាមេរិក-អាស៊ាន……………………………………………………………………….១៨
- ➢ ទស្សនៈរបស់ពួកអ្នកវិភាគអន្តរជាតិ…………………………………..១៨
- ➢ ភាពស្ទាក់ស្ទើររបស់អាស៊ានក្នុងការចាប់យកអាមេរិក…………………..១៨

# ជំពូកទី ២
# ការវិវត្តន៍នៃសមុទ្រចិនខាងត្បូង

❖ ផ្នែកទី១៖ ទំនាក់ទំនងចិន-អាស៊ាន និងទំនាក់ទំនងអាមេរិក-ចិន-អាស៊ាន ក្នុងបរិបទថ្មី បន្ទាប់ពីការអះអាងអធិបតេយ្យភាពដែនសមុទ្រលើសមុទ្រចិនខាងត្បូង ត្រូវបានពុះ កញ្ជ្រោលឡើង…………………………………………………………………………..២១
- ➢ ចិនកើនឥទ្ធិពល ដោយសារការព្រងើយកន្តើយរបស់អាមេរិក…………..២១
- ➢ ចិនបញ្ចេញផែនទីអក្សរប……………………………………………………..២១
- ➢ ចិនប្រតិកម្មទៅនឹងអាមេរិក និងក្រុមហ៊ុនរុករករ៉ែ……………..………២២

❖ ផ្នែកទី២៖ អាស៊ាន និងបញ្ហាសមុទ្រចិនខាងត្បូង បន្ទាប់ពីកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិ អាស៊ាន+៨ នៅវៀតណាម…………………...……………………………២៦
- ➢ វៀតណាមព្យាយាមដោះខ្លួនចេញពីចិន…………………………………២៦
- ➢ ការប្រឈមរបស់វៀតណាមជាមួយនឹងអាមេរិក និងចិន………………..២៧

❖ ផ្នែកទី៣៖ អាស៊ានចាំបាច់ត្រូវធ្វើអ្វីនៅចំពោះឆ្អឹងទទឹងក ដែលមិនអាចវះកាត់យកចេញបាន ទាក់ទងដល់បញ្ហាសមុទ្រចិនខាងត្បូងនោះ……………..…………………..២៩
- ➢ ចិនព្យាយាមខ្ទប់អាស៊ានកុំឱ្យចេញជាផ្លូង១………..…………………..២៩
- ➢ ចិនៈ ទន់ជាមួយប្រទេសខ្លាំង ចងចិត្តប្រទេសខ្សោយ……………….…..២៩
- ➢ ចិនៈ មិនប្រយុទ្ធជាមួយសត្រូវច្រើនក្នុងពេលតែមួយ……………………៣០
- ➢ សម្ព័ន្ធមិត្តតែពេលមានប្រយោជន៍……………………………………..៣០

❖ ផ្នែកទី៤៖ អាស៊ាន និងចិន ឆ្ពោះទៅរកក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងរួមមួយអំពី

សមុទ្រចិនខាងត្បូងបានដែរ ឬអត់.....................................................៣២

- យកក្រុមប្រតិបត្តិរួមមួយមកទប់សភាពការណ៍ ដែលកំពុងវិវត្តន៍ទៅរកផ្លូវ មរណៈ.......................................................................៣២
- ឧបសគ្គរបស់ក្រុមប្រតិបត្តិ.....................................................៣២

❖ ផ្នែកទី៥៖ ការសាកល្បងកម្រិត “ក្តៅ” របស់សមុទ្រចិនខាងត្បូង នៅពេលដែលឥណ្ឌូនេស៊ីធ្វើជាប្រធានអាស៊ាន ២០១១.....................................................៣៤

- ឥណ្ឌូនេស៊ីចង់បង្ហាញពិភពលោកថាខ្លួនជារដ្ឋឥស្លាមមួយដ៏សុក្រឹត និងប្រកាន់យកលទ្ធិប្រជាធិបតេយ្យដ៏ល្អជាងគេបំផុតលើពិភពលោក..........៣៤
- ឥណ្ឌូនេស៊ីរៀបចំផែនការសម្រាប់អាស៊ាន ព្រោះមិនចង់ឃើញអាស៊ានមានអនាគតមិនច្បាស់លាស់.....................................................៣៥

❖ ផ្នែកទី៦៖ ចំណុចរសើបទាំងឡាយនៅមុនពេលកិច្ចប្រជុំកំពូលអាស៊ានលើកទី២០ នៅកម្ពុជា.......................................................................៣៧

- កម្ពុជាទទួលរងគំនាប តែនូវរឹងមាំ..........................................៣៧
- ហ្វីលីពីនចាប់ផ្តើមមិនសប្បាយចិត្ត ព្រោះតែខ្លួនអូសទាញសមាជិកអាស៊ានមួយចំនួនមិនបាន..........................................................៣៨
- កម្ពុជា៖ ជំហរអព្យាក្រឹត្យ.......................................................៣៩

❖ ផ្នែកទី៧៖ ប្រការសំខាន់ ៧ចំនុចពាក់ព័ន្ធដល់បញ្ហាគន្លឹះក្នុងសមុទ្រខាងត្បូង..........៤២

សេចក្តីសន្និដ្ឋាន...........................................................................៤៤

ឯកសារពិគ្រោះ

ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

ពិភពលោកកំពុងតែមានភាពច្រូលច្របល់ដោយសារតែបញ្ហាដណ្តើម កន្លែងគ្នាកាន់កាប់ជាច្រើន ទាំងប្រទេសមហាអំណាច និងប្រទេសដែលមានសេដ្ឋកិច្ចខ្ពស់ តួយ៉ាងដូចជារវាងប្រទេស ជប៉ុន និងចិន ជប៉ុននិងរុស្ស៊ី ចិននិងជប៉ុន អុីស្រាអែលនិងប៉ាលេស្ទីន -ល-។ បញ្ហាទ្វេភាគីកើតឡើង
យ៉ាងច្រើនក្នុងពេលបច្ចុប្បន្ន ដោយសារតែប្រទេសខ្សោយពីមុនត្រូវបានគេរំលោភបំពាន ហើយ ឥឡូវខ្លួនក្លាយជាប្រទេសខ្លាំង ក៏ចិញ្ចឹមចិត្តចង់សើរើរបស់ខ្លួនដែលគេបំពានយកមកវិញ។ ទន្ទឹមនឹង ជំលោះទ្វេភាគីជាច្រើន ដែលពិភពលោកកំពុងបារម្ភ ក៏មានបញ្ហាមួយដែលជាទំនាស់រវាងភាគីជា ច្រើនចូលរួម គឺសមុទ្រចិនខាងត្បូងហើយប្រទេសដែលមានព្រំដែនជាប់ទៅនឹងតំបន់សមុទ្រចិន
ខាងត្បូងនេះ រួមមានទាំងអស់៖ សាធារណៈរដ្ឋប្រជាមានិតចិន ម៉ាកាវ ហុងកុង តៃវ៉ាន់ ហ្វីលីពីន ម៉ាឡេស៊ី ប្រ៊ុយណេ ឥណ្ឌូនេស៊ី សិង្ហបុរី ថៃ កម្ពុជា និងវៀតណាម។ ប៉ុន្តែប្រទេសដែលមានប្រតិកម្ម ខ្លាំងទៅនឹងបញ្ហានេះគឺមានតែ៣ប្រទេសប៉ុណ្ណោះ គឺប្រទេសចិន ប្រទេសហ្វីលីពីន និងប្រទេសវៀត ណាម។ យើងទាំងអស់គ្នាឆ្ងល់ហើយថា ហេតុអ្វីបញ្ហាមានតែពីរបីប្រទេសសោះ បែរជាដោះស្រាយ មិនចេញ? មើលពីខាងក្រៅគឺបញ្ហាពីរបីប្រទេស ប៉ុន្តែធាតុពិតជាក់ស្តែងគឺមានប្រទេសមួយទៀត ចូលរួម ហើយជាប្រទេសមហាអំណាចធំបំផុតក្នុងពិភពលោកទៀតផង គឺអាមេរិក ដែលកំពុងតែ ព្យាយាមកកូរទឹកឱ្យល្អក់ ដើម្បីអាចបន្លំខ្លួនធ្វើជាមឹកទឹកសាប ចូលទៅស្វែងរកចំណីក្នុងសមុទ្រជា មួយនឹងគេបាន។

តើទំព័រប្រវត្តិសាស្ត្ររបស់ពិភពលោកថ្មីទាក់ទងនឹងសមុទ្រចិនខាងត្បូងនេះ នឹងត្រូវបើកនៅពេលណា? ដោយអ្នកណា? រឿងទាំងអស់សុទ្ធតែអាចដោះស្រាយបាន ឱ្យតែភាគីនីមួយៗប្រកាន់យកច្បាប់។ តែដោយសារច្បាប់នាពេលបច្ចុប្បន្ន ដែលបានចូលជាធរមាននោះ គឺមានប៉ះពាល់ទៅដល់ប្រទេសដែលទើបនឹងអភិវឌ្ឍ និយាយអោយខ្លី គឺប្រទេសដែលទើបនឹងខ្លាំង ព្រោះថាប្រទេសពីអតីតកាលប្រទេសទាំងនោះ ត្រូវបានគេគាបសង្កត់ គេធ្វើបាប គេរំលោភបំពានយកធនធានរបស់ ខ្លួនជាពិសេសគឺបញ្ហាដែនដី។ ដូច្នេះនាពេលបច្ចុប្បន្ន គេប្រែក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចល្អ នឹងខ្លាំងជាងប្រទេសដែលធ្លាប់ធ្វើបាបខ្លួន ទើបគេទាត់ចោលនូវច្បាប់នាពេលបច្ចុប្បន្ន ដែលធ្វើឱ្យ បាត់បង់ប្រយោជន៍ខ្លួន លើសពីនេះគេបានបង្កើតសម្មតិកម្មថ្មីជាឯកតោភាគី ដើម្បីបន្លំភ្នែកអន្តរជាតិ បញ្ហានេះហើយ ដែលធ្វើឱ្យកាន់តែស្មុគ្រស្មាញប្រៀបបានទៅនឹងសេដ្ឋកិច្ចកំពុងតែធ្លាក់ហើយគ្រោះ

ធម្មជាតិមកបំផ្លាញថែមទៀត។ មិនត្រឹមតែប៉ុណ្ណោះ ប្រទេសដែលមានសេដ្ឋកិច្ចខ្លាំង បូករួមទាំងវិស័យយោធាផងដែរនោះ ពួកគេតែងតែធ្វើការរំលោភបំពាន គាបសង្កត់ទៅប្រទេសទន់ខ្សោយតាម
រយៈសកម្មភាព ឬចិត្តសាស្ត្រ ដើម្បីឱ្យប្រទេសទន់ខ្សោយទាំងនោះ រណបពួកគេ ឬក៏ធ្វើការអនុវត្តតាមគោលនយោបាយរបស់ពួកគេ។ ប្រទេសខ្លះក៏ស្របទៅតាមគំនាបរបស់ប្រទេសខ្លាំង ប្រទេសខ្លះក៏មិនព្រមស្របតាម ហើយក៏បង្កជាសង្គ្រាមផ្ទៃក្នុង តាមរយៈការបញ្ឆេះពីប្រទេសខ្លាំងទាំងនោះ ដោយផ្តល់លុយមកធ្វើឱ្យប្រទេសនោះមានភាពចលាចល រួចខ្លួនលើកមនុស្សដែលស្តាប់ឬ ក៏រណប
ខ្លួន តួយ៉ាងដូចជា ប្រទេសលីបី ប្រទេសអុីរ៉ាក់ ប្រទេសអាហ្កានីស្ថាន -ល- ឱ្យធ្វើជាមេដឹកនាំ។

ប៉ុន្តែបញ្ហារបស់សមុទ្រចិនខាងត្បូង មិនទាន់ប្រែក្លាយទៅជាសង្គ្រាមនៅឡើយទេ ឬក៏រុញច្រានស្ថានភាពមួយដែលមិនអាចគ្រប់គ្រងបាន ដោយសារតែប្រទេសចិន ដែលជាអ្នកកាន់កូសោរក្នុងបញ្ហានេះ មានភាពចាស់ទុំក្នុងការដោះស្រាយបញ្ហា ប្រៀបបានទៅនឹងទឹកត្រជាក់ត្រីកុំ គឺបញ្ហានេះស្ថិតក្នុងនីតិវិធីក្នុងការដោះស្រាយដែលអាចចរចាគ្នាបានថ្វីបើមានការប្រឈមខ្លះព្រោះប្រទេសដែលមានទំនាស់ជាមួយនឹងប្រទេសចិនក្នុងរឿងនេះ ហាក់បីដូចជាមិនរឹងមាំ ឬក្លាយ ជាខ្លួនមួយនៅឡើយទេ គឺខ្លួនមួយក្បាលពីរ ឬក៏សាមគ្គីគ្នាតែពេលមានប្រយោជន៍ប៉ុណ្ណោះ។

# សេចក្តីផ្តើម

ពិភពលោកកំពុងតែមានភាពច្រួលច្របល់ដោយសារតែបញ្ហាដណ្តើម កន្លែងគ្នាកាន់កាប់ជាច្រើន ទាំងប្រទេសមហាអំណាច និងប្រទេសដែលមានសេដ្ឋកិច្ចខ្ពស់ តួយ៉ាងដូចជារវាងប្រទេស ជប៉ុន និងចិន ជប៉ុននិងរុស្ស៊ី ចិននិងជប៉ុន អុីស្រាអេលនិងប៉ាលេស្ទីន -ល-។ បញ្ហាទ្វេភាគីកើតឡើង
យ៉ាងច្រើនក្នុងពេលបច្ចុប្បន្ន ដោយសារតែប្រទេសខ្សោយពីមុនត្រូវបានគេរំលោភបំពាន ហើយ ឥឡូវខ្លួនក្លាយជាប្រទេសខ្លាំង ក៏ចិញ្ចឹមចិត្តចង់សើរើរបស់ខ្លួនដែលគេបំពានយកមកវិញ។ ទន្ទឹមនឹង ជំលោះទ្វេភាគីជាច្រើន ដែលពិភពលោកកំពុងបារម្ភ ក៏មានបញ្ហាមួយដែលជាទំនាស់រវាងភាគីជា ច្រើនចូលរួម គឺសមុទ្រចិនខាងត្បូងហើយប្រទេសដែលមានព្រំដែនជាប់ទៅនឹងតំបន់សមុទ្រចិន
ខាងត្បូងនេះ រួមមានទាំងអស់៖ សាធារណៈរដ្ឋប្រជាមានិតចិន ម៉ាការ ហុងកុង តៃវ៉ាន់ ហ្វីលីពីន ម៉ាឡេស៊ី ប្រ៊ុយណេ ឥណ្ឌូនេស៊ី សិង្ហបុរី ថៃ កម្ពុជា និងវៀតណាម។ ប៉ុន្តែប្រទេសដែលមានប្រតិកម្ម ខ្លាំងទៅនឹងបញ្ហានេះគឺមានតែ៣ប្រទេសប៉ុណ្ណោះ គឺប្រទេសចិន ប្រទេសហ្វីលីពីន និងប្រទេសវៀត ណាម។ យើងទាំងអស់គ្នាឆ្ងល់ហើយថា ហេតុអ្វីបញ្ហាមានតែពីរបីប្រទេសសោះ បែរជាដោះស្រាយ មិនចេញ? មើលពីខាងក្រៅគឺបញ្ហាពីរបីប្រទេស ប៉ុន្តែធាតុពិតជាក់ស្តែងគឺមានប្រទេសមួយទៀត ចូលរួម ហើយជាប្រទេសមហាអំណាចធំបំផុតក្នុងពិភពលោកទៀតផង គឺអាមេរិក ដែលកំពុងតែ ព្យាយាមកក្វរទឹកឱ្យល្អក់ ដើម្បីអាចបន្លំខ្លួនធ្វើជាមឹកទឹកសាប ចូលទៅស្វែងរកចំណីក្នុងសមុទ្រជា មួយនឹងគេបាន។

តើទំព័រប្រវត្តិសាស្ត្ររបស់ពិភពលោកថ្មីទាក់ទងនឹងសមុទ្រចិនខាងត្បូងនេះ នឹងត្រូវបើកនៅពេលណា? ដោយអ្នកណា? រឿងទាំងអស់សុទ្ធតែអាចដោះស្រាយបាន ឱ្យតែភាគីនីមួយៗប្រកាន់យកច្បាប់។ តែដោយសារច្បាប់នាពេលបច្ចុប្បន្ន ដែលបានចូលជាធរមាននោះ គឺមានប៉ះពាល់ទៅដល់ប្រទេសដែលទើបនឹងអភិវឌ្ឍ និយាយអោយខ្លី គឺប្រទេសដែលទើបនឹងខ្លាំង ព្រោះថាប្រទេសពីអតីតកាលប្រទេសទាំងនោះ ត្រូវបានគេគាបសង្កត់ គេធ្វើបាប គេរំលោភបំពានយកធនធានរបស់ ខ្លួនជាពិសេសគឺបញ្ហាដែនដី។ ដូច្នេះនាពេលបច្ចុប្បន្ន គេប្រែក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចល្អ នឹងខ្លាំងជាងប្រទេសដែលធ្លាប់ធ្វើបាបខ្លួន ទើបគេទាត់ចោលនូវច្បាប់នាពេលបច្ចុប្បន្ន ដែលធ្វើឱ្យ បាត់បង់ប្រយោជន៍ខ្លួន លើសពីនេះគេបានបង្កើតសម្មតិកម្មថ្មីជាឯកតោភាគី ដើម្បីបន្លំភ្នែកអន្តរជាតិ បញ្ហានេះហើយ ដែលធ្វើឱ្យកាន់តែស្មុគ្រស្មាញប្រៀបបានទៅនឹងសេដ្ឋកិច្ចកំពុងតែធ្លាក់ហើយគ្រោះ

ធម្មជាតិមកបំផ្លាញថែមទៀត។ មិនត្រឹមតែប៉ុណ្ណោះ ប្រទេសដែលមានសេដ្ឋកិច្ចខ្លាំង បូករួមទាំងវិស័យយោធាផងដែរនោះ ពួកគេតែងតែធ្វើការរំលោភបំពាន គាបសង្កត់ទៅប្រទេសទន់ខ្សោយតាម
រយៈសកម្មភាព ឬចិត្តសាស្ត្រ ដើម្បីឱ្យប្រទេសទន់ខ្សោយទាំងនោះ រណបពួកគេ ឬក៏ធ្វើការអនុវត្តតាមគោលនយោបាយរបស់ពួកគេ។ ប្រទេសខ្លះក៏ស្របទៅតាមគំនាបរបស់ប្រទេសខ្លាំង ប្រទេសខ្លះក៏មិនព្រមស្របតាម ហើយក៏បង្កជាសង្គ្រាមផ្ទៃក្នុង តាមរយៈការបញ្ឆេះពីប្រទេសខ្លាំងទាំងនោះ ដោយផ្តល់លុយមកធ្វើឱ្យប្រទេសនោះមានភាពចលាចល រួចខ្លួនលើកមនុស្សដែលស្តាប់ឬ ក៏រណប
ខ្លួន តួយ៉ាងដូចជា ប្រទេសលីប៊ី ប្រទេសអុីរ៉ាក់ ប្រទេសអាហ្កានីស្ថាន -ល- ឱ្យធ្វើជាមេដឹកនាំ។

ប៉ុន្តែបញ្ហារបស់សមុទ្រចិនខាងត្បូង មិនទាន់ប្រែក្លាយទៅជាសង្គ្រាមនៅឡើយទេ ឬក៏រុញច្រានស្ថានភាពមួយដែលមិនអាចគ្រប់គ្រងបាន ដោយសារតែប្រទេសចិន ដែលជាអ្នកកាន់កូសោរក្នុងបញ្ហានេះ មានភាពចាស់ទុំក្នុងការដោះស្រាយបញ្ហា ប្រៀបបានទៅនឹងទឹកត្រជាក់ត្រីកុំ គឺបញ្ហានេះស្ថិតក្នុងនីតិវិធីក្នុងការដោះស្រាយដែលអាចចរចាគ្នាបានថ្វីបើមានការប្រឈមខ្លះព្រោះប្រទេសដែលមានទំនាស់ជាមួយនឹងប្រទេសចិនក្នុងរឿងនេះ ហាក់បីដូចជាមិនរឹងមាំ ឬក្លាយ ជាខ្លួនមួយនៅឡើយទេ គឺខ្លួនមួយក្បាលពីរ ឬក៏សាមគ្គីគ្នាតែពេលមានប្រយោជន៍ប៉ុណ្ណោះ។

## ផ្នែកទី១

# ប្រវត្តិរបស់សមុទ្រចិនខាងត្បូង៖



សមុទ្រចិនខាងត្បូងមានវិសាលភាពប្រមាណ៣.៥០០.០០០ គីឡូម៉ែត្រការ៉េ ជាតំបន់សមុទ្រ មួយដែលមានសណ្ឋានធំលំដាប់ទី៤ និងជាចំណែកមួយរបស់សមុទ្រប៉ាស៊ីហ្វិក។ ក្នុងតំបន់សមុទ្រ
ចិនខាងត្បូងនេះ សំបូរទៅដោយកោះ ហើយកោះទាំងនេះបានប្រមូលផ្តុំច្រើនកកើតឡើងទៅជាប្រជុំកោះ(archipelagoes) នៅក្នុងសមុទ្រចិនខាងត្បូង។ កោះប្រជុំកោះ និងជួរកោះទាំងនេះមួយភាគធំគ្មានមនុស្សរស់នៅ ហើយក៏បានប្រែក្លាយទៅជាគោលដៅនៃការដណ្តើមអធិបតេយ្យភាព ក្នុងការទន្ទ្រានកាន់កាប់លើកោះទាំងនេះរបស់ប្រទេសជាច្រើន ដែលមានព្រំដែនសមុទ្រជាប់ទៅនឹងតំបន់សមុទ្រចិនខាងត្បូងនេះ រួមមានទាំងអស់៖ សាធារណៈរដ្ឋប្រជាមានិតចិន ម៉ាកាវ ហុងកុង តៃវ៉ាន់ ហ្វីលីពីន ម៉ាឡេស៊ី ប្រ៊ុយណេ ឥណ្ឌូនេស៊ី សិង្ហបុរី ថៃ កម្ពុជា និងវៀតណាម។

យោងតាមឯកសាររបស់វីគីភីឌា គឺឃ្លាថា South China Sea ជានាមស័ព្ទមួយដែលត្រូវបាន ស្គាល់យ៉ាងទូលំទូលាយបំផុត ក្នុងភាសាអង់គ្លេសក្នុងការចង្អុលបង្ហាញថា តំបន់សមុទ្រនេះត្រូវបាន កំណត់ឡើងដោយ “អង្គការអន្តរជាតិខាងជលធារសាស្រ្ត” ដែលដែនសមុទ្រនេះ លាតសន្ធឹងពីទិស
និរតី រហូតដល់ភាគឦសាន្ត ដោយមានព្រំប្រទល់ភាគខាងត្បូង គឺ៣អង្សារ ក្នុងរយៈទទឹងខាងត្បូង រវាងចន្លោះកោះស៊ូម៉ាត្រា(Sumatra)ខាងត្បូង និងកោះ(Katimantan)កាទីម៉ាន់តាន់ និងព្រំដែនខាង ជើងរបស់វា គឺជាប់ឈូងសមុទ្រតៃវ៉ាន់ ដោយចាប់ពីភាគខាងជើងតៃវ៉ាន់ រត់រហូតដល់ឈូងសមុទ្រ ភូគៀនរបស់ប្រទេសចិន។

### ➢ ការហៅឈ្មោះនៅតាមប្រទេសដែលមានអធិបតេយ្យភាព

ដោយឡែកឈូងសមុទ្រថៃ ក៏មានមួយចំណែកស្ថិតនៅភាគខាងលិចរបស់សមុទ្រចិនខាង ត្បូងនេះដែរ។ ប្រទេសទាំងអស់ដែលស្ថិតនៅជុំវិញសមុទ្រចិនខាងត្បូងនេះបានហៅ តំបន់

សមុទ្រ ចិនខាងត្បូងនេះ ទៅតាមឈ្មោះខុសៗគ្នា ដោយការហៅនេះអនុលោមទៅតាម អធិបតេយ្យភាព ប្រវត្តិសាស្ត្ររបស់ពួកគេមកលើសិទ្ធិអធិបតេយ្យលើតំបន់េនះ។ ដូចជា វៀតណាម បានហៅតំបន់ សមុទ្រនោះថាជា*សមុទ្រខាងកើត* ដោយសណ្ឋានភូមិសាស្ត្ររបស់វៀតណាម គឺបែរទៅរកសមុទ្រ

ក្នុងទិសខាងកើត។ ចំពោះចិនវិញបានហៅសមុទ្រនេះថាជា*សមុទ្រខាងត្បូង* ហើយបើហ្វីលីពីនវិញ បានហៅតំបន់សមុទ្រនេះថាជា*សមុទ្រLuzon*។ ការហៅនេះ ដោយ Luzon ជាកោះមួយដ៏ធំរបស់ ហ្វីលីពីនស្ថិតនៅក្នុងតំបន់សមុទ្រនេះ។ តែក្រោយមក ហ្វីលីពីនបានប្រកាសជាផ្លូវការណ៍ដោយប្តូរ

ឈ្មោះសមុទ្រ Luzon នេះ ទៅជាសមុទ្រហ្វីលីពីនខាងលិច។ បើបារាំងវិញបានហៅថា Archipel des ile Spratley។ដោយឡែកចំពោះជប៉ុនវិញ បានហៅប្រជុំកោះនេះថា Shinan Guto។ តែបើយោងតាមឯកសារបុរមបុរាណស្តីពីដំណើរនាវាចរណ៍របស់ពួកព័រទុយហ្កាល់ នាសតវត្សន៍ទី១៥ ឬ១៦ វិញនៅ មានឈ្មោះមួយទៀតដែល ពួកនេះហៅគឺ *សមុទ្រចម្ប៉ា*។

## ➢ អត្ថប្រយោជន៍នៃសមុទ្រចិនខាងត្បូង

សមុទ្រចិនខាងត្បូង គឺជាតំបន់សមុទ្រដែលសំបូរទៅដោយសម្បត្តិធម្មជាតិ ហើយក៏ជាតំបន់មួយប្រកបទៅដោយការប្រកួតប្រជែងដណ្តើមផលប្រយោជន៍ និងជាចំណុចមួយដ៏ក្តៅបំផុតនាសតវត្សរ៍ទី២១នេះ។

ក្នុងសិក្ខាសាលាលើកទី២ ស្តីពី “ កិច្ចសហប្រតិបត្តិការសមុទ្រចិនខាងត្បូងសម្រាប់ការអភិវឌ្ឍសន្តិសុខក្នុងតំបន់ ” នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ដែលមានការអញ្ជើញចូលរួមយ៉ាងច្រើនពីបណ្តាអ្នកស្រាវជ្រាវ៧០នាក់លើពិភពលោក រួមទាំងប្រទេសអាស៊ានទាំង១០ផងនោះ ដែលអង្គសិក្ខាសាលាបានធ្វើការបរិយាយយ៉ាងច្បាស់ថា៖

សមុទ្រចិនខាងត្បូង ជាតំបន់សមុទ្រមួយដែលមានអត្ថន័យភូមិសាស្ត្រនយោបាយ ដ៏ជ្រាល

ជ្រៅ និងមានសារៈសំខាន់ជាទីបំផុត។ សមុទ្រចិនខាងត្បូងគឺជាផ្លូវគមនាគមន៍សម្រាប់នាវាចរណ៍ដ៏ច្រើនកុះករឈរលំដាប់លេខពីរលើពិភពលោក ហើយបើគិតអំពីទំហំនៃបរិមាណ ទំនិញពាណិជ្ជកម្ម ដែលដឹកជញ្ជូនឆ្លងកាត់តំបន់សមុទ្រនេះមានចំនួន៥០% ដែលទំនិញទាំងនេះធ្វើដំណើរឆ្លងកាត់ ឈូងសមុទ្រម៉ាឡាកា(Malacca) ឈូងសមុទ្រស៊ុនដា(Sunda) និងឈូងសមុទ្រលុមប៉រ (Lombor)។ ក្រៅពីនេះ ក៏មានប្រេងប្រមាណ ១.៦លានម៉ែត្រគូប(១០លានប៉ារ៉ែល)ជាប្រេងនៅដែលត្រូវបានដឹក

ជញ្ជូនឆ្លងកាត់សមុទ្រម៉ាឡាកា(Malacca) ជារៀងរាល់ថ្ងៃ ដែលជាកន្លែងសំបូរទៅដោយពួកចោរសមុទ្រ។ សមុទ្រចិនខាងត្បូង ត្រូវបានកំណត់ដោយអះអាងថា មានបរិមាណរ៉ែប្រេងប្រហែល ១,២

គីឡូម៉ែត្រគូប(៧,៧ កោដិបារ៉ែល) ដែលសរុបទាំងអស់ទៅមានប្រមាណ ៩,៥ លានគីឡូម៉ែត្រគូប (២៨ កោដិបារ៉ែល) ក្នុងបាតសមុទ្រនេះ។ ដោយឡែកឧស្ម័នហ្គាសវិញ ក៏ត្រូវបានវាយតម្លៃថា មានបរិមាណរហូតដល់ ៧.៥០០លានម៉ែត្រគូប (២៦៦កោដិហ្វីត)ផងដែរ។ ទន្ទឹមនឹងនេះ យោងតាមការស្រាវជ្រាវរបស់ក្រសួងបរិស្ថានហ្វីលីពីនអំពីប្រភពជលផលធម្មជាតិទូទៅគឺសមុទ្រចិនខាងត្បូងនេះជាតំបន់សមុទ្រមួយមានភាពសំបូរបែបទៅដោយសត្វសមុទ្រ និងរុក្ខសាគរ ជីវចម្រុះគ្រប់ប្រភេទរស់

ក្នុងបាតសមុទ្រ ដែលជាសម្បត្តិធម្មជាតិមួយមានសារសំខាន់បំផុតសម្រាប់ប្រព័ន្ធបរិស្ថានវិទ្យា

ព្រំដែនរដ្ឋ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខលើតំបន់សមុទ្រ និងមកលើកោះទាំងនេះបានក្លាយជា

កម្មវត្ថុមួយដ៏ស្រួចស្រាវ និងមានចរិតសំខាន់បំផុត ព្រោះបើកាន់កាប់បានសណ្ឋានទាំងអស់នេះនឹងជួយឱ្យប្រទេសទាំងនោះ មានលទ្ធភាពក្នុងការពង្រីកដែនអធិបតេយ្យភាព បូរណភាព រួមទាំងតំបន់សេដ្ឋកិច្ចផ្តាច់មុខទៀតផង។ ហើយប្រភពប្រេងឥន្ទនៈ និងជាតិឧស្ម័នដែលជាសក្តានុពលមួយដ៏មហិមាក្នុងទម្ងន់នៃជញ្ជីងសេដ្ឋកិច្ចបានក្លាយជាកូនសោរមួយសម្រាប់ធានានូវ សន្តិសុខ ថាមពល និងកំណើនអភិវឌ្ឍន៍របស់ប្រទេសខ្លួន ក្នុងទស្សនវិស័យនៃវិបត្តិវត្ថុធាតុធម្មជាតិ នាពេលអនាគត។

ចំពោះកត្តាភូមិសាស្ត្រនយោបាយវិញ ក្នុងករណីគ្រប់គ្រងបានតំបន់សមុទ្រចិនខាងត្បូង គឺមានន័យថា មិនត្រឹមតែគ្រប់គ្រងមកលើផ្លូវគមនាគមន៍ សម្រាប់នាវាចរណ៍ឈរលំដាប់លេខពីរ ពិភពលោកនោះទេ គឺថែមទាំងបានត្រួតត្រាប្រែក្លាយតំបន់សមុទ្រនេះ ទៅជាផ្ទះបាយរបស់ប្រទេស

ខ្លួនទៀតផងនោះ ព្រមទាំងអាចបង្កឱ្យមានផលលំបាកមិនតិច មកលើប្រទេសទាំងឡាយក្នុងការ ចង់ចេញចូល ទៅមក និងការធ្វើនាវាចរណ៍ឆ្លងកាត់ក្នុងតំបន់នេះមានភាពមិនស្រួលឡើយ។ ការធ្វើ

អធិរាជលើតំបន់សមុទ្រចិនខាងត្បូងនេះ អាចកកើតជាហេតុការណ៍នយោបាយយុទ្ធសាស្ត្រមួយដ៏ធំដែលអាចនាំធ្វើឱ្យទៅជាតំបន់ហាមហោះហើរឆ្លងកាត់ឬជាតំបន់សមុទ្រហាមមិនឱ្យមាននូវសកម្មភាពណាមួយនៅទីនេះ ព្រមទាំងប្រែក្លាយតំបន់នេះទៅជាមូលដ្ឋានយោធា ដូចជាកងទ័ពអាមេរិក ឬពួកហ្វាស៊ីសជប៉ុនធ្លាប់បានប្រើប្រាស់កោះមួយចំនួនក្នុងតំបន់នេះ ធ្វើជាកំពែងមូលដ្ឋានយោធានាសម័យសង្គ្រាមលោកលើកទី២នោះ។

### ➢ ចិន និងសមុទ្រចិនខាងត្បូង

បញ្ហាមួយដែលជាចំណុចគន្លឹះ ហើយនៅមានការចម្រូងចម្រាសគឺជុំវិញតួនាទីរបស់ចិន និង

អាមេរិកនៅក្នុងតំបន់សមុទ្រចិនខាងត្បូង។ យោងទៅតាមលោកសាស្ត្រាចារ្យThayer របស់អូស្ត្រាលី
ឱ្យដឹងថា កងទ័ពប្រជាជនចិនបានចាត់ទុកសមុទ្រចិនខាងត្បូងនេះជាតំបន់ស្លាប់រស់ ហើយកងទ័ពប្រជាជនចិនបាន និងកំពុងបង្កើនឱ្យអស់នូវសមត្ថភាពរបស់កងទ័ពជើងទឹកចិន ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការធានាការពារអធិបតេយ្យភាពនៅលើសមុទ្រចិនខាងត្បូងនេះ ឱ្យបានសុក្រឹតព្រមទាំងធ្វើគ្រប់បែបយ៉ាង ក្នុងការកំហិតដល់រាល់ការជ្រៀតចូលនូវ ទោះបីអានុភាពណាមួយរួមទាំងសហរដ្ឋអាមេរិកនៅក្នុងតំបន់សមុទ្រជុំវិញនិងតំបន់សមុទ្រសំខាន់ៗរបស់ចិនទៀតផង។

ស្ថានភាពទាំងនេះ មិនខុសអីទៅនឹងតថភាពរបស់ចក្រភពអង់គ្លេសមុននេះ ដែលគេទាំង ឡាយបានស្គាល់ និងហៅចក្រភពអង់គ្លេសថាជា“តោសមុទ្រ”នោះ ដោយអង់គ្លេសនាសម័យកាល
នោះធ្លាប់បានធ្វើអធិរាជលើមហាសាគរអស់រយៈកាលមួយដ៏យូរ។ ឥឡូវនេះ សហរដ្ឋអាមេរិក មហាអំណាចនៃមហាអំណាចពិភពលោក ដែលក្នុងនោះអត្ថប្រយោជន៍ដ៏កំពូល និងសារវន្តក្នុងយុទ្ធ សាស្ត្រសកល គឺសេរីភាពក្នុងការធ្វើនាវាចរណ៍លើមហាសាគរទាំងអស់ ដោយអំណាចក្នុងការធ្វើ
ចរាចរនាវាចរណ៍លើមហាសាគរនេះ ជាអត្តិភាព និងកម្លាំងពិតរបស់អាមេរិក ដោយសិទ្ធិអំណាចទាំងនេះផ្សារភ្ជាប់ទៅនឹងតម្លៃរបស់ប្រទេសអាមេរិកផង។ ផ្តើមចេញពីទស្សនៈនេះ ទើបអាមេរិក ចាត់ទុកខ្លួនមានអំណាចធ្វើជាម្ចាស់លើមហាសាគរទាំងអស់ ព្រមទាំងមានសិទ្ធិពេញលេញក្នុងការ

ប្រើប្រាស់នូវកម្លាំងបាយ ដើម្បីធានាការពារដល់អំណាចនោះ ដូចដែល “តោសមុទ្រ” អង់គ្លេសធ្លាប់បានវាតទីសមុទ្រទាំងអស់ក្នុងសម័យកាលនាសតវត្សរ៍ទី១៩នោះ។

ទាក់ទងដល់ទស្សនៈនយោបាយគ្រប់គ្រងមកលើមហាសាគរនេះ ចិនបានធ្វើការអះអាងថា ចិនជាប្រទេសប្រកបទៅដោយការទទួលខុសត្រូវមួយ លើសមុទ្រចិនខាងត្បូងដោយប្រទេសចិនត្រូវការបរិយាកាសសន្តិភាព រួមរស់ ជាមួយបណ្តាប្រទេសជុំវិញ ដើម្បីការអភិវឌ្ឍ និងវឌ្ឍនៈភាព ហើយបើគ្មានសន្តិភាព និងស្ថេរភាព គឺពុំអាចមានបរិយាកាសសហប្រតិបត្តិការនៅក្នុងតំបន់ដូច បច្ចុប្បន្ននេះឡើយ!។

ចំពោះទស្សនៈរបស់លោកDaniel Schaeffer មកពីវិទ្យាស្ថានសិក្សាស្រាវជ្រាវបារាំងបានផ្តល់មតិថា ប្រការដែលចិនលើកឡើងជាផ្លូវការនូវផែនទីអក្សរ U លើសមុទ្រចិនខាងត្បូង គឺជាចំណុច
រសើបមួយដែលត្រូវបានយកចិត្តទុកដាក់ជាទីបំផុតនៅក្នុងតំបន់នេះ ហើយបើកិច្ចដំណើរការចរចា

ពីគ្រប់ភាគីទាំងអស់ ក្នុងការដោះស្រាយទំនាស់វិវាទលើអធិបតេយ្យភាព នេះពុំមានវឌ្ឍនភាពរីក ចម្រើនទៅមុខទៀត ពេលនោះភាគីទាំងអស់គួរគិតដល់ការនាំអធិករណ៍នេះទៅកាន់តុលាការច្បាប់
សមុទ្រ ឬក៏តុលាការយុត្តិធម៌អន្តរជាតិ ឱ្យគេរកយុត្តិធម៌ដោះស្រាយជំនួស។

ដោយឡែក ចំពោះទស្សនៈនយោបាយរបស់វៀតណាមបានចាត់ទុកថា សន្តិភាព ស្ថេរភាព ការអភិវឌ្ឍ ចីរភាព និងសន្តិសុខ ដែលក្នុងនោះរួមមានទាំងការជួយសង្គ្រោះមនុស្សនៅលើតំបន់ សមុទ្រចិនខាងត្បូង គឺជាចំណុចសំខាន់ក្នុងរបៀបវារៈទាំងឡាយនាជំនួបផ្លូវការរវាងអាស៊ាន និងចិន
ដោយផ្អែកលើស្មារតីនៃសេចក្ដីប្រកាសលើក្រមប្រតិបត្តិស្ដីពីសមុទ្រចិនខាងត្បូង ប៉ុន្តែដោយសេចក្ដីប្រកាសក្រមប្រតិបត្តិស្ដីពីសមុទ្រចិនខាងត្បូង ពុំទាន់មានភាពសុក្រឹតគ្រប់គ្រាន់ ទើបក្រុមប្រទេសអាស៊ានទាំងអស់ ដាក់ការសង្ឃឹមមកលើក្រមប្រតិបត្តិស្ដីពីសមុទ្រចិនខាងត្បូងវិញ ដែលមានចរិតផ្សារភ្ជាប់ទៅនឹងច្បាប់ច្បាស់លាស់ និងគ្រប់វិស័យជាងហើយដែលនឹងត្រូវបានចរចា និងចុះហត្ថលេ
ខានាពេលអនាគត។

<u>ផ្នែកទី២</u>

# អាមេរិក និងអាស៊ានខ្វះ រួមគ្នាកើតជំងឺខ្លាចរអា ចំពោះការរីកដំដាត់របស់ចិនប្រជាមានិត

## ➢ អាមេរិក និងអាស៊ាន ក្នុងកិច្ចប្រជុំកំពូលលើកទី២

លោកប្រធានាធិបតីអាមេរិក Barack Obama បានដឹកនាំកិច្ចប្រជុំជាមួយប្រមុខដឹកនាំរបស់ប្រទេសអាស៊ានទាំង១០ ហើយនេះជាកិច្ចប្រជុំលើកទីពីររបស់ប្រធានាតិបតី Obama ជាមួយបណ្ដាថ្នាក់ដឹកនាំអាស៊ានដែលលើកមុនបានប្រព្រឹត្តទៅនៅសិង្ហបុរី។ ចាប់ពីពេលនោះមក សេតវិមានមាន ការសម្របសម្រួលអំពីកាលបរិច្ឆេទ និងទីកន្លែងប្រជុំជាមួយបណ្ដាប្រទេសអាស៊ាន ដោយប្រទេស
អាស៊ានមួយភាគធំ ចង់ឱ្យកិច្ចប្រជុំនេះប្រព្រឹត្តទៅនៅ Washington ព្រោះមានអត្ថន័យ និងស្របតាមកម្រិតការទូតរវាងអាស៊ាន និងអាមេរិក ក៏ប៉ុន្តែអាមេរិកយល់ឃើញថា កិច្ចប្រជុំនេះគួរប្រព្រឹត្តឡើង នៅក្រុងញូវ៉ក ដោយសារស្របនឹងការប្រជុំមហាសន្និបាតរបស់អង្គការសហប្រជាជាតិ ហើយក្រុង
ញូវយ៉ក ក៏ជាទីកន្លែងដែលប្រមូលផ្ដុំថ្នាក់ដឹកនាំកំពូលៗរបស់អន្តរជាតិ ដែលមកជួបជុំ និងប្រជុំនៅទីនោះ មានភាពងាយស្រួល និងសមរម្យ។ ប្រការមួយដែលចង់បញ្ជាក់នៅទីនោះ គឺកិច្ចប្រជុំលើកទី២អាមេរិក និងអាស៊ាននេះត្រូវបានគ្រោងប្រព្រឹត្តនៅចុងឆ្នាំនេះ ក៏ប៉ុន្តែអាមេរិក បានរុញកិច្ចប្រជុំនេះឱ្យប្រព្រឹត្តឡើង នៅមុនកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក៨ រួមមាន អូស្ត្រាលី, ចិន, ឥណ្ឌា, ជប៉ុន, រ៉ក, ញូវហ្សឺលែន, រុស្សី និងអាមេរិក ដែលនឹងប្រជុំក្នុង ខែតុលា ឆ្នាំ២០១០ នៅហាណូយទៅ
វិញ។ គោលបំណងនៃការជំរុញ ឱ្យមានកិច្ចប្រជុំកំពូលលើកទី២អាមេរិកនិងអាស៊ាននេះមុនកិច្ចប្រជុំ
រដ្ឋមន្ត្រីការពារជាតិអាស៊ានបូក៨នេះ គឺក្នុងមូលបទលើកកម្ពស់ តួនាទីរដ្ឋមន្ត្រីការពារជាតិអាមេរិក Robert Gates និងអត្តិភាពរបស់អាមេរិក ឱ្យកាន់តែមានទម្ងន់លើឆាកអន្តរជាតិ ជាពិសេសគឺដើម្បីផ្ដោតសារសំខាន់មកលើចិន ដែលជាប្រទេសមួយកំពុងចិញ្ចឹមមហិច្ឆតាលេបត្របាក់យកសមុទ្រចិនខាងត្បូងទាំងអស់ ដោយចិនមើលមកលើតំបន់សមុទ្រចិនខាងត្បូងនេះ ដូចជាផ្ទះបាយរបស់ចិន អញ្ចឹង។ ដោយឡែកចំពោះវៀតណាមនិងហ្វីលីពីនវិញបាននិងកំពុងស្ថិតនៅចំពោះមុខចុងកាណុង
របស់ចិន។ ដោយមានចរិតសំខាន់ទាក់ទងដល់សន្តិសុខលើសមុទ្រចិនខាងត្បូងយ៉ាងដូច្នេះបាន ជំរុញឱ្យអាមេរិក និងប្រទេសអាស៊ានទាំង១០ ក្នុងនោះសំខាន់ជាងគេបំផុត គឺវៀតណាមមាន

ទំនាក់ ទំនងចង់ផ្សារភ្ជាប់គ្នាជាមួយនឹងអាមេរិក ហើយនេះក៏ជាគោលដៅ និងជាអត្ថន័យចម្បង របស់កិច្ច
ប្រជុំកំពូលលើកទី២អាមេរិក និងអាស៊ាន នៅក្រុងញូវយ៉កផងដែរ។

នៅថ្ងៃទី០៥ កញ្ញា ២០១០នេះ លោក Larry Summersប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិនិងជានាយករងអង្គការសន្តិសុខជាតិអាមេរិក រួមជាមួយលោក Thomas Donilon បានដឹកនាំគណៈប្រតិភូអាមេរិកទៅទស្សនកិច្ចចិន៤ថ្ងៃ សំដៅធ្វើការពិភាក្សាលើទំនាក់ទំនងទ្វេភាគី ធ្វើឱ្យស្ថេរភាពដែលកំពុងតែតានតឹងអំពីរូបិយប័ណ្ណពាណិជ្ជកម្ម និងយោធារវាងប្រទេសទាំងពីរ។ សហរដ្ឋអាមេរិកបានបង្ខំចិនឱ្យកែសម្រួលអត្រាប្រាក់យ៉ន ព្រមទាំងមានវិធានការដាក់ទណ្ឌកម្មយ៉ាងខ្លាំងក្លា មកលើប្រទេសអុីរ៉ង។ ចំពោះចិនវិញ ចង់ឱ្យអាមេរិកបន្តកិច្ចប្រជុំ៦ភាគីឡើងវិញ ស្តីពីបញ្ហានុយក្លេអ៊ែររបស់កូរ៉េខាងជើង។ ក្នុងដំណើរទស្សនកិច្ចរបស់អាមេរិកនៅចិនលើកនេះ ភាគីចិនបានអះអាងថាត្រៀមខ្លួនពង្រីកទំនាក់ទំនងទ្វេភាគីដោះស្រាយនូវរាល់បញ្ហាផ្សេងៗ ឈរលើមូលដ្ឋានមានការ

យោគយល់សម្បទានគ្នាទៅវិញទៅមក និងមិនឯកភាពចំពោះអាមេរិកប្រើប្រាស់បញ្ហាសេដ្ឋកិច្ច និង
ពាណិជ្ជកម្មក្នុងគោលដៅនយោបាយ ហើយចិនបន្តរួមជាមួយអាមេរិក ក្នុងការរួមវិភាគទានកសាងសន្តិភាព សន្តិសុខ និងអភិវឌ្ឍន៍លើពិភពលោក។

- ត្រីវេជ៉ៀតជៀតពាជ

ពិនិត្យជារួមមើលឃើញថា ពេលនេះអាមេរិកនៅពុំទាន់មានគំនិតប្រើប្រាស់បញ្ហាសេដ្ឋកិច្ច និងពាណិជ្ជកម្ម ក្នុងគោលដៅនយោបាយនៅឡើយទេ។ ព្រោះបើធ្វើយ៉ាងដូច្នេះ គឺនឹងរុញឱ្យចិន
ធ្លាក់ក្នុងស្ថានភាពមួយដាច់ខាត ប្រយុទ្ធស្លាប់រស់ជាមួយនឹងអាមេរិកជាមិនខាន។ ដូច្នេះមានតែវិធីមួយទេ គឺឆ្លៀតឱកាសដែលចិនកំពុងតែអុងអាត់វាតទីកម្លាំងយោធា សំដៅគ្របដណ្តប់កាន់កាប់មកលើសមុទ្រចិនខាងត្បូងទាំងមូលធ្វើការគំរាមកំហែងវៀតណាម បង្កភាពភ័យខ្លាចមកលើអាស៊ីអាគ្នេយ៍ និងសន្តិសុខនៅអាស៊ី ជាលេសមួយអាចធ្វើឱ្យអាមេរិកប្រើប្រាស់នូវអានុភាពយោធារបស់ខ្លួនចូលមកសមុទ្រចិនខាងត្បូង និងអាស៊ីបូព៌ា បង្កើតទៅជាជំនឿទុកចិត្តមួយសម្រាប់ពួកប្រទេសនៅក្នុងតំបន់ ព្រមទាំងរួមដៃជាមួយកូរ៉េខាងត្បូងបំបាក់កូរ៉េខាងជើងផង។ ទន្ទឹមនឹងនេះក៏ដើម្បីប្រមូលផ្តុំ ប្រទេសអាស៊ានទាំងអស់ រួមទាំងពួកប្រទេសមហាអំណាចអាស៊ី ដែលមាន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា រួមទាំងរុស្ស៊ីផង ធ្វើការគាបសង្កត់បង្ខំឱ្យចិនវិលមករកស្ថានភាពដើមរបស់ប្រទេសខ្លួនវិញ ក្នុងឋានៈជាប្រទេសមួយចេះគោរពសន្តិសុខ បូរណភាពទឹកដី ដែនសមុទ្ររបស់បណ្តា

ប្រទេសភូមិ ផង។ ទន្ទឹមនឹងនេះដែរ បង្ខំឱ្យចិនត្រូវធ្វើការផ្លាស់ប្តូរនូវអត្រាប្តូរប្រាក់រវាងប្រាក់យ័ន និងប្រាក់ដុល្លារ
របស់អាមេរិក ដោយមិនទុកឱ្យជញ្ជីងពាណិជ្ជកម្មខាងខាតចេះតែផ្អៀងមករកអាមេរិក និងប្រទេសដទៃខ្លាំងពេក។ ព្រោះក្នុងស្ថានភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មនាពេលបច្ចុប្បន្ននេះ ទាំងអាមេរិក និងក្រុមប្រទេសអាស៊ាន បានក្លាយទៅជាជនរងគ្រោះផ្ទាល់នូវចរន្តនៃលំហូរទំនិញដ៏ថោក នាំចូលប្រ
ទេសខ្លួនពីប្រទេសចិន។ ព្រោះរួមទាំងសហរដ្ឋអាមេរិក និងពួកប្រទេសអាស៊ីទាំងអស់ធ្វើការនាំចូល
ប្រទេសចិនមិនជាប៉ុន្មាន តែបើចិននាំចូលវិញមានបរិមាណច្រើនហួសពីការប៉ាន់ស្មាន ដែលការនាំចេញនាំចូលទាំងនេះមានអតុល្យភាព ក្នុងជញ្ជីងទូទាត់ពាណិជ្ជកម្មទៅវិញទៅមក។

ប្រការដែលអាមេរិក ចាត់បញ្ជូនគណៈប្រតិភូជាន់ខ្ពស់ខាងសេដ្ឋកិច្ច និងសន្តិសុខ ទៅកាន់ចិននាពេលនេះ ពុំមែនជាកាយវិការសម្បទានជាមួយចិនលើផ្នែកសេដ្ឋកិច្ច ដើម្បីជាថ្នូរក្នុងការបន្ធូរបន្ថយនូវតួនាទីយុទ្ធសាស្ត្ររបស់អាមេរិក នៅក្នុងតំបន់សមុទ្រចិនខាងត្បូងនោះទេ។ តែជាតថភាពអាមេរិកកំពុងប្រើប្រាស់សម្ពាធយោធា និងកម្លាំងនយោបាយសរុបរបស់អាស៊ីទាំងមូល ដើម្បីធ្វើការបង្ខំឱ្យចិនវិលមករកភាពដើមរបស់ខ្លួនវិញ ជាប្រទេសស្រលាញ់សន្តិភាព និងគោរពដល់បណ្តាប្រទេសភូមិផង ព្រមទាំងមានជំហានសម្បទានខាងសេដ្ឋកិច្ច ពាណិជ្ជកម្ម សន្តិសុខនិងការពារជាតិផង ដែលទាំងអស់នេះហើយជាអត្ថន័យនៃកិច្ចប្រជុំ កំពូលលើកទី២អាមេរិក និងអាស៊ាន។

ដូច្នេះទាំងវិស័យសន្តិសុខ ការពារជាតិ រូបិយប័ណ្ណ និងពាណិជ្ជកម្មរបស់អាមេរិក-អាស៊ាន និងអាស៊ីមានភាពដូចគ្នា និងកំពុងតែស្ថិតអង្គុយលើទូករួមគ្នាតែមួយ ដើម្បីផ្ទាញ់ផ្ទាលនឹងអានុភាពរបស់ចិន។ នាយករដ្ឋមន្ត្រីឥណ្ឌាធ្លាប់បានប្រកាសថា វត្តមានរបស់ចិននៅតំបន់អាស៊ីខាងត្បូងមួយថ្ងៃកាន់តែច្រើនលើគ្រប់វិស័យ មិនដឹងថាចិនកំពុងតែធ្វើអ្វីនៅទីនេះ? ដូច្នេះត្រូវមានការប្រុងប្រយ័ត្នខ្ពស់ ស្របពេលដែលចិនកំពុងតែកោតសរសើរមិនអស់ពីចិត្តអំពីមីយ៉ាន់ម៉ា ជាប្រទេសភូមិផងមួយ

ដ៏ល្អនោះ។

ចំពោះហ្វីលីពីនវិញ ឆ្លៀតមានសង្គ្រាមពាក្យសំដីរវាងពួកប្រទេសធំទាំងនេះ បានប្រកាសថា កងកម្លាំងវិស្វកម្មយោធារបស់ខ្លួន បានត្រៀមចុះទៅបណ្តាកោះក្នុងតំបន់សមុទ្រចិនខាងត្បូង ដើម្បី ជួសជុលវាលយន្តហោះនិងកសាងមូលដ្ឋានយោធាបន្ថែមនៅលើកោះទាំងនេះ។ ហ្វីលីពីនបានកាន់
កាប់កោះ៩ ក្នុងចំណោមប្រជុំកោះស្ព្រាតលី(Spratlys) ដែលកោះទាំងនេះ កំពុងនៅមានបញ្ហាចម្រូងចម្រាស ជាមួយវៀតណាម ចិន ម៉ាឡេស៊ី តៃវ៉ាន់ និងប្រ៊ុយណេ ដែលពួកប្រទេសទាំងនេះបាន

ប្រកាស អធិបតេយ្យភាពលើប្រជុំកោះស្ព្រាតលី(Spratlys) តាមរៀងៗខ្លួន ហើយដែលរហូតមកដល់ថ្ងៃនេះ នៅពុំទាន់មានពន្លឺក្នុងដំណោះស្រាយណាមួយនៅឡើយ។

## ផ្នែកទី៣

# ប្រតិកម្មក្រោយពីកិច្ចប្រជុំកំពូលលើកទី២អាស៊ាន-អាមេរិក និង សភាពការណ៍នយោបាយ ទាក់ទិនដល់តំបន់សមុទ្រចិនខាងត្បូង៖

## ➢ ការចង្អុលតាមការគិតអាស៊ាន

ក្រោយពីកិច្ចប្រជុំកំពូលលើកទី២ អាស៊ាន-អាមេរិក សហរដ្ឋអាមេរិកធ្វើការអះអាង ដោយបង្ហាញឱ្យចិនឃើញថា តំបន់សមុទ្រចិនខាងត្បូងលែងជាផ្ទះបាយរបស់ចិនតទៅទៀត។ ហើយយុទ្ធសាស្ត្រថ្មីរបស់អាមេរិក គឺផ្តោតសារៈសំខាន់លើការផ្សារភ្ជាប់នូវទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយ
នឹងក្រុមប្រទេសអាស៊ាន ដែលមុននេះអាមេរិកតែងតែធ្វើការព្រងើយកន្តើយ ពុំសូវយកចិត្តទុកដាក់រាប់សិបឆ្នាំ ធ្វើឱ្យចិនមានលទ្ធភាពវាតទីពង្រឹងអានុភាពរបស់ខ្លួន ទាំងសេដ្ឋកិច្ចនយោបាយរហូតដល់កម្លាំងយោធាដែលគួរឱ្យមានការព្រួយបារម្ភ។ ប៉ុន្តែ បន្ទាប់ពីការអះអាងចូលរួមរបស់អាមេរិក នៅក្នុងតំបន់អាស៊ីសាជាថ្មីបានធ្វើឱ្យសភាពការណ៍នៅក្នុងតំបន់នេះមានការវិវត្តន៍ប្រែប្រួលទៅតាម
ចរន្តមួយថ្មី។

ក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅ មានការទិតៀនយ៉ាងខ្លាំងមកលើអាមេរិក អំពីការមើលស្រាល
របស់អ្នកកាន់អំណាចខ្លួនមកលើតំបន់អាស៊ីអាគ្នេយ៍។ព្រោះក្រៅពីមហាអំណាចនៅក្នុងតំបន់ដូចជាចិន ជប៉ុន កូរ៉េខាងត្បូង គឺសហរដ្ឋអាមេរិកហាក់ដូចជាពុំបានយកចិត្តទុកដាក់ មកលើប្រទេសអាស៊ីណាមួយឡើយ។ តែបន្ទាប់ពីចិនបង្កើនភាពខ្លាំងក្លា ទាំងនយោបាយនិងសេដ្ឋកិច្ច ប៉ះពាល់មកលើ
សិទ្ធិប្រយោជន៍របស់ប្រទេសមួយចំនួនក្នុងតំបន់ ព្រមទាំងបានធ្វើឱ្យឥទ្ធិពលរបស់អាមេរិកបង្រួមទៅៗ ចាប់ពីពេលនោះមក រដ្ឋការលោក Barack Obama ចាប់មានការប្រែធាតុ ហើយបង្កើនទាំងធនធានមនុស្សទាំងសម្ភារៈ។

ឥរិយាបថនយោបាយពេលនេះរបស់អាមេរិក គឺជាការត្រៀមទទួលយកនូវគ្រប់លក្ខខណ្ឌរបស់អាស៊ាន ឱ្យតែខ្លួនបានចូលមកដោយសុខនៅក្នុងតំបន់នេះ ដោយអាមេរិកលែងទ្រាំទ្របាននូវអំពើវាយឫក និងឥទ្ធិពលកាន់តែរីករាលដាលគ្រប់ទិសទី ពីមួយថ្ងៃទៅមួយថ្ងៃលើពិភពលោករបស់ចិនតទៅទៀត។ ត្រូវទទួលស្គាល់តថភាពមួយថា ប្រការដែលនាំឱ្យសម្រេចបាននូវស្ថានភាពពិតមួយយ៉ាងដូច្នេះ គឺចិនបានអត់ធ្មត់រក្សាកិត្យានុភាព និងតម្លៃការទូតរបស់ចិនដែលតម្លៃទាំងនេះផ្អែក

លើគោលការណ៍សន្តិសហវិជ្ជមាន និងការជួយឧបត្ថម្ភគាំទ្រដល់បណ្តាប្រទេសអាស៊ីអាគ្នេយ៍។ ចិន បន្តរក្សាជំហរ ទោះបីមានវិវាទណាមួយដ៏តូចក៏ដោយក៏ចិនរក្សាភាពអត់ធ្មត់ មិនឱ្យកើតមានឡើងជា
ដាច់ខាត ជៀសវាងការធ្វើឱ្យមានភាពមិនល្អប៉ះពាល់ដល់រូបភាពរបស់ចិននៅក្នុងតំបន់ក្នុងឋានៈប្រទេសចិនជាមិត្តរបស់បណ្តាប្រទេសតតីយលោកនោះ។

- រៀនពីសត្រូវ

ដោយសម្គាល់ឃើញសកម្មភាពខាងលើនេះ ជានយោបាយជោគជ័យរបស់ចិន ទើបរដ្ឋការ Barack Obama បានថតចម្លងធ្វើតាមចិន ដោយយកអាស៊ានជាមូលដ្ឋានស្នូលក្នុងការកែលម្អរូបភាព

របស់អាមេរិកក្នុងទស្សនៈរបស់អាស៊ានដែលយូរមកហើយអាស៊ានតែងតែសង្ស័យចំពោះអាមេរិក។ ប្រការដែលអាមេរិកចូលរួមក្នុងសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការអាស៊ីអាគ្នេយ៍១៩៧៦ នា ឆ្នាំ២០០៩ គឺដើម្បីជាការផ្លាស់ប្តូររបៀបរបបក្នុងការចូលរួមសហការអាចជាផ្នត់គំនិតថ្មីរបស់អាមេរិក
ក្នុងការខិតជិតមករកក្រុមប្រទេសអាស៊ាន។ ឥឡូវនេះក្នុងរដ្ឋការរបស់Obama យ៉ាងហោចណាស់គេឃើញថាមហាអំណាចអាមេរិកនេះ ដូចជាមិនសូវច្រងេងច្រងាងអុងអាត់ និងតាំងខ្លួនជាបងធំដើរ
បង្រៀនប្រដៅគេដូចមុនទៀត។ ហើយពួកប្រទេសអាស៊ាន ក៏លែងមានអារម្មណ៍មិនល្អយល់ឃើញថា ពួកខ្លួនលែងជា "កូនអុក" នៅក្នុងនយោបាយរបស់អាមេរិទៀត ដែលនេះធ្លាប់ជាទស្សនទានមួយកើតឡើងក្នុងសម័យកាលសង្គ្រាមត្រជាក់ ពន្យល់ទុកជាសហនិមិត្តហេតុក្នុងផ្នត់គំនិតរបស់អ្នកនយោបាយគ្រប់រូប។ ក្នុងបរិបទនៃជំនោរថ្មីនេះ ក្រុមប្រទេសអាស៊ានចិញ្ចឹមគំនិត និងសង្ឃឹមថា និងធ្វើការសម្របសម្រួលអូសទាញពួកប្រទេសមហាអំណាច ធ្វើយ៉ាងណាឱ្យមានប្រយោជន៍ដល់តំបន់មួយ ដែលធ្លាប់បានហែកហួរដោយមនោគមវិជ្ជា ឱ្យមានដំណើរវិវត្តន៍រីកចម្រើន។ បញ្ហាដែលចោទឡើងនៅទីនេះ តើពួកប្រទេសអាស៊ានមានលទ្ធភាព សមត្ថភាពគ្រប់គ្រាន់ ដើម្បីសម្របសម្រួលជាមួយពួកមហាអំណាចទាំងនេះ ឱ្យស្របតាមផលប្រយោជន៍ខ្លួនហើយ ឬនៅ?

ការផ្សារភ្ជាប់គ្នារវាងអាមេរិកនិងអាស៊ាន ក្នុងវេទិការបស់បណ្តាថ្នាក់ដឹកនាំដែលត្រូវបាន ហៅថាកិច្ចប្រជុំកំពូលអាស៊ី-បូ៣ នោះដែលជារង្វាស់មួយដ៏ល្អបំផុត អំពីការងើបឡើងរបស់លិទ្ធិ យុទ្ធសាស្ត្រប្រាកដនិយម។ ការផ្សារភ្ជាប់ទំនាក់ទំនងនេះ បានអនុញ្ញាតឱ្យអាមេរិកជួសមុខឱ្យប្លុក

អាស៊ានលើកឡើងនូវបញ្ហាទាំងឡាយ ដែលមានចរិតសំខាន់របស់តំបន់ ដូចជាសមុទ្រចិនខាងត្បូង និងបណ្តាបញ្ហាសន្តិសុខ ដែលមានលក្ខណៈដែលមិនមែនជាប្រពៃណី ។ ដូច្នេះអាមេរិក អាចធ្វើការទិទៀនចិនបានក្នុងក្របខ័ណ្ឌចង្អៀត ឬចំហជាមួយក្រុមប្រទេសអាស៊ាន ឬយ៉ាងហោចណាស់ក៏ការទិទៀនទាំងនេះមានការឯកភាពយល់ព្រមពីអាស៊ានផងដែរ។ ព្រោះគេអាចបកស្រាយលើចំនុចនេះនៅពេលដែលគេមើលឃើញថា ហេតុអ្វីបានជាចិនធ្វើការប្រតិកម្មយ៉ាងខ្លាំង មកលើពាក្យសំដីរបស់លោកស្រី Hillary Clinton ពេលដែលបានថ្លែងនៅហាណូយអំពីការវិវាទលើព្រំដែនសមុទ្រដែលយូរមកហើយ ភាគីនីមួយៗមានការលាក់លៀមមិនចំហនូវទស្សនៈរៀងៗខ្លួន អំពីបញ្ហាទំនាស់ដ៏រសើបនេះ។

ចិនទទួលផលយ៉ាងច្រើនពីទំនាក់ទំនង និងភាពជិតស្និទ្ធរបស់ខ្លួនជាមួយអាស៊ាន ក្នុងឋានៈជាប្រទេសមហាអំណាច ហើយចិនបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការអាស៊ីអាគ្នេយ៍១៩៧៦នាឆ្នាំ២០០៣ បន្ទាប់មកក៏ចាប់ផ្តើមចរចាអំពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយអាស៊ានតាំងពីបណ្តាឆ្នាំ២០០០។ ចិនចង់បង្ហាញឱ្យមតិសាធារណៈឃើញថា ខ្លួនជាប្រទេសដំបូង ដែលស្ថិតនៅខាងក្រៅតែចូលរួមក្នុង សន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការអាស៊ីអាគ្នេយ៍ ១៩៧៦ស្តីពីតំបន់អាស៊ីអាគ្នេយ៍មួយដែលពុំមានអាវុធនុយក្លេអ៊ែរ បើទោះបីជាទស្សនៈរបស់អាស៊ានចំពោះចិនពេលនោះនៅមានការស្ទាក់ស្ទើរនៅឡើយ។

ក្នុងបរិបទថ្មី សហរដ្ឋអាមេរិកទទួលស្គាល់តួនាទីស្នូលដ៏ចម្បងរបស់អាស៊ាន ក្នុងការកសាង
តំបន់ ហើយប្រធានាធិបតីអាមេរិក ជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តនូវជំហានការទូតថ្មី និងមានភាពអចិន្ត្រៃយ៍ទាំងនេះ។ ប្រធានាធិបតី Obama បានសំដែងការគាំទ្រនូវតួនាទីដ៏សំខាន់របស់អាស៊ានក្នុងការកសាងសហគមន៍តំបន់ ពេលដែលមានការជួបប្រាស្រ័យដំបូងរវាងសហរដ្ឋអាមេរិក

និងប្រមុខអាស៊ាននៅសឹង្ហបូរី នាចុងខែវិច្ឆិកា ឆ្នាំ២០០៩។ ព្រោះពេលនោះ ពុំមាននរណាម្នាក់នឹក ស្មានថា អាមេរិកមានជំហានសកម្មក្នុងការចង់ចូលរួមកិច្ចប្រជុំអាស៊ីខាងកើតនៅឡើយ ហើយទន្ទឹម
នេះផងដែរ ភាគីអាមេរិកក៏បានស្នើអញ្ជើញប្រមុខអាស៊ានទាំងអស់ ទៅចូលរួមប្រជុំជាមួយអាមេរិកនៅទីក្រុងវ៉ាស៊ីងតោនទៀតផង។

មានមតិជាច្រើន ធ្វើការប៉ាន់ស្មានថាពេលដែលរៀបចំកិច្ចប្រជុំកំពូលសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក នាឆ្នាំក្រោយនៅហាវ៉ៃ ពេលនោះប្រហែលជាសហរដ្ឋអាមេរិកមានសំណើថ្មីមួយសម្រាប់រចនាសម្ព័ន្ធក្នុងតំបន់ បន្ទាប់ពីមានការផ្តួចផ្តើមរបស់អូស្ត្រាលី ស្តីពីការបង្កើតឡើងនូវសហគមន៍អាស៊ីប៉ាស៊ីហ្វិកមួយត្រូវបានបដិសេធមក។

- ការជះឥទ្ធិពលដល់បណ្តាប្រទេសផ្សេងអំពីនយោបាយថ្មីរបស់អាមេរិក

ឥរិយាបថដាច់ខាតនិងទាន់ពេលវេលារបស់អាមេរិកនៅអាស៊ីអាគ្នេយ៍សំខាន់គឺផ្តោតមកលើ ចិន ប៉ុន្តែឥរិយាបថនេះ បានជះឥទ្ធិពលយ៉ាងទូលំទូលាយ ព្រមទាំងរុញពួកប្រទេសមហាអំណាច ផ្សេងទៀតដូចជា រុស្ស៊ី និងឥណ្ឌាឱ្យស្ថិតក្នុងស្ថានភាពមួយបាត់ភាពម្ចាស់ការទៅវិញ។ ដោយឡែក ចំពោះពួកប្រទេសមហាអំណាចថ្នាក់តំបន់វិញដូចជា ជប៉ុន អូស្ត្រាលី និងកាណាដា ក៏ត្រូវពិនិត្យ ឡើងវិញ និងកែសម្រួលគោលនយោបាយការបរទេសរបស់ប្រទេសខ្លួនឱ្យសមស្របតាមចរន្តវិវត្តន៍ របស់អាស៊ីផងដែរ។ និយាយជារួម ទីលានទាត់បាល់មួយថ្មីដែលមានសកម្មភាពផុសផុល ត្រូវបាន បង្កើតឡើងក្រោមការតាក់តែងនិងគ្រប់គ្រងទៅដោយក្រុមប្រទេសអាស៊ាន។

នៅមុនពេលសម្រេចបាននូវទិសដៅទាំងនេះគឺគោលនយោបាយរបស់អាមេរិកចំពោះតំបន់ អាស៊ីអាគ្នេយ៍ ឆ្លងកាត់ដំណាក់កាលជាច្រើនដូចនៅមុនឆ្នាំ១៩៩០ទំនាក់ទំនងរបស់ក្រុងវ៉ាស៊ីងតោន ជាមួយនឹងតំបន់នេះនៅមានកម្រិតដោយសារគ្រាន់តែជាការបង្កើតនូវសម្ព័ន្ធភាពយោធាទាំងឡាយ ដែលជាប្រពៃណីមានស្រាប់ និងក្នុងបញ្ហាសន្តិសុខមួយចំនួន ដែលមានការទាក់ទិនផ្ទាល់នឹងសហរដ្ឋអាមេរិក។ ទន្ទឹមនឹងនេះ រាល់ការខិតខំប្រឹងប្រែងក្នុងតំបន់ សំដៅជំរុញឱ្យមានការកកើតឡើងនូវ ទោះបីយន្តការពហុភាគីណាមួយអំពីសេដ្ឋកិច្ច ឬសន្តិសុខ គឺសុទ្ធតែរងនូវការជំទាស់ពីអាមេរិកទាំង អស់នាពេលនោះ។ ដូចករណីអាមេរិក បានធ្វើការបដិសេធយ៉ាងខ្លាំងនូវគម្រោងការកកើតការប្រជុំ គណបក្សអាស៊ីខាងកើត ដែលជាគំនិតផ្តួចផ្តើមរបស់នាយករដ្ឋមន្ត្រីម៉ាឡេស៊ី Mahathir Mohammad នាឆ្នាំ១៩៩១ ដែលគំនិតផ្តួចផ្តើមនេះ គ្រាន់តែក្នុងគោលបំណងចង់បង្កើនទំនាក់ទំនងសហប្រតិបត្តិ ការសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីប៉ូព៉ាតែប៉ុណ្ណោះ។

បន្ទាប់មកឆ្លងចូលអាណត្តិទី២របស់ប្រធានាធិបតីBill Clinton ពេលនោះអាមេរិកក៏ចាប់មាន ជំហានឯកភាព ក្នុងការទទួលស្គាល់នូការបង្កើតឡើងនូវយន្តការសន្តិសុខពហុភាគី ក្នុងក្របខ័ណ្ឌ នៅមានកម្រិតដោយការឯកភាពនេះ មានបំណងចង់ឱ្យជួយចែករំលែកនូវបន្ទុកដ៏ធ្ងន់របស់អាមេរិក តែប៉ុណ្ណោះ។ ពេលដែលមានទស្សនទាន ស្តីពីវេទិកាថ្នាក់តំបន់អាស៊ីជាលើកដំបូង ដែលបានស្នើ ឡើងវិញក្នុងបណ្តាឆ្នាំ១៩៩២-១៩៩៤ ដែលវេទិកានេះ មានគោលដៅលើកកម្ពស់កិត្យានុភាពរបស់ អាស៊ាន និងជាកម្លាំងសមតាមួយជាមួយនឹងចិន ព្រមទាំងពេលនោះសង្ឃឹមថានឹងអូសទាញចិនឱ្យ ចូលក្នុងទីលាននេះ ដើម្បីបញ្ឈប់សកម្មភាពរបស់ចិនក្នុងកម្រិតណាមួយក្នុងតំបន់ ត្រូវបានសហរដ្ឋ អាមេរិកវាយតម្លៃខ្ពស់។

បញ្ហាសមុទ្រចិនខាងត្បូង បានវិលមកលេងប្រទេសចិន គឺចាប់ពីមានការកកើតនូវវេទិកា
តំបន់អាស៊ាននេះមក។វេទិកាតំបន់អាស៊ានបានដើរតួនាទីយ៉ាងសំខាន់ក្នុងមុខងាជាវេទិកាសន្តិសុខសម្រាប់តំបន់ទាំងមូល ព្រមទាំងបានបំពេញភារៈកិច្ច ជាអ្នកកសាងជំនឿទុកចិត្តគ្នាទៅវិញទៅមក រវាងសមាជិកទាំង២៧។ ក្នុងបរិបទនេះ ភាគីចិនទទួលបានជោគជ័យក្នុងការបញ្ចុះបញ្ចូលអូសទាញ វេទិកាតំបន់អាស៊ាននេះ ដើម្បីជួយលើកកម្ពស់តួនាទីរបស់ខ្លួន នៅក្នុងតំបន់ដោយចិនមានយុទ្ធវិធី អាទិភាព គឺគាំទ្រនូវរាល់ទស្សនៈរបស់អាស៊ានរួមមានបញ្ហាសន្តិសុខនៅក្នុងតំបន់រួមទាំងវិបត្តិនៅលើ
ឧបទ្វីបកូរ៉េទៀតផង។ ឥឡូវនេះរាល់ដៃគូសន្ទនា សុទ្ធតែបានចូលរួមក្នុងសន្ធិសញ្ញាសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការអាស៊ីអាគ្នេយ៍១៩៧៦ ហើយតួនាទីរបស់អាស៊ានក្នុងបណ្តាបញ្ហាទាក់ទិនដល់សន្តិភាព និងសន្តិសុខក៏ត្រូវបានបង្កើននិងជំរុញយ៉ាងខ្លាំងក្លា។ មកដល់ដំណាក់កាលនេះ ចិនបានដឹងថាចរន្តនយោបាយនៅក្នុងតំបន់មានការវិវត្តន៍ប្រែប្រួល ដូច្នេះប្រការមួយដ៏ល្អបំផុត គឺចិន ត្រូវមានគោលនយោបាយថ្មី មួយដែលមានចរិតគួរឱ្យទាក់ទាញខ្ពស់ដើម្បីអូសទាញអាស៊ានឱ្យកាន់
តែមានភាពខ្លាំងក្លាឡើង សំដៅធ្វើឱ្យភាគីទាំងពីរអាស៊ាន-ចិនរួមមានផលប្រយោជន៍ទៅវិញទៅមក និងជឿទុកចិត្តគ្នា។

ចាប់ពីមានព្រឹត្តិការណ៍អមិត្តនៅលើកោះ Mischief Reefs ក្នុងប្រជុំកោះស្ព្រាតលី(Spratlys) នាឆ្នាំ១៩៩៥ មក ដើម្បីផ្លាស់ប្តូរស្ថានភាពពីភាពមិនរាក់ទាក់ ជាមួយនឹងប្លុកអាស៊ានមកកាន់ស្ថានភាពរាក់ទាក់វិញចិនត្រូវចំណាយពេលអស់១៥ឆ្នាំ។ តែឥឡូវនេះ បញ្ហាអធិករណ៍នៅក្នុងតំបន់សមុទ្រចិន
ខាងត្បូង បានវិលមកលេងពួកអ្នកបង្កើតគោលនយោបាយរបស់ចិនសាជាថ្មី ដោយទំនាស់វិវាទនេះ មានលទ្ធភាពអាចប្រែក្លាយទៅជាបញ្ហាអន្តរជាតូបនីយកម្ម។ ការវិវាទលើសមុទ្រចិនខាងត្បូងនៅតែ
ជាចំណុចខ្សោយនិងរសើបរបស់ចិន ហើយក៏នៅតែជារបាំងរាំងមួយ ក្នុងដំណើរផ្លូវឆ្ពោះទៅរកការ
បង្កើនទំនាក់ទំនងល្អរវាងអាស៊ានជាមួយនឹងចិន ចិននិងតំបន់ និងចិនជាមួយពិភពលោក។

មកដល់ពេលនេះ ក្រោយពីមានកិច្ចប្រជុំលើកទី២អាមេរិកនិងអាស៊ានមក អាមេរិកមានសេរីភាពពេញលេញក្នុងការលើកឡើងនូវរាល់បញ្ហា ដែលមានទាក់ទិនទៅដល់បញ្ហារបស់អាស៊ាន។ ក៏ប៉ុន្តែ ការលើកឡើងទាំងនេះរបស់អាមេរិកត្រូវមានភាពប៉ុិនប្រសប់ និងការថ្លឹងថ្លែងខ្ពស់ព្រោះបើការ

លើកឡើងនេះមិនឆ្លាត និងអាចបត់បែនបានរបស់អាមេរិក ក្នុងបរិបទថ្មីនេះអាចមានការប៉ះពាល់ ឬធ្វើឱ្យមានភាពទន់ខ្សោយនៅក្នុងទំនាក់ទំនងរវាងអាស៊ាននិងអាមេរិកទៅវិញ។ ត្រូវទទួលស្គាល់ការពិតមួយថាអាស៊ាននៅតែមានបំណងទទូចតាមទស្សនទានរបស់ខ្លួន ដែលចង់ឱ្យប្លុកអាស៊ានក្លាយជាចំណុចផ្ដែកឱ្យពួកមហាអំណាចមានសមតានឹងគ្នា ដើម្បីសំបូររុងរឿងដល់អាស៊ាន។ ព្រោះពេលដែលអាមេរិកមានសំឡេងផ្ដល់ការគាំទ្រដល់អាស៊ាន មកលើបណ្ដាបញ្ហានៅក្នុងតំបន់គឺប្លុកអាស៊ានបានស្វាគមន៍គាំទ្រដល់គំនិតនេះ។ ក៏ប៉ុន្តែ ក្នុងករណីដែលសភាពការណ៍វិវត្តន៍ទៅរកភាពអវិជ្ជមានដែលហួសពីព្រំដែននៃក្របខ័ណ្ឌរបស់អាស៊ានវិញ គឺប្រការនេះនឹងនាំឱ្យមានភាពធ្ងន់ធ្ងរ ក្នុងតុល្យភាពកម្លាំង ដែលពីដើមឡើយអាស៊ានមិនចង់បាននឹងមិនចង់ឃើញទាល់តែសោះ។

មានប្រទេសមួយចំនួននៅក្នុងតំបន់ពិសេសគឺវៀតណាម ហ្វីលីពីនបានសំដែងការស្វាគមន៍ចំពោះការវិលមកវត្តមានយោធារបស់អាមេរិកនៅក្នុងតំបន់នេះ ក្នុងពេលប្រទេសខ្លះពុំមានការទាក់ទិនណាមួយក្នុងអធិករណ៍នៅសមុទ្រចិនខាងត្បូងនោះ ហាក់បីដូចជាមានអារម្មណ៍មិនល្អនៅពេល ដែលឃើញអាមេរិកបានចូលមកក្នុងតំបន់នេះ។ ប្រទេសដែលមានអារម្មណ៍មិនរីករាយ មានដូចជា

កម្ពុជា ថៃ និងសិង្ហបុរី ព្រោះប្រទេសទាំងនេះមានការបារម្ភ ដោយមិនចង់ឃើញមានវិវាទណាមួយ កើតឡើងរវាងអាមេរិក និងចិនដែលហេតុការណ៍ពេលនោះ នឹងបង្ខំឱ្យពួកគេធ្វើការជ្រើសរើសផ្លូវ
ណាដែលពួកគេត្រូវដើរតាមចិនឬ អាមេរិក។ តែជារួម ពួកប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់ ពុំមានប្រទេសណាមួយចង់ឃើញ ចិន-ជប៉ុន ចិន-អាមេរិក មានការប៉ះទង្គិចគ្នាដែលជាការជះឥទ្ធិពលមួយដ៏អាក្រក់ ដល់ដំណើរការវិវត្តន៍រីកចម្រើននៅក្នុងតំបន់ទាំងមូលសោះឡើយ។

## ផ្នែកទី៤

## ចិន និងក្រុមប្រទេសអាស៊ាន ចាប់ដំណើរការពិភាក្សាអំពីក្រមប្រតិបត្តិស្តីពីតំបន់សមុទ្រចិនខាងត្បូងដោយអាមេរិកចង់ចានក្រមនេះចងនៅដោយច្បាប់៖

- ### ក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង

ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១០ ក្រុមមន្ត្រីជំនាញរបស់គ្រប់ភាគី ដែលមានការពាក់ព័ន្ធចិន និង អាស៊ានបានចាប់ផ្តើមមានដំណើរការពិភាក្សាគ្នា លើមូលដ្ឋានសេចក្តីប្រកាសលើក្រមប្រតិបត្តិស្តីពី

សមុទ្រចិនខាងត្បូង ឆ្នាំ២០០២ ដើម្បីរួមគ្នាកសាងក្រមប្រតិបត្តិមួយ ស្តីពីតំបន់សមុទ្រចិនខាងត្បូង ក្នុងគោលបំណងធ្វើយ៉ាងណា ដើម្បីបង្ការកុំឱ្យមានការកើតឡើងជាយថាហេតុណាមួយ អំពីអធិករណ៍ជុំវិញការវិវាទបូរណភាពទឹកដីលើសមុទ្រចិនខាងត្បូង ដែលអាចក្លាយទៅជាការប៉ះទង្គិចគ្នាជាប្រដាប់អាវុធនោះ។ នេះអាចជាជំហាននៃសញ្ញាមួយបញ្ជាក់ឱ្យឃើញថា ភាគីទាំងអស់មានបំណងចង់បង្កើនការខិតខំប្រឹងប្រែង សំដៅរក្សាសន្តិភាព ស្ថេរភាពក្នុងតំបន់ បន្ទាប់ពីមានសង្គ្រាមពាក្យសំដី ថែមទាំងសកម្មភាពការទូតមុននិងក្រោយកិច្ចប្រជុំថ្នាក់ដឹកនាំកំពូលលើកទី២អាមេរិកនិងអាស៊ាន

ដែលហេតុការណ៍ទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការអះអាង ក្នុងសេចក្តីថ្លែងការណ៍រួមរបស់កិច្ចប្រជុំថ្នាក់ដឹកនាំកំពូលលើកទី២នៃអាមេរិក និងអាសា៊ន នាថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១០ នៅទីក្រុង ញូវយ៉កកន្លងមក។ កិច្ចពិភាក្សាក្នុងកម្រិតអ្នកជំនាញ លើក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងនេះ

ក៏មានរបៀបវារៈមួយស្តីពីវិធានការដាក់ទណ្ឌកម្មលើប្រទេសណាមួយ ដែលមានការពាក់ព័ន្ធនៅក្នុងការវិវាទ ហើយពុំបានគោរពនូវលក្ខខណ្ឌរបស់ក្រមប្រតិបត្តិ ស្តីពីសមុទ្រចិនខាងត្បូងនោះផងដែរ។

សមុទ្រចិនខាងត្បូង ជាសមុទ្រមួយដែលមានផ្ទៃក្រឡា ៣,៥ លានគីឡូម៉ែត្រគូប ដែលមានវិសាលភាពរត់ពីឈូងសមុទ្រតៃវ៉ាន់ រហូតដល់ប្រទេសហ្វីលីពីន ដែលជាតំបន់ប្រជុំទៅដោយកោះ (archipelago) ដែលរួមមានទាំងកោះធំ កោះតូច កោះក្នុងបាតសមុទ្រ ដីខ្ពស់នៅក្រោមផ្ទៃទឹក ហើយដែលគេជឿថាតំបន់ទាំងនេះសំបូរទៅដោយជលផល រុក្ខសាគរ វត្ថុធាតុដើម រ៉ែហ្គាស និងប្រេងកាត តែក៏ត្រូវបានចាត់ទុកថា ជាតំបន់ទំនាស់មួយដ៏ស្រួចស្រាវធំបំផុតនៅអាស៊ីផងដែរ។ ចិន ហ្វីលីពីន វៀតណាម ម៉ាឡេស៊ី ប្រ៊ុយណេ និងតៃវ៉ាន់ សុទ្ធតែបានអះអាងអធិបតេយ្យភាព ព្រមទាំងមានការបោះទីតាំងកងទ័ពនៅលើកោះទាំងនេះ លើកលែងតែប្រទេសប្រ៊ុយណេមួយចេញ ដែលពុំមានទ័ពក្នុងតំបន់ប្រជុំកោះទាំងនេះឡើយ។

មុននេះចិន ពុំទទួលស្គាល់ក្រមប្រតិបត្តិស្តីពីបញ្ហាតំបន់សមុទ្រក្នុងសមុទ្រចិនខាងត្បូងដែលរៀបចំតាក់តែងដោយវៀតណាម និងហ្វីលីពីននាឆ្នាំ១៩៩៩ទេ ដោយពេលនោះចិនយល់ថា សេចក្តីព្រាងក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងរបស់វៀតណាម និងហ្វីលីពីន ហាក់បីដូចជាការជួយបំពេញចរិតនីត្យានុកូលភាព នូវអ្វីដែលជាការប្រកាសទាមទារអធិបតេយ្យ របស់បណ្តារដ្ឋផ្សេងទៀតនៅក្នុងតំបន់នេះ។ ប៉ុន្តែចិនបានបើកទ្វារចំហទទួលនូវរាល់រូបមន្ត និងគំនិតផ្តួចផ្តើមផ្សេងទៀតឱ្យតែ គម្រោងការផ្សេងគ្នាទាំងនេះមានបំណងល្អក្នុងការរក្សាសុខសន្តិភាព សំបូររុងរឿង និងស្ថេរភាពយូរ

អង្វែងនៅក្នុងតំបន់សមុទ្រចិនខាងត្បូងនេះ។ តែទោះបីជាចិនមានជំហរទូលំទូលាយជាងមុនក្នុងកាលៈទេសៈនេះក៏ដោយ ក៏ពុំមែនមានន័យថាចិនមានជំហានដើរថយក្រោយ ឬមានសកម្មភាពសម្បទានណាមួយអំពីបូរណភាព អធិបតេយ្យភាពរបស់ខ្លួនលើសមុទ្រចិនខាងត្បូងឡើយ។

➢ អាមេរិកជ្រៀតជ្រែកក្នុងក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង

ក្នុងបរិបទថ្មីនេះ អាមេរិកធ្វើការអះអាងជាដាច់ខាត ដោយបានធ្វើការគាំទ្រនូវគោលការណ៍សេរីភាពក្នុងការធ្វើនាវាចរណ៍ក្នុងតំបន់ ដែលក្នុងពេលនោះចិនបានចោទប្រកាន់ថាអាមេរិកសំដែង ការបារម្ភអំពីសេរីភាពក្នុងការធ្វើដំណើរក្នុងសមុទ្រចិនខាងត្បូងនេះ គ្រាន់តែជាលេសនយោបាយ មួយ ដើម្បីអាមេរិកមានលេសវិលមកវត្តមានជាយោធានៅក្នុងតំបន់នេះតែប៉ុណ្ណោះ។ ព្រមទាំងចិន បានថ្កោលទោសអាមេរិកថា បាននិងកំពុងជ្រៀតជ្រែកចូលមកក្នុងកិច្ចផ្ទៃក្នុងរបស់អាស៊ី អាមេរិកពុំ មានលក្ខណៈសម្បត្តិណាមួយដើម្បីធ្វើអន្តរាគមន៍ ដោយអាមេរិកជាប្រទេសមួយដែលស្ថិតនៅក្រៅ តំបន់ ហើយបញ្ហាទាំងអស់នេះជាបញ្ហារវាងចិនជាមួយបណ្តាប្រទេសនៅក្នុងតំបន់ ដូច្នេះប្រការខិត

ខំជំរុញឱ្យមានអន្តរជាតូបនីយកម្ម មកលើបញ្ហាសមុទ្រចិនខាងត្បូងនេះ គ្រាន់តែជាអំពើមួយនាំឱ្យបញ្ហានេះ កាន់តែមានភាពពិបាកស្មុគ្រស្មាញឡើងតែប៉ុណ្ណោះ។ ចំពោះសេរីភាព ក្នុងការធ្វើនាវាចរ ណ៍ រួមទាំងនាវារបស់សហរដ្ឋអាមេរិកដែលធ្វើដំណើរនៅក្នុងតំបន់នេះ អត់មានបញ្ហាអ្វីទេឱ្យតែពួក

គេគោរព និងប្រតិបត្តិតាមគោលការណ៍របស់អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីនីតិសមុទ្រ ឆ្នាំ ១៩៨២បានហើយ។ អាមេរិកត្រៀមខ្លួនជួយ ធ្វើសេចក្តីព្រៀងគោលការណ៍ក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង ដើម្បីធ្វើយ៉ាងណាជួយបញ្ចប់នូវវិវាទរវាងអាស៊ាន និងចិនដែលសភាពការណ៍នេះកំ ពុងតែយាយីមកលើស្ថេរភាពនៅក្នុងសមុទ្រចិនខាងត្បូង។ អាមេរិកស្នើឱ្យ ប្រទេសអាស៊ានទាំង ១០ និងចិនរួមគ្នាពិភាក្សាលើគោលការណ៍ក្រមមួយ ដែលមានចរិតចងទៅដោយច្បាប់ សំដៅធានាដល់ រាល់ការធ្វើចរាចរណ៍របស់នាវាទាំងអស់ ដោយពុំមានឧបសគ្គណាមួយកើតឡើង រារាំងដល់ដំណើរ

នាវាចរណ៍ពាណិជ្ជកម្ម។ អាមេរិកក៏ពុំចង់ឃើញមាននូវទំនាស់ ឬសង្គ្រាមណាមួយកើតឡើង ហើយអាមេរិកក៏មិនឈរក្នុងជួរភាគីណាមួយដើម្បីប្រឆាំងភាគីណាមួយដែរ។

១០ឆ្នាំមុន អាស៊ាននិងចិន ធ្លាប់បានចុះហត្ថលេខាលើសេចក្តីប្រកាសលើក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងមួយ តែពុំមានចរិតចងទៅដោយច្បាប់ ដែលគ្រាន់តែជាគោលការណ៍អំពាវនាវឱ្យមានដំណោះស្រាយដោយសន្តិវិធី សំដៅបញ្ឈប់នូវទោះបំអំពើ ឬសកម្មភាពណាមួយដែលអាចនាំទៅកើតជាអធិករណ៍តែប៉ុណ្ណោះ។ ដូច្នេះជំហររបស់អាមេរិកនាពេលនេះគឺស្នើឱ្យមានការចងក្រងច្បាប់ថ្មីដែលស្ថិតក្នុងតំបន់ជម្លោះ ដើម្បីជាការធានាបាននូវស្ថេរភាពក្នុងតបំបន់ និងសេរីភាពនៃការធ្វើនាវាចរណ៍ពាណិជ្ជកម្មអន្តរជាតិ ហើយអាមេរិកមានសេចក្តីរីករាយ ដោយមានឆន្ទៈក្នុងការពង្រីកជំនួយណាមួយនៅពេលការចរចារចាប់ផ្តើមមានសញ្ញាវិជ្ជមានដូចជាកិច្ចព្រមព្រៀង។

➢ ហ្វីលីពីន និងចិនប្រឈមមុខដាក់គ្នា

ក្នុងកំឡុងពេល ចូលរួមកិច្ចប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិ នៅទីក្រុងញូវយក
ប្រធានាធិបតី Benigno S. Aquino III របស់ហ្វីលីពីនមានប្រសាសន៍ អំពីសមុទ្រចិនខាងត្បូងមួយថ្ងៃមុនកិច្ចប្រជុំកំពូលលើកទី២អាមេរិក និងអាស៊ានស្តីពីកម្មវត្ថុនៃការវិវាទជុំវិញអធិបតេយ្យភាពនៅក្នុង សមុទ្រចិនខាងត្បូង ដោយភាគីហ្វីលីពីនបានអះអាងថា អាស៊ាននឹងរួមគ្នាទៅជាប្លុកមួយ ក្នុងករណី ដែលចិនប្រើប្រាស់នូវកម្លាំងបាយជាមធ្យោបាយ ក្នុងការដោះស្រាយនូវបញ្ហាវិវាទ ដែលកើតមាន ឡើងក្នុងសមុទ្រចិនខាងត្បូងនេះ ទន្ទឹមនេះប្រធានាធិបតី Aquino III ក៏បានបញ្ជាក់បន្ថែមថា រហូត

មកដល់ពេលនេះ នៅពុំទាន់ឃើញចិនមានការគៀបសង្កត់ណាមួយមកលើពួកយើង។ ហើយខ្ញុំសូម សំណូមពរ ដោយយើងគួរតែបញ្ឈប់ប្រើឈ្មោះ“សមុទ្រចិនខាងត្បូង South China Sea”ទៀត។ ព្រោះ
ថាឈ្មោះនេះហាក់បីដូចជាមានអត្ថន័យបង្កប់ ដោយទទួលស្គាល់ជាយថាហេតុថាសមុទ្រនេះជាកម្មសិទ្ធិរបស់ចិនរួចទៅហើយ។

នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៥ មានសញ្ញាលួចជ្រៀតចូលកាន់កាប់របស់កងទ័ពចិននៅម្តុំ កោះ Mischief Reef ដែលហ្វីលីពីនចាត់ទុកថាតំបន់នេះជាដែនដី Kalayaanស្ថិតក្នុងបូរណភាពដែនដី
របស់ហ្វីលីពីន។ ក្រោយមក កងទ័ពរបស់ប្រទេសទាំងពីរមានការផ្ទុះអាវុធដាក់គ្នា ហើយនេះក៏អាចជាលើកដំបូងដែលចិនមានការប្រទូស្តរាយជាកម្លាំងអាវុធ ដោយផ្ទាល់ជាមួយសមាជិកអាស៊ានម្នាក់អំពីបញ្ហាបូរណភាពដែនសមុទ្រនៅលើសមុទ្រចិនខាងត្បូងនោះ។

ព្រឹត្តិការណ៍ Mischief Reef នេះបានកើតឡើងក្នុងទិដ្ឋភាពមួយដ៏ពិសេសដែលពេលនោះកងទ័ពអាមេរិក ទើបតែបានដកចេញផុតពីមូលដ្ឋានយោធានៅ Subic និងClark ក្នុងប្រទេសហ្វីលីពីននាឆ្នាំ១៩៩២។ ហើយនេះក៏ជាលើកដំបូង ដែលសមុទ្រចិនខាងត្បូងស្ថិតក្នុងស្ថានភាពមួយពុំមានអំណាចខ្លាំងក្លាណាមួយទីនេះ ដែលជាឱកាសមាសប្រាក់ដើម្បីចិនអះអាងនិងបន្តវត្តមានជាយោធារបស់ខ្លួន លើប្រជុំកោះក្នុងតំបន់សមុទ្រចិនខាងត្បូងនេះ។ ប្រធានាធិបតី Fidel Ramos បានថ្កោលទោសការទន្ទ្រានកាន់កាប់នេះ ព្រមទាំងមានវិធានការជាយោធាឆ្លើយតបទៅវិញ ដោយបញ្ជាឱ្យកង
ទ័ពហ្វីលីពីន ធ្វើការបំផ្លិចបំផ្លាញនូវរាល់ស្លាកស្នាម និងបង្គោលសម្គាល់អធិបតេយ្យភាពរបស់ចិននៅលើ Mischief Reef ទាំងនេះ។

តែក្រោយមក ដោយមានជំហានសម្របសម្រួលជាបន្តបន្ទាប់មក ប្រទេសទាំងពីរហ្វីលីពីន និងចិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីជាច្រើនក្នុងកិច្ចព្រមព្រៀងទាំងនេះមិនអនុញ្ញាតឱ្យមានការប្រើប្រាស់កម្លាំងបាយ ក្នុងការដោះស្រាយនូវការទំនាស់វិវាទ ព្រមទាំងរួមគ្នាអំពាវនាវឱ្យមានការគោរពអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីនីតិសមុទ្រឆ្នាំ១៩៨២ទាំងអស់គ្នា។

<u>ផ្នែកទី៥</u>

## ប្រតិកម្មអន្តរជាតិជុំវិញខ្លឹមសារ ក្នុងសេចក្តីថ្លែងការណ៍រួមកិច្ចប្រជុំកំពូល លើកទី២ អាស៊ាន-អាមេរិក និងទស្សនវិស័យឈានទៅដល់ការកកើតសហប្រតិបត្តិការយោធាអាមេរិក-អាស៊ាន៖

- ទស្សនៈរបស់ពួកអ្នកវិភាគអន្តរជាតិ

ពួកអ្នកវិភាគអន្តរជាតិអះអាងថា សេចក្តីថ្លែងការណ៍កិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ាន-អាមេរិក នាថ្ងៃទី២៤ កញ្ញា ២០១០ នៅក្រុងញូវយ៉ក គឺជាសេចក្តីថ្លែងការណ៍មួយដែលមានលក្ខណៈពិសេសដំបូងមុនគេបង្អស់ បន្ទាប់ពីមានការកកើតនូវអង្គការសហប្រជាជាតិមក។ ព្រោះសេចក្តីថ្លែងការណ៍រួមគ្នានេះ ជាអត្ថបទនយោបាយរវាងមហាអំណាចមួយ និងប្រទេស១០ របស់អាស៊ានទាំងអស់១១ ដែលប្រទេសទាំង១១នេះ មានស្ថានភាពលក្ខណៈសម្បត្តិខុសគ្នាទាំងស្រុង ទាំងពីរបបនយោបាយ ទាំងបែបផែនសេដ្ឋកិច្ច រហូតដល់ជំនឿ សាសនា វប្បធម៌ និងសតិអារម្មណ៍ទៀតផង។ ខ្លឹមសារ និង

អត្ថន័យរបស់សេចក្តីថ្លែងការណ៍នេះអាចនឹងធ្វើឱ្យអ្នកទាំងឡាយយល់គ្រប់ជ្រុងជ្រោយយ៉ាងច្បាស់ គឺបន្ទាប់ពីនេះច្រើនឆ្នាំទៀត នៅពេលដែលគោលដៅ និងកម្មវិធីសកម្មភាពទាំងឡាយរបស់សេចក្តីថ្លែងការណ៍រួមនេះ ត្រូវយកទៅធ្វើឱ្យទៅជាភាពជាក់ស្តែង និងពេលអត្ថបទនយោបាយនៃសេចក្តី ថ្លែងការណ៍រួមនេះ បានក្លាយទៅជាគ្រឹះជាអំណាចបន្ថែមមាន តួនាទីសម្រេចលើការប្រែប្រួលផ្លាស់

ប្តូរជាសារវន្ត ចំពោះផែនទីយុទ្ធសាស្ត្រនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និយាយដោយឡែក និងក្នុងតំបន់ប៉ាស៊ីហ្វិកខាងលិចនិយាយជារួមមក។

ពួកអ្នកនយោបាយអន្តរជាតិ ធ្វើការរិះគន់លើពាក្យពេចន៍មួយម៉ាត់ក្នុងសេចក្តីថ្លែងការណ៍រួមរបស់កិច្ចប្រជុំថ្នាក់ដឹកនាំលើកទី២នេះ តែប្រហែលជាមានប្រការមួយដែលគួរឱ្យចាប់អារម្មណ៍ និងយកចិត្តទុកដាក់ជាទីបំផុតនោះគឺបញ្ហាយោធាក្នុងសេចក្តីថ្លែងការណ៍រួមនេះដែលនឹងត្រូវពន្យល់បកស្រាយក្នុងកម្រិតណានោះ? ព្រោះនៅក្នុងសេចក្តីថ្លែងការណ៍រួមនេះ បានសង្កត់ធ្ងន់ថា “អាស៊ានវាយតម្លៃខ្ពស់ ចំពោះការអះអាងចូលរួមរបស់សហរដ្ឋអាមេរិក ក្នុងកម្រិតខ្ពស់បំផុតជាមួយប្រទេសដែលជាសមាជិកអាស៊ានភាគីទាំងអស់ដែលបានចូលរួមក្នុងសេចក្តីការណ៍មានការពេញចិត្តចំពោះការអះអាងយ៉ាងរឹងមាំរបស់អាមេរិក ក្នុងការបន្តជំរុញទំនាក់ទំនងទៅលើគ្រប់វិស័យជាមួយអាស៊ាន លើកកម្ពស់ទំនាក់ទំនងភាពជាដៃគូឆ្ពោះទៅកាន់កម្រិតយុទ្ធសាស្ត្រមួយ។

### ➢ ភាពស្ទាក់ស្ទើររបស់អាស៊ានក្នុងការចាប់យកអាមេរិក

ជាទស្សនរួមក្នុងទំនាក់ទំនងអន្តរជាតិប្រទេសដែលពុំសូវមានការទាក់ទិនក្នុងអត្ថប្រយោជន៍ គឺមានទស្សនវិស័យក្នុងការចូលរួមដោះស្រាយបញ្ហាជាច្រើន តែសម្របសម្រួលតាមនិន្នាការរួមរបស់ផលប្រយោជន៍រួម ដោយពុំមានចរិតអត្តនោម័តនៅក្នុងដំណោះស្រាយរបស់បញ្ហាឡើយ។ ពិនិត្យក្នុងស្ថានភាពរួមនេះ គឺអាមេរិកទេដែលត្រូវការអាស៊ាន ច្រើនជាងអាស៊ានត្រូវការអាមេរិក។ ព្រោះក្នុងភូមិសាស្ត្រយុទ្ធសាស្ត្រទោះបីជាមហាអំណាចណាក៏ដោយឱ្យតែមានអានុភាពយោធាគ្របដណ្តប់លើសមុទ្រចិនខាងត្បូងបាន គឺប្រទេសនេះនឹងធ្វើជាម្ចាស់នៃសរសៃឈាមសេដ្ឋកិច្ច ហើយប្រសិនបើអាមេរិកដណ្តើមតំបន់នេះតួនាទីរបស់អាមេរិកដែលជាមហាអំណាចទី១នោះ ក៏លែងមានអ្នកហ៊ានប្រកួតប្រជែងដែរ។ អំពីវិស័យសេដ្ឋកិច្ច និងការធ្វើចរាចរណ៍លើសមុទ្រវិញ គឺសមុទ្រចិន

ខាងត្បូង គឺជាកូនសោរមួយដ៏សំខាន់ក្នុងការ “បើកទ្វារ” ចេញទៅកាន់តំបន់សមុទ្រឥណ្ឌា និងប៉ាស៊ី ហ្វិក។ ហើយបើគិតអំពីទិដ្ឋភាពយុទ្ធសាស្ត្រនៅក្នុងតំបន់វិញ ការកាន់កាប់បានសមុទ្រចិនខាងត្បូង ជាការគំរាមកំហែងដោយផ្ទាល់មកលើសន្តិសុខ និងសុវត្ថិភាពទាំងមូលមកលើកម្លាំងអាមេរិក ដែល

វត្តមាននៅលើប្រជុំកោះ Caroline និង Mariana ដែលកោះទាំងពីរនេះ ស្ថិតនៅមិនឆ្ងាយពីប្រជុំកោះ ស្ព្រាតលី (Spratlys) មិនដល់ 2.000 ម៉ែល៍ផងនោះ។

ដោយតំបន់សមុទ្រចិនខាងត្បូង បានក្លាយទៅជាអត្ថប្រយោជន៍ស្លាប់រស់ក្នុងអនាគតយ៉ាង ដូច្នេះទើបខ្លឹមសារនៅក្នុងសេចក្តីថ្លែងការណ៍រួមកិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ាន-អាមេរិកលើកទី២កន្លង

មក ភាគីអាមេរិកមានជំហានសម្បទានជាមួយអាស៊ានដ៏ច្រើន ក្នុងបញ្ហាមួយពោរពេញទៅដោយការចម្រូងចម្រាស គឺបញ្ហាដ៏រសើបអំពីសិទ្ធិមនុស្សនៅមីយ៉ាន់ម៉ា។ ការធ្វើសម្បទានរបស់អាមេរិកអំពីបញ្ហាមីយ៉ាន់ម៉ាត្រូវបានប្តូរទូទាត់មកវិញ ដោយអាស៊ានក៏មានជំហានសម្បទានជាមួយអាមេរិកក្នុងបញ្ហាតន្លឹះមួយចំនួន ក្នុងនោះមានបញ្ហាប្រទេសអុីរ៉ង់ និងប្រទេសកូរ៉េខាងជើងផងដែរ។

ការគំរាមកំហែងពីខាងក្រៅមកលើសន្តិសុខរបស់អាស៊ាន ជាប្រការមួយដែលគ្មាននរណាម្នាក់ដែលមិនដឹងអំពីហេតុការណ៍ទាំងនេះឡើយ។ ប៉ុន្តែរហូតមកដល់ពេលនេះ នូវពុំទាន់មានកិច្ចព្រមព្រៀងសហប្រតិបត្តិការពិតប្រាកដដោយឡែកណាមួយ អំពីយោធាជាមួយនឹងអាមេរិកនៅ ឡើយទេ។ អាចមានមូលហេតុជាច្រើន តែមូលហេតុដ៏ចម្បងបំផុតនោះគឺគ្មានប្រទេស “ក” ណាមួយ

មានបំណងចង់ចងសម្ព័ន្ធភាពយោធា ជាមួយនឹងអាមេរិកនៅឡើយទេ។ ព្រោះការចងសម្ព័ន្ធភាព យោធានោះ អាចក្លាយជាសកម្មភាពមួយដោយយថាហេតុបានដាក់ប្រទេស“ក”នេះ ឱ្យស្ថិតនៅក្នុង ស្ថានភាពផ្ទាញ់ផ្ទាលដោយផ្ទាល់ទៅនឹងអានុភាពរបស់មហាអំណាចចិនទៅហើយ។ព្រោះការព្រួយ

បារម្ភទាំងនេះ ពុំមែនជាការបាម្ភដែលពុំមានមូលដ្ឋាននោះទេ ដោយគេសង្កេតឃើញនយោបាយនាពេលនេះ ជាល្បែងនយោបាយមួយពោរពេញទៅដោយកលយុទ្ធពឹសពុល បើប្រៀបធៀបទៅនឹង សម័យមុនឆ្ងាយគ្នាណាស់ ដោយពេលនេះមានភាពទំនើប និងស្មុគ្រស្មាញបំផុតសម្រាប់សកម្មភាព

លើក្តារអុកនយោបាយអន្តរជាតិ។ ដូច្នេះបើប្លុកអាស៊ាន មានកិច្ចសហប្រតិបត្តិការយោធាផ្លូវការជាមួយអាមេរិក គឺអាចចៀសផុតពីការបារម្ភអំពីការដាក់ទណ្ឌកម្ម ព្រោះគេអាចដាក់ទណ្ឌកម្មមកលើ

ប្រទេសមួយ តែគេមិនអាចដាក់ទណ្ឌកម្មមកលើប្រទេស១០ស្របពេលតែមួយនោះទេ ដែលនេះជាការលំបាកមួយ។ ម្យ៉ាងវិញទៀត សេចក្តីបារម្ភដ៏ធំបំផុតរបស់អាស៊ាននាពេលបច្ចុប្បន្នគឺខ្លួនអាស៊ានដោយផ្ទាល់តែម្តង គឺបារម្ភអំពីភាពបែកបាក់សាមគ្គីភាពផ្ទៃក្នុងរបស់អាស៊ាន។ ការជួបចរចាដោយឡែក ឬកិច្ចព្រមព្រៀងជាឧបតោភាគី គ្រាន់តែជាវិធីសាស្រ្តមួយក្នុងនយោបាយបែងចែកដើម្បីងាយស្រួលគ្រប់គ្រង ហើយនេះក៏ជាវិធានការមួយដ៏មានប្រសិទ្ធភាពបំផុត ក្នុងការធ្វើឱ្យអាស៊ានកាន់តែ

ខ្សោយទៅៗ ស្លាប់ជាបណ្តើរៗក្នុងភាពមន្ទិលសង្ស័យដាក់គ្នាប្រឈមមុខដាក់គ្នាដែលមិនគួរឱ្យមាន
សោះឡើយ។

មេរៀនប្រវត្តិសាស្ត្រថ្មីសម្រាប់ប្រទេសតូច គឺការចងសម្ព័ន្ធភាពសាមគ្គីភាពនឹងគ្នាឱ្យកាន់តែមានភាពជិតស្និទ្ធ និងមានប្រសិទ្ធភាពល្អ ជាជាងមានកិច្ចសហប្រតិបត្តិការយោធាលើគ្រប់វិស័យជាមួយសហរដ្ឋអាមេរិក។ ដែលអ្នកវិភាគយល់ថាជាផ្លូវតែមួយគត់របស់អាស៊ាន ក្នុងការការពារអធិបតេយ្យភាព បូរណភាពទឹកដី និងដើម្បីធ្វើឱ្យអាស៊ានក្លាយជាអានុភាពដ៏រឹងមាំពិតប្រាកដ ទាំងក្នុងតំបន់ និងលើពិភពលោកនាពេលបច្ចុប្បន្ន។ សេចក្តីថ្លែងការណ៍រួម ក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ាន-អាមេរិកលើកទី២ គឺជាទ្វារដែលបានបើកទូលាយនៅពេលដែលឈានជើងឆ្លងកាត់ហើយ។

បញ្ហាបច្ចុប្បន្នថា តើដល់ពេលណាដែលប្លុកអាស៊ានឃើញថា មានភាពចាំបាច់ត្រូវមានកិច្ច សហប្រតិបត្តិការនោះ? ហើយកិច្ចសហប្រតិបត្តិការនេះត្រូវស្ថិតក្នុងកម្រិតត្រឹមណា? ព្រោះនៅក្នុង
សេចក្តីថ្លែងការណ៍រួមនេះ មានឃ្លាមួយបានសរសេរយ៉ាងចាប់ចិត្ត និងផ្តល់សារៈសំខាន់ថា យើងស្វាគមន៍ដល់គំនិតលើកកម្ពស់ទំនាក់ទំនងជាដៃគូរបស់យើង ដើម្បីឆ្ពោះទៅកាន់កម្រិតយុទ្ធសាស្ត្រ ហើយក្រុមឥស្សរជនឆ្នើមនឹងទទួលភារកិច្ច ក្នុងការធ្វើឱ្យទៅជាភាពជាក់ស្តែង និងពិតប្រាកដនូវអនុ
សាសន៍ទាំងឡាយឱ្យចប់ជាស្ថាពរនាឆ្នាំ២០១១។

ដូច្នេះ នៅពេលដែលប្រើពាក្យពេចន៍ថាយើងហើយ គឺពុំមានអ្វីជាដោយឡែកទៀតទេ បញ្ហា ចុងក្រោយគឺក្រុមឥស្សរជនឆ្នើមរបស់អាស៊ាន និងអាមេរិកមានលទ្ធភាពស្វែងរកសំឡេងទូទៅមួយ
ដែលមានភាពឆ្លាតវៃ និងប្រកបទៅដោយភាពប្រាកដនិយមពិតប្រាកដដែរឬអត់? បើគោលដៅនិងផលប្រយោជន៍នូវមានភាពខុសគ្នាទាំងនេះ។ ដូចមនុស្សពីរនាក់គេងគ្រែតែមួយតែសុបិន្តខុសគ្នា។

## <u>ផ្នែកទី១</u>

## ទំនាក់ទំនងចិន-អាស៊ាន និងទំនាក់ទំនងអាមេរិក-ចិន-អាស៊ាន ក្នុងបរិបទថ្មី បន្ទាប់ពីការអះអាងអធិបតេយ្យភាពដែនសមុទ្រលើសមុទ្រចិនខាងត្បូងត្រូវបានពុះកញ្ជ្រោលឡើង៖

- ### ចិនកើនឥទ្ធិពល ដោយសារការព្រងើយកន្ដើយរបស់អាមេរិក

លោក Lee Kwan Yew អតីតនាយករដ្ឋមន្ត្រីសិង្ហបុរី ទើបនឹងបានផ្ដល់អនុសាសន៍មួយថាចិនមិនគួរមានអំពើណាមួយឱ្យហួសហេតុពេក ក្នុងការចាប់បង្ខំលើពួកប្រទេសតូច នៅក្នុងប្លុកអាស៊ាន ព្រោះការធ្វើទាំងអស់នេះ បានត្រឹមតែនាំឱ្យចិនទទួលបានត្រឹមតែការខាតបង់ប៉ុណ្ណោះ។ លោក Lee Kwan Yew បានធ្វើការវិភាគជុំវិញដំណើរវិវត្តន៍នាពេលថ្មីៗនេះ ក្នុងទំនាក់ទំនងត្រីកោណអាមេរិក-ចិន និងអាស៊ាន ដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងសមុទ្រចិនខាងត្បូង។

ដោយរវល់ជាប់ផុងជាមួយការធ្វើសង្គ្រាមនៅអុីរ៉ាក់និងអាហ្វហ្គានីស្ថានមក អាមេរិកបាន ទុក ចោលតំបន់អាស៊ីខាងកើត និងតំបន់ប៉ាស៊ីហ្វិកទៅម្ខាង ទុកឱ្យតួឯកចិនសំដែងរឿងស្រេចតែចិត្តនៅ ក្នុងតំបន់ ដែលគ្មាននរណាម្នាក់ហ៊ាននិយាយស្តីស្ទីម្បីតែក្អកឡើយ។ តែឥឡូវនេះ នៅពេល អាមេរិក សម្រេចចិត្តបោសសម្អាតការធ្វើសង្គ្រាមរបស់ខ្លួននៅអុីរ៉ាក់ និងលើកផែនការដកទ័ព ទាំងអស់ចេញ ពីអាហ្វហ្គានីស្ថាន នាឆ្នាំ២០១១នេះមក មជ្ឈដ្ឋានអ្នកកាន់អំណាចរបស់រដ្ឋការ Barack Obama បាន សម្រេចស្តារអំណាច និងឥទ្ធិពលរបស់ប្រទេសអាមេរិកនៅអាស៊ីខាងកើត និងក្នុងតំបន់ប៉ាស៊ីហ្វិក ទាំងមូលទៀតវិញ។

ហេតុអ្វីបានជាសកម្មភាពទាំងនេះមានសារៈសំខាន់យ៉ាងដូច្នេះ? ពីព្រោះគន្លឹះសំខាន់នេះគឺ ផ្តើមចេញពីបញ្ហាសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយរបស់ពិភពលោក ដែលកំពុងតែមានភាពប្រែប្រួលវិវត្តន៍ពីតំបន់អាត្លង់ទិចមកតំបន់ប៉ាស៊ីហ្វិកវិញ។ ទំនាក់ទំនងពាណិជ្ជកម្មវិនិយោគទុននិងសេដ្ឋកិច្ច ទាំងក្នុងតំបន់អាត្លង់ទិច ទាំងក្នុងតំបន់ប៉ាស៊ីហ្វិកមានការរីកផុសផុលនិងធ្វើឱ្យតំបន់ទាំងនេះប្រែ ក្លាយជាតំបន់មួយដែលមានសារៈសំខាន់ និងប្រកបទៅដោយថាមពលខ្លាំងក្លាបំផុតលើពិភពលោក នាសតវត្សរ៍ទី២១នេះ។ ប៉ុន្តែ ដើម្បីប្រែខ្លួនឱ្យក្លាយជាមហាអំណាចប្រកបដោយឧត្តមភាពផុតលេខ ទាមទារឱ្យប្រទេសទាំងនេះ ត្រូវប្រមូលផ្តុំនូវឆន្ទៈ និងគ្រប់មធ្យោបាយទាំងអស់ ដើម្បីបម្រើឱ្យគោល
ដៅតែមួយនេះ។

## ➢ ចិនបញ្ចោញដែនទីអក្សរប

នៅខែឧសភា ឆ្នាំ២០០៩ ម៉ាឡេស៊ី និងវៀតណាម ដាក់សំណើរួមទៅអង្គការសហប្រជាជាតិ ក្នុងក្របខ័ណ្ឌអនុសញ្ញាស្តីពីច្បាប់សមុទ្រ ដើម្បីធ្វើការទាមទារដែនអធិបតេយ្យភាពមកលើតំបន់ខ្ពង់រាបបាតសមុទ្រ ពង្រីកដោយភ្ជាប់ទៅនឹងជួរកោះតូចៗមួយចំនួន ដែលស្ថិតនៅភាគខាងត្បូងរបស់សមុទ្រចិនខាងត្បូង។ ទន្ទឹមនឹងនេះ វៀតណាមក៏បានដាក់សំណើដោយឡែក នូវការទាមទាររបស់ខ្លួនផងដែរ។

ចិនបានបដិសេធនូវសំណើពីរខាងលើនេះរបស់ម៉ាឡេស៊ី និងវៀតណាម ហើយនៅក្នុងខ្លឹម

សារកំណត់ទូត ដែលបានផ្ញើជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ភាគីចិនបានអះអាងនូវអធិបតេយ្យភាពពេញលេញដែលមិនអាចបដិសេធបានរបស់ចិន មកលើបណ្តាកោះក្នុងសមុទ្រចិន ខាងត្បូង និងតំបន់សមុទ្រនៅក្បែររួមទាំងអំណាចអធិបតេយ្យ និងអំណាចយុត្តាធិការមកលើតំបន់
ទឹកដែលមានការពាក់ព័ន្ធក៏ដូចជាតំបន់បាតសមុទ្រនិងក្នុងដីក្រោមបាតសមុទ្រផងដែរ។ កំណត់ទូត

របស់ចិន ក៏មានភ្ជាប់ទៅជាមួយនូវផ្ទាំងផែនទីចាស់ដោយមានស្នាមផ្លូវគូរដាច់ៗពីគ្នារត់តាមអក្សរ U ដែលផ្លូវអក្សរ U នេះ រត់ព័ទ្ធជុំវិញទាំងកោះធំ កោះតូច មានប្រមាណទាំងអស់២០០កោះដែលភាគីចិនចាត់ទុកជាដែនដីមិនអាចប្រកែកបានរបស់ខ្លួន។ រហូតមកដល់ថ្ងៃនេះ ចិននៅពុំទាន់បានឆ្លើយតបវិញចំពោះប្រទេសម៉ាឡេស៊ី វៀតណាម ហ្វីលីពីន តៃវ៉ាន់ និងប្រ៊ុយណេអំពីសំណើរបស់ប្រទេសទាំងនេះ ក្នុងការទាមទារដែនអធិបតេយ្យភាពរបស់ពួកគេ ក្នុងសមុទ្រចិនខាងត្បូងនៅឡើយ។




## ➢ ចិនប្រតិកម្មទៅនឹងអាមេរិក និងក្រុមហ៊ុនរុករករ៉ែ

ការវិលត្រឡប់មកវិញ របស់មហាអំណាចអាមេរិកនៅតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិកនេះ គឺនាវេទិកាតំបន់អាស៊ាន ឆ្នាំ២០១០ នៅហាណូយ លោកស្រី Hillary Clinton បានប្រកាសយ៉ាងឱឡារិកថា អាមេរិកមានអត្ថប្រយោជន៍គន្លឹះចាំបាច់នៅក្នុងតំបន់រួមទាំងក្នុងការ ដោះស្រាយបញ្ហា ដោយសន្តិវិធី ចំពោះរាល់ទំនាស់វិវាទទាំងឡាយអំពីដែនអធិបតេយ្យភាព លើប្រជុំកោះប៉ារ៉ាសែល

និងកោះស្ព្រាតលី ក្នុងតំបន់សមុទ្រចិនខាងត្បូងនេះទៀតផង។ លោកស្រី Hillary Clinton ក៏បានអះអាងបន្ថែមថា ការដោះស្រាយចំពោះការវិវាទទាំងនេះមានសារសំខាន់ណាស់ចំពោះសន្តិសុខក្នុងតំបន់ ហើយអាមេរិកមានអត្ថប្រយោជន៍ជាតិ ក្នុងការការពារសិទ្ធិសេរីភាពក្នុងការធ្វើចរាចរណ៍ការប្រាស្រ័យទាក់ទងដល់សិទ្ធិទាំងឡាយ ដែលមានការពាក់ព័ន្ធដល់សមុទ្រការគោរពច្បាប់អន្តរជាតិ ក្នុងតំបន់ដែលសំបូរទៅដោយសម្បត្តិធម្មជាតិទាំងនេះទៀតផង។

ទាក់ទងដល់ចំណុចគន្លឹះដ៏សេរីបទាំងនេះ រដ្ឋមន្ត្រីការបរទេសចិនបានប្រតិកម្មយ៉ាងខ្លាំង ដោយចាត់ទុកយោបល់លើកឡើងរបស់លោកស្រី Hillary Clinton គឺជាការវាយប្រហារមកលើ ប្រទេសចិន។ ហើយលោកក៏បានអះអាងបន្ថែមទៀតថា សមុទ្រចិនខាងត្បូងបច្ចុប្បន្ននៅតែជាតំបន់ មួយប្រកបទៅដោយសន្តិភាព ហើយអាស៊ានពុំមែនជាវេទិកាមួយដ៏សមស្រប ដើម្បីដោះស្រាយនូវ បញ្ហាវិវាទទាំងនេះទេ។ យោងតាមទស្សនរបស់រដ្ឋមន្ត្រីការបរទេសចិនគឺ មូលហេតុដែលនាំឱ្យចិន
និងពួកប្រទេសអាស៊ាន មានការខ្វែងគំនិតគ្នាអំពីដែនអធិបតេយ្យភាពលើសមុទ្រនេះ ដោយពួកគេជាអ្នកភូមិផងនឹងគ្នា ដែលមិនមែនមកអំពីរដ្ឋទាំងនេះជាសមាជិករបស់អាស៊ាននោះទេ។ លោករដ្ឋមន្ត្រីការបរទេសចិនបានធ្វើការបញ្ជាក់ថា នេះពុំមែនជាអធិករណ៍រវាងចិនជាមួយនឹងប្លុកអាស៊ានទេ ដូច្នេះហើយទើបចិនមានគំនិតផ្តួចផ្តើមឱ្យមានការជួបចរចារដោយឡែកជាមួយនឹងប្រទេសនីមួយៗដែលមានការពាក់ព័ន្ធ ក្នុងទំនាស់វិវាទលើប្រជុំកោះក្នុងសមុទ្រចិនខាងត្បូងនេះ។

ចំណុចក្តៅនឹងផ្ទុះឡើងទាក់ទងដល់ការទាមទារ និងការប្រឆាំងទៅនឹងការទាមទារទាំងនេះ មកពីដំបូងឡើយ វៀតណាមបានប្រកាសសិទ្ធិរុករករ៉ែក្នុងតំបន់មួយចំនួន ក្នុងសមុទ្រចិនខាងត្បូង នេះ ទៅឱ្យក្រុមហ៊ុន BP និង Exxon Mobil។ នៅឆ្នាំ២០០៨ រដ្ឋាភិបាលចិនបានធ្វើការព្រមានចំពោះ
ក្រុមហ៊ុនExxon Mobil ដោយបង្ខំឱ្យ Exxon Mobilនេះ ត្រូវតែលុបចោលនូវកិច្ចព្រមព្រៀងទាំងឡាយជាមួយវៀតណាមអំពីការរុករកប្រេងនេះ។ ក្នុងករណីដែលក្រុមហ៊ុន Exxon Mobilនេះ មានបំណងមិនចង់ឃើញនូវហានិភ័យ ឬគ្រោះថ្នាក់ណាមួយកើតឡើងដោយចៃដន្យមកលើចំពោះកិច្ចសន្យានាពេលអនាគតរវាងក្រុមហ៊ុននេះជាមួយនឹងចិននោះ។ យោងតាមការជូនព័តមានពីភាគីចិន គឺក្រុមហ៊ុនExxon Mobil នេះ បានធ្វើការរុករករ៉ែប្រេងលើតំបន់ដែលចិនចាត់ទុកថាជាបូរណភាពដែនដីមិនអាចប្រកែកបាន តាំងពីបុរមបុរាណយូរយារណាស់មកហើយរបស់ចិន ក្នុងសមុទ្រចិនខាងត្បូង។

ដោយវេនរបស់ប្រទេសខ្លួនជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ាន ទើបវៀតណាមដាក់បញ្ហាដ៏សេរីបស្តីពីសមុទ្រចិនខាងត្បូងនេះ ទៅក្នុងរបៀបវារៈដែលជាហេតុផលចម្បងនាំដល់ការធ្វើអន្តរាគមន៍របស់អាមេរិកក្នុងបញ្ហានេះ។ ព្រឹត្តិការណ៍នយោបាយនេះ បានក្លាយទៅជាផ្លូវរបត់មួយដ៏

សំខាន់ ក្នុងទំនាក់ទំនងរវាងអាមេរិក-ចិន អាមេរិក-អាស៊ាន និងចិន-អាមេរិក-អាស៊ានមក។ ប្រការ ដែលលេចធ្លោក្នុងបរិបទថ្មីនៃទំនាក់ទំនងអាមេរិក-ចិននេះ គឺជាការអះអាងថាទំនាក់ទំនង អាមេរិក-ចិន មិនត្រឹមតែជាកិច្ចសហប្រតិបត្តិការនោះទេ ថែមទាំងជារបត់មួយក្នុងការកំហិតនូវ អានុភាពរបស់
ចិនថែមទៀតផង ជាពិសេសគឺជាសកម្មភាពឆ្លើយតបទៅនឹងឥរិយាបថរបស់ចិន មកលើប ណ្ដា
ប្រទេសតូចតាចនៅក្នុងតំបន់ទៀតផង។

តែយ៉ាងណាក៏ដោយ ក៏ទំនាក់ទំនងអាមេរិកចិន នៅតែជាកត្តាចាំបាច់ដោយទំនាក់ទំនងនេះ មានចរិតផ្ដល់ប្រយោជន៍ជាបដិការឱ្យគ្នា ដែលពុំអាចធ្វើការបដិសេធបាននៅចំពោះមុខពេលនេះ។ នៅថ្ងៃទី១៦ ខែសីហា ២០១០ មន្ទីរបញ្ចកោណបានធ្វើរបាយការណ៍មួយ ដោយលើកឡើងអំពីចិន បានជំរុញយ៉ាងខ្លាំងនូវការវិនិយោគមកលើការកសាងអាវុធនុយក្លេអ៊ែរកាំជ្រួចរយៈចម្ងាយវែង និងខ្លី

នាវាមុជទឹក នាវាផ្ទុកយន្តហោះ និងមធ្យោបាយក្នុងធ្វើសង្គ្រាមទាំងឡាយ លើប្រព័ន្ធគមនាគមន៍ព័ត មាន។ លទ្ធភាព និងសមត្ថភាពរបស់កងទ័ពចិនអាចធ្វើការវាយប្រហារមកលើគោលដៅទាំងឡាយ ដែលស្ថិតឆ្ងាយពីតៃវ៉ាន់ រហូតដល់ផ្ទុំកោះ Guam របស់អាមេរិកទៀតផង។ ទាំងអស់នេះជាការចាប់ ផ្ដើមនៃការកកើតឡើងនូវទីលានប្រយុទ្ធមួយ ដែលមានការប្រកួតប្រយុទ្ធគ្នាយ៉ាងយូរអង្វែងជាច្រើន ទសវត្សរ៍រវាងអាមេរិក និងចិនដើម្បីដណ្ដើមឧត្តមភាពផុតលេខនៅតំបន់សមុទ្រប៉ាស៊ីហ្វិកសាជាថ្មី។

មើលទៅឃើញថា មានភាពតានតឹងមិនទុកចិត្តនឹងគ្នា ក៏ប៉ុន្តែមានកត្តាមួយដែលមានចរិត ស្ថេរភាពក្នុងទំនាក់ទំនងអាមេរិក-ចិន នោះ គឺប្រទេសទាំងពីរនេះ មានភាពចាំបាច់ត្រូវការកិច្ចសហ ប្រតិបត្តិការក្នុងក្របខ័ណ្ឌនៃការប្រកួតប្រជែង ដែលផ្ដល់ផលប្រយោជន៍ឱ្យឱ្យគ្នាទៅវិញទៅមកជា មួយគ្នា។ ចំពោះមុខ ចិនត្រូវការបច្ចេកទេសឧស្សាហកម្មខ្ពស់ ការបណ្ដាក់ទុន និងទីផ្សាររបស់អាមេ រិក ចំពោះអាមេរិកវិញ ក៏ត្រូវការទីផ្សាររបស់ចិន ក៏ដូចជាមានការព្រមព្រៀងគ្នាមួយដោយមិនចំហរ ឬយ៉ាងហោចណាស់ ក៏ត្រូវមានការគាំទ្រពីប្រទេសនេះ ក្នុងការចូលរួមដោះស្រាយនូវបញ្ហាធំៗទាំង ឡាយលើពិភពលោកពីផងដែរ។ ដូច្នេះអត្ថប្រយោជន៍មានចរិតបដិការនេះអាចក្លាយជាចលករមួយ ដ៏ខ្លាំងក្នុងការធ្វើឱ្យប្រទេសទាំងពីរនេះពុំមានការប្រឈមមុខដាក់គ្នាជាកម្លាំងបាយទោះបីក្នុងកាលៈ ទេសៈណាមួយក៏ដោយនាពេលខាងមុខនេះ។

ភាគីចិន ចាំបាច់ត្រូវតែធ្វើការថ្លឹងថ្លែងប្រុងប្រយ័ត្ន ក្នុងការពិនិត្យមើលឱ្យគ្រប់ជ្រុងជ្រោយ ថា តើការទាមទាររបស់ខ្លួនក្នុងការចរចាដោយឡែកជាមួយប្រទេសអាស៊ាននីមួយៗនេះ អាចនឹង ធ្វើឱ្យ ប្រទេសដែលមានការពាក់ព័ន្ធដោយផ្ទាល់មកលើសមុទ្រចិនខាងត្បូងនោះអាចមាន សកម្មភាពងាក
មករកនឹងអាមេរិកដែរឬទេ? មួយក្នុងចំណោមគោលដៅយូរអង្វែងរបស់ចិនគឺធ្វើសមាហរណកម្មឱ្យ

បានជាមួយប្លុកអាស៊ានលើផ្នែកសេដ្ឋកិច្ច ក៏ដូចជាជាមួយជប៉ុន និងកូរ៉េខាងត្បូង។ គោលដៅទាំងឡាយរបស់ចិននឹងទទួលបរាជ័យ បើចិនមានអំពើជាយថាហេតុ ក្នុងការុញក្រុមប្រទេសអាស៊ានឱ្យងាកចេញពីចិនទៅរកអាមេរិកនោះ។ ហើយជាពិសេសគឺ ចាប់តាំងពីអាមេរិកប្រកាសនូវនយោបាយ

របស់ខ្លួន ក្នុងការផ្តល់កិច្ចគាំទ្រដល់សំណូមពរស្របច្បាប់របស់ពួកប្រទេសតូច នៅក្នុងតំបន់ជុំវិញការទាមទារសិទ្ធិ និងអធិបតេយ្យភាពលើតំបន់សមុទ្រចិនខាងត្បូងនោះ។

ការវិលមកវិញទាំងការងារការទូត ទាំងសកម្មភាពយោធារបស់អាមេរិក ក្នុងយុទ្ធសាស្ត្រវិលត្រឡប់មកវិញ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិករបស់រដ្ឋការលោកBarack Obama ជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍ បានក្លាយជាចំណែកមួយដ៏សំខាន់ ក្នុងរបៀបវារៈនយោបាយរបស់សេតវិមាន។ អាចមាន មូលហេតុចម្បងធំពីរ ដែលបានបង្ខំសហរដ្ឋអាមេរិក វិលមកអោបអាស៊ានវិញ គឺបញ្ហាសន្តិសុខ និង

សេដ្ឋកិច្ច។ វាក៏អាចជារឿងមួយដ៏ចម្លែក និងកម្រ ដែលមន្ត្រីការទូតជាន់ខ្ពស់របស់សហរដ្ឋអាមេរិកធ្វើដំណើរទៅមកវៀតណាម ក្នុងគ្រប់បេសកកម្មគួរឱ្យកត់សម្គាល់ និងត្រូវបានមជ្ឈដ្ឋានអ្នកវិភាគសភាពការណ៍អន្តរជាតិដាក់ឈ្មោះឱ្យការទៅមកឡើងចុះនេះថា“ពីសត្រូវក្លាយជាសម្ព័ន្ធមិត្ត”។

ចំពោះលោកស្រី Hillary Clinton វិញ ហាក់បីដូចជាមិនលាក់លៀមគំនិតរបស់ខ្លួន ក្នុងការ

ពេញចិត្តពេញថ្លើមនូវទស្សនទាននយោបាយមួយស្តីពីសហគមន៍អាស៊ី-ប៉ាស៊ីហ្វិកដែលជាគំនិតផ្តួចផ្តើមរបស់លោក Kevin Rudd អតីតនាយករដ្ឋមន្ត្រីអូស្ត្រាលីបានលើកឡើងកន្លងមក។

ព្រោះការផ្សារភ្ជាប់ជាគន្លឹះរបស់អាស៊ាន គឺជាដំណាក់កាលចុងក្រោយក្នុងយុទ្ធសាស្ត្រផ្សារភ្ជាប់គ្នាជាខ្សែរយៈសង្វាក់ទៅនឹងតំបន់អាស៊ីបូព៌ា ជាទីកន្លែងដែលអាមេរិក មានកម្លាំងសម្ព័ន្ធមិត្តជាប្រពៃណីស្រាប់រួមមាន ជប៉ុន កូរ៉េខាងត្បូង និងជាមួយអូស្ត្រាលី ណូវែលហ្សេឡង់ ដែលស្ថិតនៅខាងកើតប៉ាស៊ីហ្វិក និងនៅអាស៊ីខាងត្បូង រួមមានឥណ្ឌាមួយទៀតជាប្រទេសឈានមុខក្នុងការស្តារទំនាក់ទំនងឡើងវិញជាមួយនឹងសហរដ្ឋអាមេរិកផងដែរ។

ចំពោះអាស៊ីវិញជាតំបន់ដែលត្រូវអាមេរិកផ្តោតអារម្មណ៍យកចិត្តទុកដាក់មុនគេបង្អស់ដោយមកពីបញ្ហាសេដ្ឋកិច្ច និងសន្តិសុខហើយកម្មវត្ថុដែលលេខធ្លោមុនគេគឺចាប់ផ្តើមពីបញ្ហាសន្តិសុខថាមពល រហូតដល់សេរីភាពរបស់នាវាចរណ៍លើសមុទ្រនេះឯង។

តែយ៉ាងណាក៏ដោយ តំបន់អាស៊ីអាគ្នេយ៍ធ្លាប់មានឈ្មោះថា ជាតំបន់មានអរិយធម៌ទន់ភ្លន់មាននយោបាយ និងសិល្បៈការទូតសុភាព ដូច្នេះ អាមេរិកចាំបាច់ត្រូវមានជំហានដើរយឺតៗតែរឹងមាំ។ ការខ្វះចរិតឯកភាពក្នុងប្លុកអាស៊ាន គឺជាប្រពៃណី ហើយក៏ជាប្រការមួយដ៏ពិបាករបស់អាមេរិក

ក្នុងការតាក់តែងឡើងនូវគោលនយោបាយរួមមួយដែលមានភាពជ្រាលជ្រៅ។ ដោយឃើញខ្លឹមសារមានពាក្យពេចន៍ពិរោះមែនតែការអនុវត្តខុសពីនេះទាំងអស់មិនដូចការគិត។ ដូច្នេះដើម្បីរក្សាឱ្យបានការឯកភាពខ្ពស់ អាមេរិកចាំបាច់ត្រូវមានឥរិយាបថគោរពដោយស្មោះ ដល់ភាពអំណត់ទាំងឡាយរបស់បណ្តារដ្ឋាភិបាលអាស៊ាន ដោយត្រូវមើលឃើញការពិតរបស់ភាពអត់ធ្មត់មួយដ៏តថភាពយ៉ាងដូច្នេះ។

បន្ទាប់ពីមានការខិតខំប្រឹងប្រែងនាពេលថ្មីៗនេះ ក្រុមប្រទេសអាស៊ានហាក់បីមានភាពជឿជាក់ និងសេចក្តីក្លាហាននៅចំពោះមុខការអុងអាត់របស់ចិន ដែលកំពុងតែមានសកម្មភាពវាតទីលើសមុទ្រចិនខាងត្បូងនោះ។ តែវិធានការមួយដ៏ល្អជាងគេបំផុតនោះ គឺអាមេរិក៏មិនត្រូវធ្វើ ឬលើកទឹកចិត្តឱ្យមានប្រទេសអាស៊ីណាមួយ ក្នុងចំណោមសមាគមអាស៊ាននេះ ឱ្យងើបឈរឡើងដើរតាមអាមេរិកដើម្បីតទល់ប្រឆាំងទៅនឹងចិនឡើយដែរ។ ព្រោះយ៉ាងហោចណាស់អាមេរិកក៏ត្រូវដឹងថាអា នុភាពរបស់ចិន ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែរីកធំធាត់ ហើយផ្តើមចេញពីទំនាក់ទំនងជាប្រវត្តិសាស្ត្រ រវាងចិនជាមួយតំបន់នេះ ជាពិសេសគឺកម្លាំងអាណិកជនចិន ដែលមានស្រាប់នៅគ្រប់ទិសទី ទូទាំង
អាស៊ី និងលើពិភពលោក ដូច្នេះមិនងាយបំបាក់ចិនទេ បើសហរដ្ឋអាមេរិកគ្មានយុទ្ធសាស្ត្រឆ្លាត។

ទាំងអាមេរិក ទាំងចិន គួរមានការមូលមតិគ្នាមួយ ក្នុងទំនាក់ទំនងដោយធ្វើយ៉ាងណា ដើម្បីការពារដល់បណ្តាអត្ថប្រយោជន៍របស់ក្រុមប្រទេសអាស៊ានដែលអ្នកទាំងពីរនេះគួរមានរបៀបលេងលើក្តារអុកអន្តរជាតិ ដែលធ្វើយ៉ាងណា "មិនឱ្យក្តៅពេក តែក៏មិនត្រូវត្រជាក់ពេក" ផងដែរ។

<u>ផ្នែកទី២</u>

## អាស៊ាន និងបញ្ហាសមុទ្រចិនខាងត្បូង បន្ទាប់ពីកិច្ចប្រជុំ រដ្ឋមន្ត្រីការពារជាតិ អាស៊ាន+៨ នៅវៀតណាម៖

➢ វៀតណាមព្យាយាមដោះខ្លួនចេញពីចិន

បើពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ ទោះបីជាស្ថិតក្នុងកាលៈទេសៈណាមួយ និងក្នុងទស្សន នយោបាយណាក៏ដោយ ក៏មានចំណុចមួយមិនអាចបដិសេធបានជាការពិតនោះ គឺក្នុងរយៈ ពេល មួយឆ្នាំនេះ បន្ទាប់ពីជំនួសថៃទទួលតួនាទីជាប្រធានអាស៊ាននមក គឺវៀតណាមបានខិតខំ ប្រឹងប្រែង អស់ពីកម្លាំងកាយចិត្តក្តាប់ឱ្យបានឱកាស ដើម្បីរំកិលខ្លួនឱ្យចេញផុតពីតារាវិថីឥទ្ធិពល របស់ចិន រួច

ឆ្ពោះទៅលំហាពិភពលោក ហើយនេះក៏ពុំមែនជាភាពចៃដន្យណាមួយ គឺសុទ្ធតែមានបំណងទាំងនេះ ដែលក្នុងរយៈពេលមិនដល់កន្លះឆ្នាំផង ទាំងមន្ត្រីជាន់ខ្ពស់ការទូត និងយោធាអាមេរិក បានបណ្តាក់ គ្នាធ្វើការទៅមកចុះឡើងវៀតណាម ប្រកបដោយឆន្ទានុសិទ្ធិ ហើយសូម្បីតែហេតុការណ៍តូច តាច ដូចទឹកជំនន់កើតឡើងក្នុងតំបន់ភូមិភាគកណ្តាលរបស់វៀតណាមក៏ពួកនេះទទួលបាននូវ អំណោយ

លួងចិត្តពីលោកស្រី Hillary Clinton ផងដែរ។

អត្តិភាព និងកិត្យានុភាពរបស់វៀតណាម ត្រូវបានលើកកម្ពស់ពិតប្រាកដ បន្ទាប់ពីកិច្ចប្រជុំ កំពូលវេទិកាតំបន់អាស៊ាន-១៧ មក ហើយសំឡេងនិយាយរបស់វៀតណាម ក៏ចាប់មានទម្ងន់អំពី សមុទ្រចិនខាងត្បូង ព្រមទាំងត្រូវបានមតិសាធារណៈពិភពលោកយកចិត្តទុកដាក់ និងតាមដានជា ទីបំផុត រួមទាំងអាស៊ាន អាមេរិក និងចិនផង។ ទន្ទឹមនឹងហេតុការណ៍ទាំងនេះ ការសម្រេចវិលមក វិញរបស់អាមេរិកនៅតំបន់អាស៊ីអាគ្នេយ៍របស់រដ្ឋការObamaដោយសហរដ្ឋអាមេរិកធ្វើការជ្រើសរើស យកវៀតណាមជាដៃគូមួយគួរឱ្យទុកចិត្តបំផុត ក្នុងការអភិវឌ្ឍចំពោះសេចក្តីសម្រេចនេះ។ ពេលនេះ តួនាទីយុទ្ធសាស្ត្ររបស់វៀតណាមបានលេចធ្លោឡើង ដូចជាផ្ទាំងគំនូររូបភាពនយោបាយថ្មីមួយនៅ អាស៊ីប៉ាស៊ីហ្វិក ក្នុងបរិបទថ្មីបន្ទាប់ពីកិច្ចប្រជុំវេទិកាតំបន់អាស៊ាន និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិ អាស៊ានបូក៨ មក។

ក្នុងស្ថានភាពដ៏ពិសេស និងជាប្រវត្តិសាស្ត្រនេះ កិច្ចប្រជុំកំពូលរដ្ឋមន្ត្រីការពារជាតិអាស៊ាន បូក៨ បានធ្វើឱ្យរដ្ឋធានីហាណូយពេលនោះ ស្រាប់តែក្លាយទៅជាកន្លែងប្រមូលផ្តុំនូវអំណាចសេដ្ឋ កិច្ច និងអានុភាពយោធាដ៏រឹងមាំនិងខ្លាំងក្លាបំផុតលើពិភពលោក ដែលការប្រជុំទាំងនេះ រួមមានការ ជួបប្រាស្រ័យទាក់ទងគ្នាជាទ្វេភាគីផង ជាត្រីភាគីផង និងពហុភាគីផងដែលមានគ្រប់សមាភាពទាំង មហាអំណាចក្នុងតំបន់ និងមហាអំណាចពិភពលោក ដូចជា ជប៉ុន ចិន អាមេរិក រុស្ស៊ី អូស្ត្រាលី និង ឥណ្ឌាជាដើម ។ ល ។

ក៏ប៉ុន្តែ មានព្រឹត្តិការណ៍មួយគួរឱ្យផ្តោតការយកចិត្តទុកដាក់នោះផងដែរគឺ នៅមុនកិច្ចប្រជុំ រដ្ឋមន្ត្រីការពារជាតិអាស៊ានបូក៨នេះ គឺមានធ្វើពិធីបើកព្រឹត្តការណ៍ ស្រាប់តែឯកអគ្គរដ្ឋទូតចិននៅ ប្រទេសហ្វីលីពីន ប្រកាសយ៉ាងឱឡារិកដោយអះអាងថា ចិន និងបណ្តាប្រទេសអាស៊ាន បាននិង កំពុងចាប់ផ្តើមធ្វើការពិភាក្សាអំពីក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង សម្រាប់សមុទ្រចិនខាងត្បូង

សំដៅធ្វើការរារាំងទប់ស្កាត់នូវរាល់ទំនាស់វិវាទអំពីដែនអធិបតេយ្យភាព ដោយធ្វើយ៉ាងណាកុំឱ្យអធិ

ករណ៍នេះរីករាលដាល ហើយផ្ទុះជាការប៉ះទង្គិចគ្នាជាកម្លាំងអាវុធលើសមុទ្រចិនខាងត្បូង ក្នុងពេលអនាគតនោះ។

ការប្រកាសនេះ ហាក់បីដូចជាមានបំណងចង់បំពុលស្ថានការណ៍ ធ្វើឱ្យសភាពការណ៍មានភាពស្រពិចស្រពិលមិនច្បាស់លាស់ ក្នុងកិច្ចប្រជុំនេះដោយចិននៅតែដាច់ខាតបដិសេធមិនទទួលយកការធ្វើអន្តរាគមន៍ពីប្រទេសខាងក្រៅតំបន់ ហើយអាមេរិកត្រូវចាត់ទុកថាជាជនដែលស្ថិតនៅខាងក្រៅតំបន់គ្មានភារកិច្ចណាមួយគ្មានសិទ្ធិជ្រៀតជ្រែក ក៏ដូចជាគ្មានមុខចូលរួមក្នុងដំណើរការប្រជុំទាំងនេះឡើយ។

### ➢ ការប្រឈមរបស់វៀតណាមជាមួយនឹងអាមេរិក និងចិន

យោងតាមការសិក្សាអង្កេតរបស់អ្នកវិភាគនៅក្នុងតំបន់ គឺសភាពការណ៍ក្នុងសមុទ្រចិនខាងត្បូងនៅតែមានអស្ថេរភាពដដែល បើទោះបីជាមានកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក៨ រួចមក ក៏ដោយ។ ហើយជាធម្មតាស្ថានភាពរបស់វៀតណាមចំពោះអាស៊ាន ក៏ដូចជាចំពោះថ្នាក់ដឹកនាំទាំង
អស់របស់ចិន ក៏វៀតណាមនៅតែមានភាពប្រឈមជាប្រឆាំដ៏ច្រើនឥតគណនា ជាពិសេសក្នុងស្ថានភាពដែលវៀតណាម កំពុងរំកិលខ្លួនសម្របសម្រួលទៅជាដៃគូយុទ្ធសាស្ត្រជាមួយអាមេរិក ក្នុងការរួមដៃទប់ទល់ទៅនឹងអានុភាពរបស់ចិន ទាំងក្នុងតំបន់ ទាំងនៅក្នុងតំបន់សមុទ្រចិនខាងត្បូងនេះ។ ក្នុងទស្សនវិស័យនៃបរិបទថ្មីមួយនេះ វៀតណាមត្រូវប្រឈមមុខនឹងបញ្ហាដ៏លំបាកស្មុគ្រស្មាញពីរទាំងចំពោះមុខទាំងយូរអង្វែងរួមមាន៖

១- ចំពោះអាមេរិក យោងតាមទស្សនៈរបស់លោកHurt Campbell ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិក សហរដ្ឋអាមេរិកមានគោលបំណងដ៏សាមញ្ញបំផុត គឺចង់រក្សាតំបន់សមុទ្រចិនខាងត្បូងនេះ ឱ្យនៅតែជាតំបន់ដែលនាវាចរណ៍អន្តរជាតិអាចធ្វើដំណើរដោយសេរី និងមានសុវត្ថិភាព។ អាមេរិក
មានអត្ថប្រយោជន៍ជាតិមួយដ៏ធំនៅក្នុងតំបន់សមុទ្រនេះ ក្នុងករណីអាមេរិកការពារបាននូវសិទ្ធិសេរី ភាពក្នុងការធ្វើនាវាចរណ៍ ព្រមទាំងរក្សាតំបន់សមុទ្រនេះឱ្យនៅតែជាតំបន់សមុទ្រសេរី។ ដូច្នេះការ
ចូលរួមរបស់អាមេរិកនៅក្នុងតំបន់សមុទ្រចិនខាងត្បូងនេះ គឺមានចរិតយុត្តិធម៌ និងសត្យានុម័តបំផុត ដោយពុំមែនជាការមើលមិនឃើញទៅនឹងអ្វីទាំងអស់។

២- ចំពោះចិនវិញ ដោយមានសម្ពាធពីសហគមន៍អន្តរជាតិ ជាពិសេសគឺអាមេរិក គឺចិនអាច បោះបង់ចោលនូវទស្សទានហៅថាអគ្រាការប្រាក់ស្នូល តែចិនដាច់ខាតមិនបោះបង់ចោលនូវ ផ្លូវ គំនូសអក្សរប ដែលចិនបានគូសកំណត់នៅលើតំបន់សមុទ្រចិនខាងត្បូងរួចហើយនោះទេ។ មុន និង ក្រោយ ជាដាច់ខាតចិនប្តេជ្ញាការពារអក្សរបនៅលើតំបន់សមុទ្រចិនខាងត្បូងនេះ ជាសក្ខីកម្ម មួយ
ដែលមិនអាចប្រកែកបាន អំពីសកម្មភាពនៃការវាតទីរបស់ចិន ដែលផ្លូវអក្សរប នេះបានគ្របដណ្តប់ ៨០% នៃវិសាលភាពលើសមុទ្រចិនខាងត្បូងអស់ទៅហើយនោះ។

ជាធម្មតា គ្មានប្រទេសណាមួយក្នុងសហគមន៍អាស៊ាន អាចទទួលយកបាននូវអំពើដ៏ហួស ហេតុរបស់ចិនយ៉ាងដូច្នេះទេ។ ទើបស្ថានភាពសន្តិសុខនៅក្នុងតំបន់សមុទ្រចិនខាងត្បូង នៅតែ មាន អស្ថេរភាព និងទទួលការគំរាមកំហែងជាប្រចាំ។

តើសមាគមអាស៊ានត្រូវធ្វើយ៉ាងដូចម្តេច? ហើយវៀតណាម គួរតែមានប្រតិកម្មយ៉ាងណា

ចំពោះការព្យាបាលរបស់ចិនយ៉ាងនេះ? តែយើងទាំងអស់គ្នាត្រូវតែដឹងថា ផ្លូវអក្សរបនៅលើតំបន់ សមុទ្រចិនខាងត្បូងនេះ ពុំមានជាប់ទាក់ទិនពាក់ព័ន្ធទៅនឹងអាមេរិកទេព្រោះឱ្យតែនាវាអាមេរិកអាច ធ្វើដំណើរទៅមកដោយសេរី ហើយត្រូវបានធានាសុវត្ថិភាព សន្តិសុខនៅលើសមុទ្រចិនខាងត្បូង គឺ ជាបំណងមួយដ៏គ្រប់គ្រាន់សម្រាប់អាមេរិក។ ទន្ទឹមនឹងនេះ អាមេរិកមានសិទ្ធិចាត់ទុកតំបន់សមុទ្រ ចិនខាងត្បូង ដូចដែនសមុទ្រអន្តរជាតិដែលប្រទេសខ្លួនមានសិទ្ធិសេរីភាពពេញលេញ ក្នុងការធ្វើ នាវាចរណ៍ហោះហើរដោយគ្មានឧបសគ្គណាមួយ ដូច្នេះចិនមានរឿងអ្វីដែលត្រូវធ្វើការបដិសេធនឹង សំណូមពររបស់អាមេរិកចង់បាននោះទេ ដើម្បីទាញអាមេរិកចេញពីវៀតណាម។ ហើយដំណើរការ ចរចាររវាងប្រទេសចិននិងអាមេរិកអំពីសមុទ្រចិនខាងត្បូងដល់ដំណាក់កាលនេះនឹងអាចត្រូវចប់ជា ស្ថាពរបន្ទាប់ពីចិនចេះបំពេញចិត្តតាមសំណូមពររបស់អាមេរិកមក។

ព្រឹត្តិការណ៍ខាងលើនេះ ក៏មានសម្មតិកម្មមួយដែលការទស្សន៍ទាយនេះ មានលទ្ធភាព ក្លាយ ទៅជាការពិតច្រើនោះ គឺប្រទេសជាសមាជិកអាស៊ានទាំងអស់ ជាពិសេស គឺវៀតណាមគួរតែ ដើរឱ្យ
ឆ្ងាយចៀសឱ្យឆ្ងាយពីមហាអំណាចអាមេរិកនេះព្រោះក្នុងការទំនាក់ទំនងសហប្រតិបត្តិជាមួយអាមេ រិក អ្នកទាំងឡាយចងចាំបានថា បាវចនារបស់អ្នកដឹកនាំអាមេរិកគឺតម្កល់ឧត្តមប្រយោជន៍ជាតិរបស់ អាមេរិកខ្ពស់បំផុត គឺជាគោលការណ៍អាទិភាព មុនអាមេរិកសម្រេចគិតដល់ប្រយោជន៍របស់សម្ព័ន្ធ មិត្តជាក្រោយ។

## ផ្នែកទី៣

# អាស៊ានចាំបាច់ត្រូវធ្វើអ្វីទៅចំពោះមុខដុំសាច់ជាប់ក ដែលមិនអាចវះកាត់ យកចេញបាន នាក់ទងដល់បញ្ហាសមុទ្រចិនខាងត្បូងនោះ៖

### ➢ ចិនព្យាយាមខ្ទប់អាស៊ានកុំឱ្យចេញជាដុំដែក

សូម្បីតែប្រទេសអាស៊ានទាំងអស់រួបរួមសាមគ្គីនឹងគ្នាជាប្លុកមួយក៏ដោយ ក៏ចិននៅតែមានឧត្តមភាពខ្លាំងក្លាជាងពួកប្រទេសអាស៊ានទាំងអស់បូកជាមួយគ្នា។ ទន្ទឹមនេះ ចិនក៏មានសិល្បៈការទូត និងយុទ្ធសីល៍ក្នុងការធ្វើឱ្យមានការអាប់អរួរ ធ្លាក់ចុះនូវការគាំទ្រចំពោះពួកប្រទេសអាស៊ាន ជាមួយនឹងពួកប្រទេសអាស៊ីក្នុងទំនាក់ទំនងនិងមានទំនាស់ជាមួយគ្នាឯង។

មីយ៉ាន់ម៉ា ជាប្រទេសដាច់ដោយឡែកដែលស្ថិតនៅក្រៅបរិវេណសមុទ្រចិនខាងត្បូងហើយ មីយ៉ាន់ម៉ាក៏នឹងពុំមានការខាតបង់ប្រយោជន៍ណាមួយ ក្នុងករណីដែលសមុទ្រចិនខាងត្បូងក្លាយទៅ

ជាផ្ទះបាយរបស់ចិននោះ ដូច្នេះចិនមានលទ្ធភាពច្រើនក្នុងការអូសទាញមីយ៉ាន់ម៉ា ឱ្យឈរឆ្ងាយពីជំហររួមរបស់ពួកប្រទេសអាស៊ាន។

ចំពោះកម្ពុជា និងថៃវិញ គឺជាប្រទេសដែលស្ថិតនៅក្នុងតំបន់ឈូងសមុទ្រថៃ ដូច្នេះ ប្រទេសពីរនេះ ក៏ពុំមានហេតុផលណាមួយពាក់ព័ន្ធទៅនឹងផលប្រយោជន៍ នៅក្នុងតំបន់សមុទ្រចិនខាងត្បូង ឡើយដែរ។ ហើយក៏ជាប្រទេសដែលស្ថិតនៅក្នុងមុខសញ្ញា ដែលត្រូវចិនបញ្ចុះបញ្ចូលឱ្យគាំទ្រចិន ផងដែរ។ មុននេះ កម្ពុជាក៏ធ្លាប់បានប្រកាសយ៉ាងចំហរប្រឆាំងទៅនឹងអន្តរជាតូបនីយកម្មសមុទ្រចិន
ខាងត្បូងរួចហើយ។ ដោយឡែកសិង្ហបុរី ជាប្រទេសដែលពុំមានទំនាស់វិវាទណាមួយអំពីដែនដីលើតំបន់សមុទ្រជាមួយចិន តែសិង្ហបុរីមានជំហរនយោបាយគាំទ្រអាស៊ាន និង អាមេរិក។

ដូច្នេះ ចិននឹងខិតខំអូសទាញបញ្ចុះបញ្ចូលពួកប្រទេសទាំងនេះ ដើម្បីឱ្យសភាពការណ៍កាន់តែស្ពឹកស្រពន់ទៅ ដើម្បីកុំឱ្យអាស៊ានមានការមូលមតិគ្នាបាន។ ព្រោះបើអាចធ្វើឱ្យមានទម្ងន់ ដើម្បីតទល់ជាមួយចិនបាន ក្នុងករណីពួកប្រទេសទាំងនេះ មានការមូលមតិគ្នា មានការឯកភាពគ្នាខ្ពស់ ទាំងក្នុងអាស៊ានផង ទាំងផ្ទៃក្នុងរបស់ប្រទេសខ្លួនផង។

ចំពោះពួកប្រទេសអាស៊ីអាគ្នេយ៍វិញ ចិននឹងស្វែងរកនូវគ្រប់មធ្យោបាយ ដើម្បីបំបែកបំបាក់បែងចែកពួកប្រទេសទាំងនេះ ឱ្យដើរដាច់ដោយឡែកពីគ្នាតាមផលប្រយោជន៍រៀងៗខ្លួន ដើម្បីងាយ ស្រួលចាត់ចែងម្ចាស់ការ និងគ្រប់គ្រងលើសភាពការណ៍នៅក្នុងតំបន់។

- **ចិន៖ ទន់ជាមួយប្រទេសខ្លាំង ចង់ចិត្តប្រទេសខ្សោយ**

ឥណ្ឌូនេស៊ី ជាប្រទេសដែលពុំមានទំនាស់អំពីកោះជាមួយចិន តែមានវិវាទអំពីដែនសមុទ្រដោយតំបន់សមុទ្រមានការជាន់លើគ្នានៅត្រង់ម្តុំខាងក្រោមបំផុតរបស់តំបន់សមុទ្រ ក្នុងដែនទីអក្សរ U ហើយដោយឥណ្ឌូនេស៊ីជាប្រទេសមួយ ក្នុងចំណោមប្រទេសអាស៊ីអាគ្នេយ៍ដែលមានទំនាស់ និង មានអានុភាពយោធាខ្លាំងក្លាជាងគេបំផុតនោះ ទើបចិនមានសិល្បៈការទូតអាចផ្អាក និងបន្ថយការ ប្រឈមជាមួយឥណ្ឌូនេស៊ីសិន ដោយមានភាពទន់ភ្លន់ទៅរកឥណ្ឌូនេស៊ី ដើម្បីមានឱកាសទប់ទល់
ជាមួយពួកប្រទេសផ្សេងទៀត។

ឯម៉ាឡេស៊ី និងប្រ៊ុយណេវិញ មានទំនាស់លើបញ្ហាកោះមួយចំនួន តែមិនជាធំដុំជាមួយនឹងចិន ហើយតំបន់សមុទ្រដែលប្រទេសម៉ាឡេស៊ី និងប្រ៊ុយណេមានវិវាទជាមួយនឹងចិននោះគឺជាតំបន់

សមុទ្រដែលស្ថិតនៅចុងក្នុងតំបន់សមុទ្រក្នុងផែនទីអក្សរប ផងដែរ។ ម៉ាឡេស៊ី និង ប្រ៊ុយណេ ក៏ជាប្រទេសអាស៊ីអាគ្នេយ៍មួយ ដែលមានទម្ងន់ក្នុងការទំនាស់នេះ ហើយជាប្រទេសដែលមានកងទ័ព ជើងទឹកនិងទ័ពអាកាសដ៏ខ្លាំងក្លាត្រូវបានបំពាក់ទៅដោយសម្ភារៈទ័ពដ៏ទំនើបដូច្នេះចិនអាចផ្អាកការ
ប្រឈមជាមួយប្រទេសទាំងពីរនេះមួយរយៈសិន ដើម្បីមានភាពទន់ភ្លន់ទុកដោះស្រាយបញ្ហានៅពេលក្រោយ។

រក្សាទុកកម្លាំងប្រឈមជាមួយ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ប្រ៊ុយណេ ទាំងនេះទៅម្ខាង ដើម្បីចិន ប្រមូលធនធាន និងវិធានការទាំងអស់មកគិតគូរគូរទប់ទល់ និងដោះស្រាយបញ្ហាជាមួយ ហ្វីលីពីន និងវៀតណាម។ ហ្វីលីពីន ជាប្រទេសឈរលំដាប់លេខពីរ ដែលមានបញ្ហាកោះជាមួយចិន ចំណែក វៀតណាមវិញជាប្រទេសលំដាប់លេខមួយ ដែលមានទំនាស់វិវាទអធិបតេយ្យភាព ទាំងលើសមុទ្រ
ទាំងលើកោះដ៏ច្រើន និងមានភាពតានតឹងបំផុតជាមួយនឹងចិន។

- ចិនៈ មិនប្រយុទ្ធជាមួយសត្រូវច្រើនក្នុងពេលតែមួយ

ចំពោះមុខ គឺចិនប្រមូលផ្តុំកម្លាំងទាំងអស់តម្រង់មុខព្រួញលើវៀតណាមនិងហ្វីលីពីនតែមួយគត់ អំពីបញ្ហាប្រជុំកោះស្ព្រាតលី ក្នុងសមុទ្រចិនខាងត្បូង។

ហើយទោះបីជា សន្ធិសញ្ញាការពារជាតិរវាងហ្វីលីពីន និងអាមេរិកពុំបាននិយាយដល់ប្រជុំកោះស្ព្រាតលី ក៏ដោយ ប៉ុន្តែ ហ្វីលីពីនក៏មានសន្ធិសញ្ញាការពារជាតិជាមួយនឹងប្រទេសដ៏ទៃលើពិភពលោក ដូច្នេះរបងការពាររបស់វៀតណាមមានចន្លោះប្រហោងច្រើនកន្លែងជាងហ្វីលីពីន។

មានសញ្ញាបញ្ជាក់ឱ្យឃើញថា បច្ចុប្បន្នចិនប្រមូលផ្តុំកម្លាំង វាយមកលើវៀតណាមខ្លាំងជាង គេ ដោយបរិវេណតំបន់ហាមឃាត់មិនឱ្យនេសាទ ត្រូវអាជ្ញាធរចិនដាក់បម្រាមយ៉ាងតានតឹងបំផុតចំ
ពោះវៀតណាម ដែលក្នុងពេលនោះ ចិនហាក់បីដូចជាមានភាពធូរលុង និងមិនជាតឹងរឹុងជាមួយនឹង បណ្តាប្រទេសដទៃទៀត ក្នុងការនេសាទនៅក្នុងតំបន់សមុទ្រទាំងនេះឡើយ។

ក្រៅពីនេះ ចិនក៏ធ្លាប់គាបសង្កត់មកលើក្រុមហ៊ុន BP និង Exxon Mobil ឱ្យដកគម្រោងរុករកប្រេងរបស់ខ្លួនចេញពីវៀតណាម តែចិនពុំដែលធ្វើយ៉ាងដូច្នេះជាមួយប្រទេសផ្សេងទៀត នៅក្នុងតំបន់នេះឡើយ។ ទន្ទឹមនឹងនេះ ចិនក៏ធ្លាប់បានចុះហត្ថលេខាដោយឯកតោភាគី ក្នុងការសិក្សាស្រាវជ្រាវរុករកប្រេង នៅក្នុងតំបន់ក្បែរព្រំដែនសមុទ្ររបស់វៀតណាម តែពុំដែលមានករណីនេះចំពោះប្រទេសដទៃឡើយ។

- សម្ព័ន្ធមិត្តតែពេលមានប្រយោជន៍

ជាការពិតណាស់ ហ្វីលីពីនមាននយោបាយជិតស្និទ្ធ ស្មាកៀកស្មាជាមួយនឹងវៀតណាមទប់

ជាមួយចិនអំពីវិវាទនៅលើសមុទ្រចិនខាងត្បូងនេះ។ តែក្រោយមកភាពជិតស្និទ្ធនេះ បានអន់ថយទៅវិញ ដោយយហ្វីលីពីនធ្លាប់បានចុះហត្ថលេខាក្នុងការរុករកប្រេងជាមួយចិន ក្នុងតំបន់ប្រជុំកោះស្ព្រាតលីនាឆ្នាំ២០០៤ ហើយហ្វីលីពីនក៏ធ្លាប់បដិសេធមិនទទួលស្គាល់នូវរបាយការណ៍ទាំងឡាយស្តី
ពីខ្ពង់រាបបាតសមុទ្ររបស់វៀតណាមនិងរបស់ម៉ាឡេស៊ីនាឆ្នាំ២០០៩ទៀតផង។ សកម្មភាពខាងលើ
នេះបញ្ជាក់ឱ្យឃើញថា ហ្វីលីពីនពុំមែនជាសម្ព័ន្ធមិត្តគួរឱ្យទុកចិត្តរបស់វៀតណាម និងមានការយល់

ផ្សេងក្នុងបញ្ហារបស់សមុទ្រចិនខាងត្បូងនេះ។

ចិនក៏មានការខុសឆ្គងមួយចំនួនដែរ ប៉ុន្តែការលេងល្បែងប៉ាហ៊ីនៅលើក្តារអុកអន្តរជាតិលើតំបន់សមុទ្រចិនខាងត្បូង ក៏ទើបនឹងមានការចាប់ផ្តើមដែរ ដូច្នេះចិននៅមានពេលវេលាច្រើន រួមទាំងឱកាសសម្រាប់អនុវត្តគោលនយោបាយទន់ និងអំណាចរឹង ដើម្បីខ្លួនមានលទ្ធភាព ក្នុងការជម្នះមកលើសភាពការណ៍ទាំងឡាយនាពេលខាងមុខ។ ចិននឹងបង្កើនឱ្យអស់សមត្ថភាព ជាមួយនឹងវិធានការសំដៅធ្វើឱ្យប្រទេសទាំងនេះលែងមានឆន្ទៈទៅមុខទៀត រួមទាំងការយកចិត្តទុកដាក់របស់អាមេរិកមកលើសភាពការណ៍ទាំងនេះ ក៏មានការធ្លាក់ចុះផងដែរ។

ទិសដៅពហុភាគីក្នុងការចរចា និងអន្តរជាតូបនីយកម្មតំបន់សមុទ្រចិនខាងត្បូង គឺជាមាគ៌ាមួយដ៏ត្រឹមត្រូវ និងមានភាពចាំបាច់ជាទីបំផុត សម្រាប់បញ្ហាសមុទ្រចិនខាងត្បូង។ ប៉ុន្តែ ដើម្បីធ្វើឱ្យសម្រេចនូវទិសដៅទាំងនេះពួកប្រទេសតូចដែលមានការពាក់ព័ន្ធក្នុងជម្លោះវិវាទត្រូវធ្វើដំណើរយ៉ាងឆ្ងាយ ដោយត្រូវឆ្លងកាត់ដំណាក់កាលដ៏លំបាកយ៉ាងច្រើន ទើបសង្ឃឹមថាអាចឆ្ពោះទៅរកការជោគជ័យបានជាស្ថាពរ ក្នុងករណីដែលពួកខ្លួនមានសាមគ្គីភាពផ្ទៃក្នុងអាស៊ានជាធ្លុងមួយសិន។

## ផ្នែកទី៤

## អាស៊ាន និងចិន ឆ្ពោះទៅរកក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងរួមមួយ អំពីសមុទ្រចិនខាងត្បូងបានដែរ ឬអត់៖

- យកក្រមប្រតិបត្តិរួមមួយមកទប់សភាពការណ៍ ដែលកំពុងវិវត្តន៍ទៅ

  រកគ្រោះថ្នាក់

ដោយមានសេចក្តីបារម្ភ ចំពោះសភាពការណ៍ដ៏តានតឹង នៅក្នុងតំបន់សមុទ្រចិនខាងត្បូង ដែលជាហេតុអាចនាំឱ្យមានការប្រទូស្តរាយដោយអាវុធនោះទើបឥណ្ឌូនេស៊ីនិងចិនសូមឱ្យប្រញាប់ប្រញាល់ព្រមព្រៀងឱ្យបាននូវក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងរួមមួយឱ្យបានប្រញាប់។ ក្រៅពីនេះ រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី ក៏ធ្វើការព្រមានអំពីលទ្ធភាពនៃសភាពការណ៍មួយ ដែលអាចវិវត្តន៍កើតមានឡើងទៅជាភាពស្មុគ្រស្មាញបំផុត ហើយអាចធ្វើឱ្យសភាពការណ៍នេះ កើតហួសពី

ក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ខ្លួនទៀតផង។

ទន្ទឹមនេះ លោកក៏បានអះអាងបន្ថែមថា ចាប់តាំងពីអាស៊ាន និងចិនឯកភាពរួមគ្នាកសាងសេចក្តីប្រកាសលើក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងមួយ រហូតមកដល់ថ្ងៃនេះបាន៩ឆ្នាំកន្លង

ផុតទៅហើយ។ ដូច្នេះ ល្មមដល់ពេលហើយដែលត្រូវសន្ធនាចាំបាច់ឈានទៅដល់ការព្រមព្រៀងជា
លទ្ធផលជាក់ស្តែងណាមួយ ហើយបើនៅតែបណ្តោយទុកឱ្យសភាពការណ៍អសកម្មនេះ បន្តអូស បន្លាយទៅមុខទៀត ច្បាស់ជានឹងនាំមកនូវផលវិបាកមួយដ៏ស្មុគស្មាញ ដែលមិនចាំបាច់ត្រូវតែមាន
ទាល់តែសោះ។

ទំនាស់វិវាទទាំងឡាយនៅក្នុងសមុទ្រចិនខាងត្បូងធ្វើឱ្យមានសភាពការណ៍តានតឹងរវាងចិន និងបណ្តាប្រទេសភូមិផង ជាពិសេសគឺវៀតណាម និងហ្វីលីពីន។ ក្រៅពីនេះ រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីក៏បានរំលឹកផងដែរ ដល់ករណីវិវាទលើតំបន់សមុទ្រខាងកើត ការប៉ះទង្គិចគ្នារវាងចិនជាមួយនឹងជប៉ុន និងហេតុការណ៍ប្រទូស្តរាយទាំងឡាយរវាងកូរ៉េខាងត្បូង និងកូរ៉េខាងជើងនាខែវិច្ឆិកាឆ្នាំ២០១០នេះ។

ក្នុងឋានៈជាប្រធានអាស៊ានឆ្នាំ២០១១េនះ រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីបាននិយាយថា ត្រូវ
តែជំរុញឱ្យមានការជួបចរចាររវាងអាស៊ាន-ចិននៅលើផ្លូវថ្មីមួយនិងជាបន្ទាន់ដោយមិនរង់ចាំទៀតទេ ព្រោះពិភពលោក និងតំបន់ទាំងមូលបាននិងកំពុងរុលទៅមុខហើយ។

- ឧបសគ្គរបស់ក្រមប្រតិបត្តិ

ក្នុងការចូលរួមកិច្ចប្រជុំនៅ Lombob នេះដែរ ក៏មានលោក Surin Pitsawan អគ្គលេខាធិការអាស៊ាន ដោយលោកបាននិយាយថា ចិនកំពុងតែស្វែងរកនូវដំណោះស្រាយមួយ ចំពោះអាស៊ាន វិញក៏កំពុងតែស្វែងរកនូវគោលជំហររួមមួយ។ ហើយបើយោងតាមការបញ្ជាក់របស់ AFP គឺអាស៊ាន មានបំណងចង់ដោះស្រាយការវិវាទនេះ ទៅតាមដំណោះស្រាយពហុភាគី ក្នុងពេលដែលចិនមាន បំណងចង់ដោះស្រាយតាមរូបភាពជាទ្វេភាគី។

មានមូលហេតុចម្បងមួយ ដែលជាឧបសគ្គរាំងមិនឱ្យក្រមប្រតិបត្តិរួមមួយនេះទៅមុខបាន ដោយចិនមានឥរិយាបថស្ទាក់ស្ទើរមិនចង់ប្រឈមមុខជាមួយប្លុកអាស៊ានទាំងមូល។

នៅក្នុងទិដ្ឋភាពមួយ ដែលប្រធានាធិបតីចិនលោក ហ៊ូ ជីនតាវ បានទៅបំពេញទស្សនកិច្ចផ្លូវ

រដ្ឋនៅអាមេរិកនោះ ពួកអ្នកវិភាគសភាពការណ៍អន្តរជាតិបានរំពឹងរង់ចាំថា ទីក្រុងវ៉ាស៊ីងតោននឹង សម្តែងឥរិយាបថនយោបាយផ្តល់ការគាំទ្រដល់អាស៊ាន ប្រៀបដូចជាកំពែងប្រឈមមុខមួយតទល់
ទៅនឹងអានុភាពយោធាដ៏ខ្លាំងក្លារបស់ចិននៅក្នុងតំបន់នេះ។

## ផ្នែកទី៩

# ការសាកល្បងកម្រិត"ក្តៅ" របស់សមុទ្រចិនខាងត្បូង នៅពេលដែលឥណ្ឌូនេស៊ី ធ្វើជាប្រធានអាស៊ាន ២០១១៖

- ឥណ្ឌូនេស៊ីចង់បង្ហាញពិភពលោកថាខ្លួនជារដ្ឋឥស្លាមមួយដ៏សុក្រឹត និង ប្រកាន់យកលទ្ធិប្រជាធិបតេយ្យដ៏ល្អជាងគេបំផុតលើពិភពលោក

ក្នុងប៉ុន្មានខែខាងមុខនេះ បើនរណាយកចិត្តទុកដាក់មកលើតំបន់សមុទ្រចិនខាងត្បូងក៏សុទ្ធតែបានរំពឹងមើលមកប្រទេសឥណ្ឌូនេស៊ី ដែលជាប្រទេសបន្តមុខតំណែងជាប្រធានអាស៊ាន បន្ទាប់ពីវៀតណាម។ មូលបទចម្បង ដែលអ្នកសង្កេតការណ៍តាមដាននោះ គឺការរង់ចាំមើលកំដៅដែលហាណូយ បានដុតឱ្យសមុទ្រចិនខាងត្បូងឱ្យក្តៅរួចទៅហើយ ដូច្នេះមិនដឹងថា ចាកាតាមានបំណងបន្តដុតកំដៅនេះ ឱ្យកាន់តែក្តៅឡើងថែមទៀត ឬក៏អត់ទាក់ទងដល់អធិបតេយ្យបូរណភាពលើតំបន់ សមុទ្រចិនខាងត្បូងទៀតឬអត់?

ភាពប្រឈមលើកនេះ គឺជាការប្តូរសេចក្តីប្រកាសលើក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងឆ្នាំ២០០២ អំពីសមុទ្រចិនខាងត្បូងឱ្យទៅជាក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង ដែលមានចរិត មានតម្លៃចាប់បង្ខំទៅដោយច្បាប់ហើយក្លាយទៅជាក្រមប្រតិបត្តិមួយសំដៅឆ្ពោះទៅរកការព្យាបាល ដោយយុត្តិធម៌ និងការរក្សាសន្តិភាព ស្ថេរភាព នៅក្នុងតំបន់ដោយរង់ចាំរហូតដល់ការវិវាទអំពីអធិប
តេយ្យភាពលើដែនសមុទ្រ រវាងភាគីអ្នកទាមទារសិទ្ធិទាំងឡាយ ដែលអាចដោះស្រាយបានដោយរលូននោះ។ក្នុងសម័យកាលនោះ សេចក្តីប្រកាសលើក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងត្រូវបានចាត់ទុកថា"ផ្លូវបត់"ជាសញ្ញាវិជ្ជមានដ៏កម្របំផុតពីប្រទេស១០អាស៊ីអាគ្នេយ៍ដែលយូរមកហើយតែងតែរងការសើចចំអកថា ជាក្រុមប្រទេសជួបគ្នាគ្មានខ្លឹមសារនយោបាយអ្វីទាំងអស់ ថែមទាំងបើកផ្លូវឆ្ពោះទៅរកសករាជថ្មីមួយ ក្នុងទំនាក់ទំនងជាមួយចិន។ ប៉ុន្តែ ជាអកុសល ស្រាប់តែក្នុងប៉ុន្មានឆ្នាំនេះ សេចក្តីសង្ឃឹមបានប្រែក្លាយទៅជាអាប់អួរតានតឹងឡើង រវាងចិនជាមួយនឹងបណ្តាប្រទេសមានការពាក់ព័ន្ធក្នុងទំនាស់សមុទ្រចិនខាងត្បូងកាន់តែផុសផុលឡើង រួមមានទាំងការរត់ប្រណាំងសព្វាវុធនៅក្នុងតំបន់ក៏កើនឡើង ការប៉ះទង្គិចគ្នារវាងកប៉ាល់នេសាទសង្គ្រាមជោហាសាស្ត្រ និងសកម្មភាពយ៉ាងអាថ៌កំបាំងរបស់ចិន ក្នុងចលនារុញបញ្ហាដ៏រសើបរបស់តំបន់សមុទ្រចិនខាងត្បូង ឱ្យចេញផុតពីរបៀបវារៈ ក្នុងកិច្ចប្រជុំទាំងឡាយរបស់អាស៊ាននាពេលអនាគតទៀតផង។

ដូចជាពុំមានអ្វីដែលចំលែកឡើយ ដោយបន្ទាប់ពីមានផ្លូវរបត់២០០២ មក ក៏នៅបន្សល់ទុកមកនូវសំណួរជាច្រើនដែលអត់ទាន់ដោះ។ ដោយមកអំពីមានការសង្ស័យអូសបន្លាយឆ្ងាយរវាងពួក អ្នកទាមទារសិទ្ធិ ក្នុងការប្រកាសអះអាងអធិបតេយ្យ ដែលពុំទាន់គិតដល់ភាពខុសគ្នាអំពីប្រព័ន្ធ នយោបាយ និងច្បាប់ទម្លាប់ទាំងឡាយទៀតផង ព្រមទាំងសួរថាតើសេចក្ដីប្រកាសលើក្រមប្រតិបត្តិ

ស្ដីពីសមុទ្រចិនខាងត្បូងនេះ ជាឯកសារមានទំងន់ពិតប្រាកដដែរ ឬអត់? រួមទាំងការស្រេកឃ្លាននូវឥទ្ធិពលរៀងៗខ្លួន បានក្លាយជាអសារបង់តាមពេលវេលា ដោយចរិតរឹងរូសអភិរក្សរបស់អាស៊ាន ហើយជាពិសេសមកពីប្រទេសអាស៊ាននីមួយៗ មានការពិនិត្យពិច័យនិងថ្លឹងថ្លែងក្នុងការផ្ដល់សារៈសំខាន់ក្នុងទំនាក់ទំនងរបស់ប្រទេសខ្លួនជាមួយនឹងចិនផង ទើបនៅពេលដែលលើកឡើងអំពីបច្ចុប្បន្នភាពនៃជម្លោះសមុទ្រចិនខាងត្បូងមក ពួកអ្នកទាមទារសិទ្ធិខ្លះ ដូចជាមានការបារម្ភអំពីភាព

តានតឹងរហូតដល់យល់ថា ប្រទេសរបស់ខ្លួននឹងត្រូវគួចចូលទៅក្នុងព្យុះសង្ឃរារបស់វិបត្តិសង្គ្រាមមួយមិនស្រួលដូចការគិតឡើយ។

អាកប្បកិរិយាមួយដែលត្រូវបានចាត់ទុ ុកថាជាជំហានសកម្មនាពេលថ្មីៗ គឺការមិនលាក់បាំង

នូវកលល្បិចការទូត ដែលភាគីចិននៅតែអះអាងដាច់អហង្ការថា ទោះជាមានប្រកាសអធិបតេយ្យភាព មកលើតំបន់សមុទ្រណាក៏ដោយ ក៏ចុងក្រោយត្រូវតែដោះស្រាយដោយទ្វេភាគីជាមួយនឹងក្រុង

ប៉េកាំងដដែល ទោះបីជាចិន មានជំហានវិជ្ជមានឆ្ពោះទៅកសាងក្រមប្រតិបត្តិមួយ ដោយសុក្រឹតក៏ដោយ។ ប្រការនេះឆ្លុះបញ្ចាំងឱ្យឃើញនូវសេចក្ដីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីចិន នៅចំពោះមុខប្រទេសជាដៃគូនៅក្នុងតំបន់ នាខែតុលា ឆ្នាំ២០១០ ថាចិនមានបំណងចង់ជួយបង្កើតឡើងនូវតំបន់

សមុទ្រមួយសន្តិភាព និងសហប្រតិបត្តិការ។

មានបំរាមមួយថា មិនអនុញ្ញាតឱ្យសមុទ្រចិនខាងត្បូង ក្លាយទៅជាទីលានបន្សល់ទុកមកនូវ

ស្លាកស្នាមដោយ“ការទូតទូកកំភ្លើង” បណ្ដាអានុភាពអំណាចនយោបាយណាមួយឱ្យមាននៅទីនេះឡើយ។

ទំនាក់ទំនងឥណ្ឌូនេស៊ី-ចិនជាទំនាក់ទំនងមួយដែលមានចរិតរសើបបំផុតនៅក្នុងតំបន់ដែលចំណុចរសើបនេះទាក់ទងដល់ប្រវត្តិជូរចត់ពោរពេញទៅដោយឈាម ទឹកភ្នែក ការធ្វើបាប ភាពមានមន្ទិលសង្ស័យដែលនិគមជនជាតិចិនរស់នៅឥណ្ឌូនេស៊ីទទួលរងគ្រោះនោះពិតមែនតែបានឆ្លងផុតទៅជាង៤ទសវត្សរ៍មកហើយក៏ដោយ។

តែក្នុងប៉ុន្មានឆ្នាំនេះ គេសម្គាល់ឃើញអានិកជនចិនត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅនៅចំពោះមុខសង្គមឥណ្ឌូនេស៊ីដែលមានការបើកទូលាយជាងមុនហើយការខិតខំរាក់ទាក់នេះបានជួយជំរុញឱ្យទំនាក់ទំនងឥណ្ឌូនេស៊ី-ចិន កាន់តែមានភាពល្អប្រសើរ។ ទំនាក់ទំនងរកស៊ីពាណិជ្ជកម្ម និង ការបណ្តាក់ទុនរបស់ចិននៅឥណ្ឌូនេស៊ីបានពង្រីក និងលើកកម្ពស់។ ទន្ទឹមនឹងនេះ នាវាចម្បាំងបី គ្រឿងរបស់ចិន បន្ទាប់ពីបញ្ចប់បេសកកម្មក្នុងយុទ្ធនាការយាមល្បាត ប្រយុទ្ធប្រឆាំងជាមួយនឹងពួក ចោរសមុទ្រស៊ូម៉ាលី ពេលត្រឡប់ទៅប្រទេសចិនវិញ បានចូលឈប់សំចតទស្សនាកោះមួយចំនួន របស់ឥណ្ឌូនេស៊ី។ ទន្ទឹមនឹងហេតុការណ៍ទាំងនេះ ក៏មានកត្តាផ្សេងទៀតបានលេខឡើងនៅចាកាតា

ផងដែរថា ឥណ្ឌូនេស៊ីកំពុងតែសកម្មក្នុងស្វែងរកវិធីដុសខាត់ខ្លួន ដោយធ្វើឱ្យប្រទេសខ្លួនមានកម្រិតអន្តរជាតិ ដោយតាំងខ្លួនជាប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យមួយដ៏មហិមានៅអាស៊ី និងធ្វើខ្លួនជារដ្ឋឥស្លាមមួយដ៏សុក្រឹតគំរូ និងដ៏ធំបំផុតលើពិភពលោកផង។

- ឥណ្ឌូនេស៊ីរៀបចំផែនការសម្រាប់អាស៊ាន ព្រោះមិនចង់ឃើញអាស៊ានមាន អនាគតមិនច្បាស់លាស់

ទន្ទឹមនេះ ឥណ្ឌូនេស៊ីបានខិតខំប្រឹងប្រែង ដើម្បីនាំអាស៊ានឆ្ពោះទៅរកអនាគតមួយមានភាពប្រាកដ និងច្បាស់លាស់ជាងនេះ ដោយឆ្លងតាមរយៈការធានានូវការព្រមព្រៀងមួយ ដែលមានចរិតមូលដ្ឋាន ដូចជាក្រមប្រតិបត្តិសម្រាប់តំបន់សមុទ្រចិនខាងត្បូង ដែលជាចំណែកមួយរបស់ការខិតខំប្រឹងប្រែងនេះ ក្នុងពេលឥណ្ឌូនេស៊ីបំពេញមុខងារជាប្រធានអាស៊ាន២០១១។

ក្រៅពីដុសខាត់ខ្លួនឱ្យកាន់តែភ្លឺថែមទៀតឥណ្ឌូនេស៊ីក៏មានសំណូមពរស្នើសុំអាស៊ានគួរចាប់

ផ្តើមដើរតួនាទីនៅលើឆាកអន្តរជាតិ ដោយសកម្មចូលរួមដោះស្រាយបញ្ហាពិភពលោក បញ្ហាបម្រែបម្រួលអាកាសធាតុ ដោះស្រាយការប្រទូស្តរាយដោយអាវុធ និងសន្តិសុខ ដើម្បីក្រោយឆ្នាំ២០១៥ សមាគមអាស៊ាននេះ អាចមានគ្រឹះទូទៅមួយដូចអាស៊ីខាងកើត ក្នុងតំបន់ប៉ាស៊ីហ្វិកនេះ។

ឥណ្ឌូនេស៊ី ក៏បានលើកឡើងនូវវិស័យបីជាសរសេរទ្រូង ដែលរហូតមកដល់ថ្ងៃនេះ នៅពុំ ទាន់បាននាំមកនូវផលប្រយោជន៍ណាមួយ ដូចជាធ្វើយ៉ាងណាដោះស្រាយបញ្ហាសមុទ្រក្នុងតំបន់។ ការយកចិត្តទុកដាក់នេះដោយបញ្ហាសមុទ្រនៅតែជាបញ្ហាចាំបាច់ត្រូវពិភាក្សាព្រោះមានការទាក់ទង

ទៅដល់ការនេសាទត្រី និងអំពីនាវារបស់កងទ័ពជើងទឹករបស់អាស៊ានផង ពីពួកប្រទេសអាស៊ីបូព៌ាផង។ល។ ឥណ្ឌូនេស៊ី មានបំណងចង់ពង្រីកនូវវេទិកាមួយអំពីសមុទ្រដោយពិភាក្សានិងរកវិធានការ

ទាំងឡាយ ក្នុងការដោះស្រាយលើហេតុការណ៍ទាំងនោះដោយភ្ជាប់បទបញ្ញត្តិមានអនុភាពគតិយុត្ត ចាប់បង្ខំដោយច្បាប់ និងនីតិវិធីនៃសកម្មភាពក្នុងស្តង់ដារបស់វាដែលឥណ្ឌូនេស៊ីមិនចង់ឱ្យមានហេតុការណ៍ណាមួយកើតឡើងចេញផុតពីក្របខ័ណ្ឌហួសពីការគ្រប់គ្រងឡើយ។

ពួកអ្នកវិភាគនយោបាយធ្វើការបំរាមថា ការវិវាទព្រំដែនរវាងពួកប្រទេសសមាជិកអាស៊ាន ជាមួយនឹងប្រទេសដែលមិនមែនជាសមាជិកអាស៊ាន ជាពិសេសគឺ ចិននៅលើសមុទ្រចិនខាងត្បូង គឺជាការសាកល្បងចំពោះតួនាទីដឹកនាំរបស់ឥណ្ឌូនេស៊ីនាពេលនេះហើយ។ ទាក់ទងដល់ចំណុចរសើបនេះ រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីបានអះអាងថា ក្នុងឆ្នាំនេះ ឥណ្ឌូនេស៊ីជាប្រធានអាស៊ាន គឺកិច្ចសន្ទនារវាងអាស៊ាន និងចិន អំពីសមុទ្រចិនខាងត្បូងនឹងត្រូវបន្តដោយរំពឹងថា គ្រប់ភាគីទាំងអស់នឹងមានជំហានរីកចម្រើនក្នុងក្រមប្រតិបត្តិ ដើម្បីរួមគ្នាដោះស្រាយលើបញ្ហាអធិបតេយ្យភាព
ចំពោះតំបន់នេះដោយយុត្តិធម៌។

<u>ផ្នែកទី៦</u>

## ចំណុចរសើបនាំឪឡាយដៅមុនពេលកិច្ចប្រជុំកំពូលអាស៊ាន

លើកទី២០នៅកម្ពុជា៖

- កម្ពុជាទទួលរងគំនាប តែនូវតែរឹងមាំ

ថ្ងៃទី៣០ ខែមីនា លោកប្រធានាធិបតី ហ៊ូ ជីនតាវ បំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា ដំណើរទស្សនកិច្ចនេះ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដោយដំណើរទស្សនកិច្ចនេះបានប្រព្រឹត្តទៅនៅមុនពេលកិច្ចប្រជុំអាស៊ានលើកទី២០។ មជ្ឈដ្ឋានសារព័តមានអន្តរជាតិបានចាត់ទុក ដំណើរទស្សនកិច្ចក្នុងដំណាក់កាលនេះជាអំណាចនៃការគាបសង្កត់មួយមកលើកម្ពុជា ដើម្បីឱ្យកម្ពុជារក្សាអាសនៈជាប្រធានអាស៊ាន ដោយមិននាំយកបញ្ហាសមុទ្រចិនខាងត្បូង ទៅលើតុរបស់កិច្ចប្រជុំដើម្បីិវិភាគនោះ

ទេ ប៉ុន្តែនៅមុនពេលចាកចេញទៅដើម្បីចូលរួមកិច្ចប្រជុំកំពូលប្រធានាធិបតីហ្វីលីពីនAquino III នៅតែអះអាងថា នៅតែយកបញ្ហាសមុទ្រចិនខាងត្បូងនេះ ទៅដាក់លើតុប្រជុំរបស់ថ្នាក់ដឹកនាំអាស៊ានទាំងអស់។

វៀតណាមបានជំរុញឱ្យមានគោលជំហររួមមួយ នៅមុនពេលចរចាជាមួយនឹងចិន៖ ក្រុមការងារស្តីអំពីបញ្ហា “ក្រមប្រតិបត្តិ (Code of Conduct)” បានប្រជុំគ្នាលើកទី៤ សំដៅជំរុញការតាក់តែងក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង ហើយតំណាងពីប្រទេសអាស៊ាននីមួយៗ បានពិនិត្យ និង អនុម័តមកលើរបាយការណ៍របស់កិច្ចប្រជុំលើកទី៣ ដែលបានប្រព្រឹត្តទៅនៅហាណូយពីមុននោះ។

ក្នុងកិច្ចប្រជុំលើកទី៣ នៅហាណូយ គឺភាគីវៀតណាមបានលើកឡើងជាសំណូមពរដល់ប្រទេសអាស៊ានទាំងអស់ ចាំបាច់ត្រូវឯកភាពលើទស្សនរួម ជាពិសេស គឺកត្តាដ៏សារវន្តរបស់ក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង ដើម្បីមានជំហរមួយនៅមុនពេលត្រូវចរចាជាមួយនឹងចិន។

អំពីប្រធានក្រុមរបស់បណ្តាប្រទេស ក្នុងក្រុមការងារស្តីអំពីក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង នៅមុនពេលមានកិច្ចប្រជុំលើកទី៤ គឺរវាងសមាជិកអាស៊ាននូវមានមតិខុសផ្សេងគ្នា អំពីបញ្ហាសមុទ្រចិនខាងត្បូង។ ដោយប្រទេសកម្ពុជា មីយ៉ានម៉ា ឡាវ និងថៃបានចាត់ទុកនេះជាបញ្ហាទ្វេភាគីរវាងចិនជាមួយនឹងប្រទេសអាស៊ានផ្សេងទៀត។ ក្នុងពេលនោះ ហ្វីលីពីនមានបំណងទទូចចង់ដោះស្រាយបញ្ហាវិវាទសមុទ្រចិនខាងត្បូងនោះទៅតាមយន្តការពហុភាគី។ ពិសេសជាងនេះ គឺហ្វីលីពីនចង់ឱ្យសម្ព័ន្ធមិត្តរបស់គេ គឺអាមេរិកធ្វើអន្តរាគមន៍ចូលមកដំណើរការនេះ ក៏ដូចជាផ្តល់ការការពារ

ហ្វីលីពីននៅពេលដែលមានហេតុការណ៍អស្ថេរភាពណាមួយកើតឡើងនោះ។

បញ្ហាមីយ៉ាន់ម៉ា ក៏ជាកម្មវត្ថុមួយដ៏ក្តៅនាកិច្ចប្រជុំកំពូលលើកនេះ ជាពិេសសគឺក្នុងស្ថានភាព មួយ ដែលមីយ៉ាន់ម៉ាកំពុងដំណើរការបោះឆ្នោតបំពេញបន្ថែមអាសនៈក្នុងរដ្ឋសភា។

ប្រទេសទាំង អស់ រួមទាំងអាស៊ានមានសេចក្តីរំពឹងយ៉ាងជ្រាលជ្រៅ ដោយចង់ឃើញមានការវិវត្តន៍ប្រែប្រួលជា
វិជ្ជមានក្នុងជីវភាពនយោបាយរបស់មីយ៉ាន់ម៉ា។ ហើយប្រការដែលមីយ៉ាន់ម៉ាបានម្ចាស់ការអញ្ជើញពួកប្រទេសអាស៊ាន ដៃគូចរចា និងអង្គការអន្តរជាតិ ឱ្យចូលរួមសង្កេតការណ៍បោះឆ្នោត នាថ្ងៃទី១ ខែមេសា នេះជាជំហានមួយដ៏វិជ្ជមានដែលត្រូវបានវាយតម្លៃខ្ពស់។

ឥទ្ធិពលរបស់ចិនចំពោះកម្ពុជា នឹងត្រូវបានសាកល្បងនាកិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជា ៖ ពិតមែនវត្តមានរបស់ចិននៅកម្ពុជាមានជាការពិត ដោយឆ្លងតាមរយៈគម្រោងយ៉ាងច្រើនលើគ្រប់

វិស័យ ក៏ប៉ុន្តែឥទ្ធិពលពិតប្រាកដរបស់ចិនមកលើកម្ពុជា និងត្រូវបានសាកល្បងនាកិច្ចប្រជុំកំពូលអាស៊ានលើកទី២០នេះនៅភ្នំពេញ ឆ្លងតាមរយៈដំណើរទស្សនកិច្ចផ្លូវរដ្ឋ របស់លោកប្រធានាធិបតីចិន ហ៊ូ ជីនតាវ មកកម្ពុជាលើកនេះ។

យោងតាមពួកអ្នកសង្កេតការណ៍នយោបាយក្នុងតំបន់បានវិភាគថា ដំណើរទស្សនកិច្ចរបស់លោក ហ៊ូជីនតាវ មកកម្ពុជា បានធ្វើឱ្យមនភាពសង្ស័យកាន់តែខ្លាំង ជុំវិញអំណាចរបស់ចិនក្នុងការគាបសង្កត់បង្ខំឱ្យកម្ពុជាលុបចោលកិច្ចពិភាក្សា អំពីអធិបតេយ្យភាពលើសមុទ្រចិនខាងត្បូង ចេញពី
របៀបវារៈរបស់កិច្ចប្រជុំកំពូលអាស៊ាន ដែលមុននេះទោះបីកម្ពុជាបានប្រកាសថា នឹងពុំមានសំណុំ
រឿងសមុទ្រចិនខាងត្បូងក្នុងរបៀបវារៈការងាររបស់អាស៊ានឡើយនោះ។

ភាពតានតឹងលើសមុទ្រចិនខាងត្បូង ធ្លាប់ជាកម្មវត្ថុដ៏ស្រួចស្រាវនាកិច្ចប្រជុំវេទិកាតំបន់អាស៊ាន បន្ទាប់ពីមានឧបទ្ទវហេតុកើតឡើងជាហូរហែដោយមានការគំរាមកំហែងភាពរំខានអុកឡុកពីនាវាយាមល្បាតរបស់ចិន មកលើនាវានេសាទ នាវារុករកប្រេងរបស់វៀតណាម និងហ្វីលីពីននៅលើសមុទ្រចិនខាងត្បូងនោះ។ ហើយមិនត្រឹមប៉ុណ្ណោះ បញ្ហាសមុទ្រចិនខាងត្បូងធ្លាប់ធ្វើឱ្យអាស៊ានទាំង១០ មានការបែកបាក់មិនឯកច្ឆន្ទនឹងគ្នារហូតមកដល់ពេលបច្ចុប្បន្ននេះ ក្នុងស្ថានភាពមួយដែល
អាមេរិកបានធ្វើការផ្លាស់ប្តូរយុទ្ធសាស្ត្រវិលមកកាន់តំបន់អាស៊ីវិញ។

- ## ហ្វីលីពីនចាប់ផ្តើមត្រៀមពលមុខព្រោះខ្វះអ្នកសហការជាសមាជិកអាស៊ានមួយ ចំនួនមិនបាន

មន្ត្រីជាន់ខ្ពស់របស់ហ្វីលីពីនម្នាក់ បាននិយាយជាមួយ Reuters ថា ហ្វីលីពីនគ្មានរំពឹងដោយសង្ឃឹមថា និងមានការគាំទ្រណាមួយពីកម្ពុជា ឡាវ មីយ៉ាន់ម៉ា នឹងថៃ លើបញ្ហានេះឡើយ។ ដោយ

រហូតមកដល់ពេលនេះប្រទេស៤ខាងលើនេះតែងតែគេចវេសបញ្ហាវិវាទអធិបតេយ្យភាពលើសមុទ្រចិនខាងត្បូងជានិច្ច។ ក្រៅពីនេះ មន្ត្រីជាន់ខ្ពស់ហ្វីលីពីនរូបនេះ ក៏បានអះអាងបន្ថែមថា ពួកគេមានអារម្មណ៍អស់សង្ឃឹមនៅចំពោះមុខការខិតខំប្រឹងប្រែងរបស់ចិន ក្នុងការរារាំងទប់ស្កាត់នូវរាល់ការពិភាក្សាបញ្ហានេះក្នុងផ្ទៃក្នុងរបស់អាស៊ាន នៅពេលដែលចិនបានលើកឡើងជាឯកតោភាគីនូវផ្ទាំងផែនទីអក្សរ “U” ដោយចិនបានអះអាងអធិបតេយ្យភាពជិត៨០ភាគរយ នៃវិសាលភាពលើតំបន់ សមុទ្រចិនខាងត្បូង ហើយក្រៅពីនេះ ចិនបានបដិសេធដាច់អហង្ការលើសំណើរបស់ហ្វីលីពីនទាក់ ទងដល់ការស្នើជួបពិភាក្សា ដើម្បីកំណត់នូវតំបន់ដែលមានទំនាស់ និងតំបន់ដែលពុំមានទំនាស់ ដើម្បីអាចរួមឆ្ពោះទៅការរួមគ្នាធ្វើសេចក្តីថ្លែងការណ៍រួមផងដែរ។

តែទោះបីជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ក៏ហ្វីលីពីននៅតែជំនះលើកបញ្ហាសមុទ្រចិនខាងត្បូងក្នុងកិច្ចប្រជុំអាស៊ានលើកទី២០នេះ បើទោះបីជាកម្ពុជាពុំបានដាក់ក្នុងរបៀបវារៈរបស់
កិច្ចប្រជុំកំពូលក៏ដោយ។

លោកCarl Baher នាយកមជ្ឈមណ្ឌលសិក្សាយុទ្ធសាស្ត្រអន្តរជាតិនៅហាវ៉ៃ បានធ្វើសេចក្តីសន្និដ្ឋានថានេះ គឺជាការពិសោធន៍មួយដ៏ពិតប្រាកដចំពោះសហគមន៍អាស៊ាន។ សមាគមអាស៊ានពិតជាពុំប្រសិទ្ធភាព ព្រោះមកពីអាស៊ានធ្វើសកម្មភាពលើមូលដ្ឋានការមូលមតិរួមគ្នា ហើយដោយសារពុំមានការឯកច្ឆន្ទរួមយ៉ាងដូច្នេះ ទើបពួកគេនឹងពិបាកសម្រេចបាននូវការឯកភាពណាមួយលើបញ្ហាវិវាទអធិបតេយ្យភាពណាស់។

នាយករដ្ឋមន្ត្រីកម្ពុជាធ្លាប់បានប្រកាសជាច្រើនដងថាជំនួយរបស់ចិនពុំមានលក្ខខណ្ឌ តែបើយោតាមពួកអ្នកជំនាញការនយោបាយក្នុងតំបន់បានសន្និដ្ឋានថា ក្នុងប៉ុន្មានឆ្នាំនេះ កម្ពុជាបានធ្លាក់យ៉ាងឆាប់រហ័សក្នុងគារាវិថីឥទ្ធិពលសេដ្ឋកិច្ចរបស់ចិន ហើយកម្ពុជាមិនរវល់ដល់វិវាទអធិបតេយ្យភាពលើសមុទ្រចិនខាងត្បូង។ ដូច្នេះហើយប្រការដែលកម្ពុជាធ្វើជាប្រធានប្តូរវេនអាស៊ានក្នុងឆ្នាំនេះកាន់តែមានការលំបាកជាច្រើន ក្នុងការជំរុញអនុវត្តសេចក្តីប្រកាសលើក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង ដើម្បីឈានទៅកសាងក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងឱ្យបានឆាប់នោះ។

លោកIan Storey បាននិយាយដោយត្រង់ថាពួកគេបានចំណាយពេលអស់៩ឆ្នាំទើបសម្រេចបានសេចក្តីប្រកាសលើក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង ២០០២ ដូច្នេះពុំដឹងថា ត្រូវចំណាយអស់ពេលប៉ុន្មានទៀត ដើម្បីស្វែងរកភាពកុងសង់ស៊ីសនិងគ្នា ហើយឈានទៅរកក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូងឱ្យបាននោះ។

ការប្រឈមមុខដាក់គ្នា រវាងនាវាចិននឹងនាវារបស់វៀតណាម និងហ្វីលីពីនក្នុងឆ្នាំកន្លងទៅកាន់តែបញ្ជាក់ឱ្យឃើញថា សេចក្តីប្រកាសលើក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង២០០២ កាន់តែ

ពុំមានប្រសិទ្ធភាពអ្វីទាំងអស់ ហើយវិធីសាស្ត្រ និងបញ្ហារបស់ពួកអាស៊ានក៏នៅមានចំណុចមិនស៊ីសង្វាក់ខ្វះខាតច្រើនដែរ។

មកដល់ឆ្នាំ២០១១ ប្រធានប្ដូរវេនអាស៊ាន គឺឥណ្ឌូនេស៊ីខិតខំរក្សាជំហរកណ្ដាលចៀសវាងមិនធ្វើឱ្យមានភាពក្ដៅគគុកណាមួយទាក់ទងទៅដល់ការវិវាទអធិបតេយ្យភាពលើសមុទ្រឡើយ នៅក្នុងកម្រិតណាមួយនោះ ដោយចៀសវាងភាពតានតឹងជាមួយនឹងចិន។ យោងតាមការវិភាគរបស់ អ្នកនយោបាយសំណុំរឿងសមុទ្រចិនខាងត្បូងនេះនឹងត្រូវបង្អូកជាច្រើនឆ្នាំខាងមុខដោយឆ្នាំ ២០១២

នេះ កម្ពុជាជាប្រធានអាស៊ាន ឆ្នាំក្រោយ២០១៣ប្រ៊ុយណេ បន្ទាប់មកដល់ឆ្នាំ២០១៤ មីយ៉ាន់ម៉ា និង ដល់ឆ្នាំ២០១៥ គឺឡាវជាប្រធាន ដោយប្រទេសទាំង៤នេះ ច្បាស់ជានឹងមិនជំរុញដោះស្រាយបញ្ហា ទំនាស់វិវាទសមុទ្រចិនខាងត្បូងនេះ ក្នុងពេលដែលពួកគេទទួលតំណែងជាប្រធានអាស៊ានឡើយ។

## ➢ កម្ពុជា៖ ជំហរអព្យាក្រឹត្យ

ចិនត្រូវការកម្ពុជា តែកម្ពុជាក៏មានភូមិសាស្ត្រនយោបាយយុទ្ធសាស្ត្រមួយស្ថិតនៅភាគខាង លិចរបស់ប្រទេសវៀតណាម ហើយក៏ជាប្រទេសសម្ព័ន្ធមិត្តយុទ្ធសាស្ត្ររបស់កម្ពុជាផងដែរ។

ឆ្នាំ២០១២កម្ពុជាជាប្រធានប្ដូរវេនអាស៊ានទន្ទឹមនេះកម្ពុជាក៏ចង់បានអាសនៈជាសមាជិកមិនអចិន្ត្រៃយ៍ក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិផងដែរ តើអាចគេចវេសបានបញ្ហាសមុទ្រចិនខាងត្បូងដែរឬអត់? នាយករដ្ឋមន្ត្រីកម្ពុជាក៏ធ្លាប់បានប្រកាសថា ឆ្នាំនេះកម្ពុជាមានតួនាទីជាប្រធានអាស៊ានប្ដូរវេន កម្ពុជានឹងស្វែងរកការគាំទ្រពីអាស៊ាន ដើម្បីឱ្យមានអាសនៈមួយជាសមាជិកមិនអចិន្ត្រៃយ៍ ក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដូច្នេះរាល់បញ្ហាវិវាទនៅក្នុងតំបន់ ដូចជាករណីអធិករណ៍នៅលើតំបន់សមុទ្រចិនខាងត្បូង គឺកម្ពុជាបំពេញភារកិច្ច ជាអ្នកសម្របសម្រួលក្នុងស្ថានភាពមួយអព្យាក្រិត្យដោយមិនឈរខាងនេះ ឬឈរនៅខាងនោះឡើយ។ ការឈរជាអព្យាក្រឹតរបស់កម្ពុជា គឺជាភាពមួយដ៏ល្អបំផុត តែប្រការនេះ ក៏នឹងធ្វើឱ្យប្រទេសជាសមាជិកអាស៊ានមួយចំនួនមិនសប្បាយចិត្តផងដែរ។

លោក Arata Mahapatra អ្នកវិភាគនយោបាយរបស់ឥណ្ឌា បានអះអាងបន្ថែមថា នៅពេលដែលកម្ពុជាប្រកាន់នូវជំហរអព្យាក្រឹត គឺឥរិយាបថនេះនឹងធ្វើឱ្យកិត្យានុភាពរបស់កម្ពុជា កាន់តែបាន

លើកកម្ពស់នៅលើឆាកអន្តរជាតិ ប៉ុន្តែក្នុងពេលដែលជាងមួយពាក់កណ្ដាលសមាជិកអាស៊ាន កំពុងមានបញ្ហាវិវាទសមុទ្រចិនខាងត្បូង ច្បាស់ជាពួកគេមិនសប្បាយចិត្ត ទៅនឹងទស្សនអព្យាក្រឹតរបៀបនេះរបស់កម្ពុជាទេ។

ចិនជានិច្ចបានប្រកាសថា នឹងដោះស្រាយបញ្ហាសមុទ្រចិនខាងត្បូង ជាមួយនឹងពួករដ្ឋទាមទារសិទ្ធិ ក្នុងក្របខ័ណ្ឌសេចក្តីប្រកាសលើក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង ហើយចិនក៏មានបំណងស្វែងរកកិច្ចសហការជាមួយនឹងពួកប្រទេសពាក់ព័ន្ធ សំដៅដោះស្រាយនូវការខ្វែងគំនិតគ្នា ដើម្បីឈានដល់ការអភិវឌ្ឍនរួម។ ប៉ុន្តែយ៉ាងណាក៏ដោយ ចិនបានប្រឆាំងដាច់ខាតនូវគោលគំនិតចង់អន្តរជាតូបនីយកម្មមកលើបញ្ហាវិវាទសមុទ្រចិនខាងត្បូង ព្រមទាំងបដិសេធមិនអនុញ្ញាតឱ្យមានអានុភាពខាងក្រៅណាមួយ ដែលចង់ជ្រៀតជ្រែកចូលមកក្នុងដំណើរការអធិករណ៍នេះ។

ក្នុងស្ថានភាពមួយយ៉ាងដូច្នេះ តើកម្ពុជារក្សាបានភាពអព្យាក្រិត្យបានដែរឬអត់ ជាមួយក្រុងហាណូយ? ហើយដែលកំពុង តែមានបញ្ហាវិវាទជាមួយនឹងក្រុងប៉េកាំងយ៉ាងនេះ។

សមុទ្រចិនខាងត្បូង ជាតំបន់សមុទ្រដែលមានការពាក់ព័ន្ធទៅនឹងប្រទេសយ៉ាងច្រើនជាផ្លូវ នាវាចរណ៍មួយដោយសេរីពីមុនមក ហើយនៅពេលដែលសហគមន៍អន្តរជាតិ រួមទាំងចិនផងក៏ជា សមាជិកនៅក្នុងសហគមន៍នេះដែរ ដែលយើងទាំងអស់គ្នា មានក្រមច្បាប់របស់អនុសញ្ញាអង្គការ សហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ១៩៨២នោះ។ បែរទៅជាចិនប្រឆាំងដាច់ខាត មិនអនុញ្ញាតឱ្យពួក
ប្រទេសពាក់ព័ន្ធធ្វើអន្តរជាតិតូបនីយកម្ម មកលើសុំណុំរឿងសមុទ្រចិនខាងត្បូងនេះ ក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិទៅវិញ ដែលជាចំណោទចម្ងល់មួយដ៏ធំ។

យុទ្ធសាស្ត្ររបស់ចិន គឺលួងលោមមួយ ឬប្រទេសជាច្រើន ក្នុងសមាជិកអាស៊ានឱ្យមានការឯកភាពទទួលយកវិធីសាស្ត្ររបស់ចិនសិន ព្រមទាំងធ្វើយ៉ាងណា ដើម្បីរារាំងទប់ទល់កុំឱ្យមានការមូលមតិគ្នាណាមួយរបស់អាស៊ានចេញមុខប្រឆាំងចិន លើបញ្ហាសមុទ្រចិនខាងត្បូង ក្នុងគ្រប់កាលៈទេសៈចំពោះមុខ និងក្នុងអនាគតភាព។

ប្រការដែលចិនសកម្មបន្តប្រឆាំងទៅនឹងគំនិតធ្វើអន្តរជាតិតូបនីយកម្ម លើបញ្ហាសមុទ្រចិន
ខាងត្បូងនោះ គឺចិនសំដៅកំណត់នូវការបង្កើនអានុភាពរបស់អាមេរិក នៅលើសមុទ្រចិនខាងត្បូងនេះឯង។ ព្រោះវត្តមានជាអចិន្ត្រៃយ៍របស់អាមេរិក បង្កទៅជាអំណាចសម្ពាធមួយ មកលើព្រំដែន សមុទ្រភាគខាងត្បូងរបស់ចិនជាប្រឆាំងផងដែរ។

នាយករដ្ឋមន្ត្រីកម្ពុជាក៏ធ្លាប់បានពន្យល់បកស្រាយថា មិនអន្តរជាតូបនីយកម្មបញ្ហាមានន័យថា មិនអនុញ្ញាតឱ្យភាគីទី៣ ធ្វើឱ្យមានភាពគ្រោះថ្នាក់ មកលើគោលការណ៍សន្តិភាពរបស់អាស៊ាននេះទេ។

ជាការពិតកម្ពុជា គឺជាប្រទេសអព្យាក្រឹតមួយដែលពុំមានការពាក់ព័ន្ធណាមួយសោះ ទៅនឹងបញ្ហាសមុទ្រចិនខាងត្បូងនេះ។ប្រទេសកម្ពុជាមានស្ថានភាពមួយដ៏សត្យានុម័តបំផុតក្នុងការបំពេញមុខងារយ៉ាងវិជ្ជមានរបស់ខ្លួន ក្នុងការចូលរួមដោះស្រាយបញ្ហាវិវាទនេះ ដូចដែលកម្ពុជាធ្លាប់បានធ្វើក្នុង១០ឆ្នាំមុនកន្លងមកនោះ។ កម្ពុជាបានរួមចំណែកមួយធំយ៉ាងធេង ក្នុងការបង្កើតឡើងនូវសេចក្តី

ប្រកាសលើក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង២០០២ ដែលនេះជាការទស្សន៍វាយតម្លៃរបស់អង្គ

សិក្ខាសាលារវាង វិទ្យាស្ថានស្រាវជ្រាវតេណ្ឌា និងវិទ្យាស្ថានសម្រាប់សហប្រតិបត្តិការនឹងសន្តិភាព កន្លងមកនៅភ្នំពេញ។ តួនាទីប្រធានប្តូរវេនអាស៊ាន២០១២កម្ពុជាជាភាគីអព្យាក្រឹតមួយទៀត ដែលមានប្រសិទ្ធភាពបំផុតក្នុងការបង្កើនន្នូវលក្ខខណ្ឌអំណោយផលមួយផងដែរ ក្នុងការបង្កើនសាមគ្គីភាពក្នុងអាស៊ាន ការជំរុញការជឿទុកចិត្តគ្នា និងការធ្វើឱ្យមានភាពមូលមតិគ្នា រវាងភាគីអ្នកទាមទារសិទ្ធិ ដែលកម្ពុជាមានលទ្ធភាពដាក់ចេញនូវគំនិតផ្តួចផ្តើមយ៉ាងវិជ្ជមាន និងប្រកបដោយភាពសត្យានុម័តបំផុត ដែលភាគីពាក់ព័ន្ធទាំងអស់អាចទទួលយកបាន។

## ផ្នែកទី៧

## ប្រការសំខាន់ ៧ចំណុចពាក់ព័ន្ធដល់បញ្ហាតង់ស្យុងក្នុងសមុទ្រចិនខាងត្បូង៖

លោកសាស្ត្រាចារ្យ Carl Thayer នៃវិទ្យាស្ថានការពារជាតិអូស្ត្រាលី បានលើកអំពីបញ្ហា៧ចំណុចដែលនៅសេសសល់ក្នុងតំបន់ទាក់ទងដល់សមុទ្រចិនខាងត្បូង សម្រាប់ពួកប្រទេសស្ថិតនៅជុំវិញសមុទ្រចិនខាងត្បូង៖

ទីមួយ នៅពុំទាន់មានទស្សនវិស័យណាមួយក្នុងការដោះស្រាយ មកលើការទំនាស់វិវាទដ៏សារវន្តចំពោះអធិបតេយ្យភាព និងអំណាចអធិបតេយ្យ លើផ្លូវច្បាប់អំពីកោះ និងតំបន់សមុទ្រទាំងឡាយលើសមុទ្រចិនខាងត្បូង ដែលក្នុងនោះរួមមានទាំងប្រជុំកោះប៉ារ៉ាសែល និងកោះស្ព្រាតលី ។ ភាគីទាំងអស់ និងបន្តប្រឆាំងជំទាស់ ទោះបីសកម្មភាពណាមួយពីភាគីម្ខាងទៀត ដោយចាត់ទុកអំ ពើទាំងនោះបានរំលោភបំពានមកលើដែនអធិបតេយ្យភាពរបស់ប្រទេសខ្លួន។

ទីពីរ លិទ្ធិជាតិនិយម នៅតែជាកម្លាំងចិត្តមួយយ៉ាងខ្លាំងក្លា ដែលបានជិតជាប់នៅក្នុងស្មារតីទាំងរបស់ជនជាតិចិន វៀតណាម និងហ្វីលីពីន ដែលប្រការនេះជាបញ្ហាមួយដ៏លំបាកស្មុគស្មាញបំផុត ក្នុងការជំរុញស្វែងរកឱ្យមានដំណោះស្រាយសម្រាប់បញ្ហាដ៏រសើបនេះ។

ទីបី ពួកប្រទេសដែលមានការពាក់ព័ន្ធលើសមុទ្រចិនខាងត្បូងសុទ្ធតែបានតាមដានក្នុងការជំរុញផែនការសហប្រតិបត្តិការ ជាមួយបណ្ដាសហក្រុមហ៊ុនបរទេស រួមទាំងការអំពាវនាវអូសទាញឱ្យពួកនេះចូលមកធ្វើការរុករក និងធ្វើអាជីវកម្មប្រេងនៅក្នុងតំបន់សមុទ្រ ដែលមានទំនាស់វិវាទនៅឡើយនោះ។

ទីបួន នៅពេលដែលប្រភពត្រីក្នុងតំបន់សមុទ្រចិនក៏ដូចជានៅតំបន់ជុំវិញនិងជិតកោះហាយណាំបានរីងស្ងួត រកចាប់ត្រីអស់បានហើយនោះ។ ជាយថាហេតុ បានបង្ខំឱ្យពួកប្រទេសអ្នកនេសាទត្រីទាំងនេះ ដែលមានការលើកទឹកចិត្តពីអាជ្ញាធរចិន បានចាត់បញ្ជូន និងពង្រាយនូវកងនាវាយាម ល្បាតយ៉ាងច្រើនគ្រឿងចុះមកតំបន់ខាងក្រោមសំដៅផ្តល់ការការពារដល់កប៉ាល់នេសាទរបស់ពល

រដ្ឋចិនឱ្យបាន។

ទីប្រាំ ចិនកាន់តែមោះមុតហើយមានសកម្មភាពជាអគ្គនោម័តរួមទាំងមានប្រតិកម្មនិងថ្កោលទោស ចំពោះរាល់សកម្មភាពណាមួយ ដែលកើតមានឡើងលើសមុទ្រចិនខាងត្បូង ដែលទោះបីជាសកម្មភាពទាំងនេះមានចរិកលក្ខណៈជាស៊ីវិលក៏ដោយ។ ចិនបន្តរក្សាជំហររឹងរូស ដោយបដិសេធនូវរាល់ការចោទប្រកាន់ណាមួយមកលើខ្លួន ពីពួកប្រទេសពាក់ព័ន្ធថាសុទ្ធតែខុសទាំងអស់ ឬមួយក៏បានចាត់ទុករាល់សកម្មភាពរបស់ចិនលើសមុទ្រចិនខាងត្បូង ជាសកម្មភាពសមស្របទៅនិងច្បាប់ធរមានជាធម្មតារបស់ចិន។

ទីប្រាំមួយ ពួកប្រទេសដែលមានការពាក់ព័ន្ធ សុទ្ធតែបានបន្តនិងពង្រីកនូវសកម្មភាពការ អនុវត្តច្បាប់ចំពោះនាវាចរណ៍ ហើយសំខាន់ជាងនេះ គឺពួករដ្ឋដែលបានទាមទារសិទ្ធិនោះបានជំរុញ

ការងារទំនើបកម្មទាំងកងទ័ពជើងគោក និងជើងអាកាស សំដៅប្តេជ្ញាការពារផលប្រយោជន៍លើ សមុទ្រចិនខាងត្បូងឱ្យបាន។

ទីប្រាំពីរ អាស៊ានទៅមានការមិនឯកភាព លើរបៀបទំនាក់ទំនងជាមួយចិនក្នុងបញ្ហាវិវាទ លើសមុទ្រចិនខាងត្បូង ដែលនេះពុំមែនជាទស្សនវិស័យមួយដ៏ល្អ សម្រាប់ការឆ្ពោះទៅអនុម័តក្រម ប្រតិបត្តិមួយ ដែលមានចរិកចងទៅដោយច្បាប់ និងកំណត់បញ្ជាក់នូវរបៀបព្យាបាលរបស់ប្រទេស នីមួយៗ ដើម្បីសន្តិភាព និងស្ថេរភាពលើសមុទ្រចិនខាងត្បូងឡើយ។

និន្នាការធំខាងលើទាំងអស់នេះ សុទ្ធតែជាប្រការដែលធ្វើឱ្យមានការបារម្ភទាំងអស់។ ហើយតំបន់សមុទ្រអាស៊ីអាគ្នេយ៍នៅតែមានការចម្រូងចម្រាស់រហូត ដែលពីមួយថ្ងៃទៅមួយថ្ងៃកាន់តែក្តៅឡើង ដែលមួយថ្ងៃកាន់តែជ្រាលជ្រៅឡើងៗ ងាយបំផុតក្នុងការនាំទៅឱ្យមានការប្រទូស្តរាយដោយកម្លាំងអាវុធនោះ។

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ លើបញ្ហាសមុទ្រចិនខាងត្បូងក្នុងក្របខណ្ឌអាស៊ាន រួចមក យើងអាចធ្វើការសន្និដ្ឋានបានថា សាច់រឿងនេះហាក់បីដូចជាប្រហាក់ប្រហែលទៅនឹង រឿងប្រលោមលោករបស់ចិនយ៉ាងដូច្នេះ គឺរឿងសាមកុក ដែលបង្កប់នូវយុទ្ធសាស្ត្រ និងល្បិចកលជាច្រើន ហើយរហូតមកដល់ពេលបច្ចុប្បន្ន បញ្ហាសមុទ្រចិនខាងត្បូង នៅតែប្រកបទៅដោយភាពអាថ៌កំបាំង ដែលយើងម្នាក់ៗពិបាកនឹងយល់បាន ។

ចរន្តនយោបាយរបស់សមុទ្រចិនខាងត្បូងនេះ ប្រៀបបានទៅនឹងជាចរន្តនយោបាយពិភពលោក គឺពោរពេញទៅដោយភាពអនាធិបតេយ្យ ដែលជាប្រភពនៃទំនាស់ដ៏សំខាន់រវាងសហាគមន៍នយោបាយអធិបតេយ្យ។ ដោយសារតែតម្រូវការរបស់ភាគីក្នុងតំបន់ជម្លោះមិនមែនជាជម្រើសរយៈពេលវែង ធ្វើឱ្យភាគីនីមួយៗបានបង្កើតនូវយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីបន្តស្វែងរកនូវផលប្រយោជន៍ជាមូលដ្ឋានរបស់ខ្លួនតាមលទ្ធភាពដែលខ្លួនអាចធ្វើទៅបាន។

កត្តាបញ្ហាទាំងអស់នេះ គឺជាកត្តងាយស្រួលដោះស្រាយ តែក៏ជាកត្តាមរណៈ ប្រសិនបើបន្តព្រងើយកន្តើយ ព្រោះថាយើងមានរូបមន្តអស់ហើយសម្រាប់ដោះស្រាយ តែអ្វីដែលយើងខ្វះនោះគឺជាអាជ្ញាកណ្ដាលអព្យាក្រឹតមួយតែប៉ុណ្ណោះ សូម្បីតែអង្គការសហប្រជាជាតិ ក៏មិនទាន់អាចសន្និដ្ឋានថា
ជាអាជ្ញាកណ្ដាលអព្យាក្រឹតនៅឡើយទេ ដោយយើងឃើញហើយថា បញ្ហារបស់ពិភពលោកពីមួយថ្ងៃទៅមួយថ្ងៃកាន់តែច្រើនឡើង ស្របពេលដែលការដោះស្រាយមានភាពយឺតយ៉ាវយ៉ាងខ្លាំង កាន់តែធ្វើឱ្យគ្មានតុល្យភាពរវាងបញ្ហា និងដំណោះស្រាយ ដូច្នេះគម្លាតរវាងបញ្ហា និងដំណោះស្រាយពី

មួយថ្ងៃទៅមួយថ្ងៃកាន់តែឆ្ងាយ កត្តានេះនឹងរុញច្រានឱ្យអង្គការសហប្រជាជាតិ វិលទៅរកអតីតភាព
របស់ខ្លួនវិញដែលប្រទេសជាច្រើនលេងស្តាប់ ជាពិសេសប្រទេសក្រីក្រ និងទន់ខ្សោយដោយពួកគេមានអារម្មណ៍ឯកោរ ពេលដែលពួកគេរងការរំលោភបំពានគ្មានពីណាជួយពួកគេ ជាពិសេសអង្គការសហប្រជាជាតិនេះតែម្តង ដែលតាំងពីដើមគឺជាក្តីសង្ឃឹមយ៉ាងធំជាងគេរបស់ប្រទេសក្រីក្រ និងទន់ខ្សោយ។ តែវាក៏មិនមែនជាកំហុសរបស់អង្គការសហប្រជាជាតិដែរ ដោយសារតែគំនាបយ៉ាងច្រើនហើយមហាអំណាចមួយចំនួនមានការពាក់ព័ន្ធក្នុងរឿងនេះទើបធ្វើឱ្យភាពអព្យាក្រឹតប្រែក្លាយទៅជាការមិនអើពើ ដោយមានការយកចិត្តទុកដាក់តិចតួចបំផុត។

ហេតុនេះវាចាំបាច់ខ្លាំងណាស់ ក្នុងការបង្កើតនូវទស្សនៈវិស័យដែលមានភាពអព្យាក្រឹតមួយដែលអាចធ្វើឱ្យភាគីទាំងអស់មានភាពកក់ក្តៅក្នុងការទទួលយក ដើម្បីជៀសវាងបញ្ហាធំគ្រោះថ្នាក់កើតឡើង ដែលហួសពីអ្វីដែលយើងអាចគ្រប់គ្រងបាន ដូចជា សង្គ្រាមលោកលើកទី១ ឬសង្គ្រាម លោកលើកទី២ ។ល។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ លើបញ្ហាសមុទ្រចិនខាងត្បូងក្នុងក្របខណ្ឌអាស៊ាន រួចមក យើងអាចធ្វើការសន្និដ្ឋានបានថា សាច់រឿងនេះហាក់បីដូចជាប្រហាក់ប្រហែលទៅនឹង រឿងប្រលោមលោករបស់ចិនយ៉ាងដូច្នេះ គឺរឿងសាមកុក ដែលបង្កប់នូវយុទ្ធសាស្រ្ត និងល្បិចកលជាច្រើន ហើយរហូតមកដល់ពេលបច្ចុប្បន្ន បញ្ហាសមុទ្រចិនខាងត្បូង នៅតែប្រកបទៅដោយភាពអាថ៌កំបាំង ដែលយើងម្នាក់ៗពិបាកនឹងយល់បាន ។

ចរន្តនយោបាយរបស់សមុទ្រចិនខាងត្បូងនេះ ប្រៀបបានទៅនឹងជាចរន្តនយោបាយពិភពលោក គឺពោរពេញទៅដោយភាពអនាធិបតេយ្យ ដែលជាប្រភពនៃទំនាស់ដ៏សំខាន់រវាងសហគមន៍នយោបាយអធិបតេយ្យ។ ដោយសារតែតម្រូវការរបស់ភាគីក្នុងតំបន់ជម្លោះមិនមែនជាជម្រើសរយៈពេលវែង ធ្វើឱ្យភាគីនីមួយៗបានបង្កើតនូវយុទ្ធសាស្រ្តរបស់ខ្លួន ដើម្បីបន្តស្វែងរកនូវផលប្រយោជន៍ជាមូលដ្ឋានរបស់ខ្លួនតាមលទ្ធភាពដែលខ្លួនអាចធ្វើទៅបាន។

កត្តាបញ្ហាទាំងអស់នេះ គឺជាកត្តងាយស្រួលដោះស្រាយ តែក៏ជាកត្តាមរណៈ ប្រសិនបើបន្តព្រងើយកន្តើយ ព្រោះថាយើងមានរូបមន្តអស់ហើយសម្រាប់ដោះស្រាយ តែអ្វីដែលយើងខ្វះនោះគឺជាអាជ្ញាកណ្តាលអព្យាក្រឹតមួយតែប៉ុណ្ណោះ សូម្បីតែអង្គការសហប្រជាជាតិ ក៏មិនទាន់អាចសន្និដ្ឋានថា

ជាអាជ្ញាកណ្តាលអព្យាក្រឹតនៅឡើយទេ ដោយយើងឃើញហើយថា បញ្ហារបស់ពិភពលោកពីមួយថ្ងៃទៅមួយថ្ងៃកាន់តែច្រើនឡើង ស្របពេលដែលការដោះស្រាយមានភាពយឺតយ៉ាវយ៉ាងខ្លាំង កាន់តែធ្វើឱ្យគ្មានតុល្យភាពរវាងបញ្ហា និងដំណោះស្រាយ ដូច្នេះគម្លាតរវាងបញ្ហា និងដំណោះស្រាយពី

មួយថ្ងៃទៅមួយថ្ងៃកាន់តែឆ្ងាយ កត្តានេះនឹងរុញច្រានឱ្យអង្គការសហប្រជាជាតិ វិលទៅរកអតីតភាព

របស់ខ្លួនវិញដែលប្រទេសជាច្រើនលេងស្តាប់ ជាពិសេសប្រទេសក្រីក្រ និងទន់ខ្សោយដោយពួកគេមានអារម្មណ៍ឯកោរ ពេលដែលពួកគេរងការរំលោភបំពានគ្មានពីណាជួយពួកគេ ជាពិសេសអង្គការសហប្រជាជាតិនេះតែម្តង ដែលតាំងពីដើមគឺជាក្តីសង្ឃឹមយ៉ាងធំជាងគេរបស់ប្រទេសក្រីក្រ និងទន់ខ្សោយ។ តែវាក៏មិនមែនជាកំហុសរបស់អង្គការសហប្រជាជាតិដែរ ដោយសារតែគំនាបយ៉ាងច្រើនហើយមហាអំណាចមួយចំនួនមានការពាក់ព័ន្ធក្នុងរឿងនេះទើបធ្វើឱ្យភាពអព្យាក្រឹតប្រែក្លាយទៅជាការមិនអើពើ ដោយមានការយកចិត្តទុកដាក់តិចតួចបំផុត។

ហេតុនេះវាចាំបាច់ខ្លាំងណាស់ ក្នុងការបង្កើតនូវទស្សនៈវិស័យដែលមានភាពអព្យាក្រឹតមួយ

ដែលអាចធ្វើឱ្យភាគីទាំងអស់មានភាពកក់ក្តៅក្នុងការទទួលយក ដើម្បីជៀសវាងបញ្ហាដ៏គ្រោះថ្នាក់កើតឡើង ដែលហួសពីអ្វីដែលយើងអាចគ្រប់គ្រងបាន ដូចជា សង្គ្រាមលោកលើកទី១ ឬ សង្គ្រាម លោកលើកទី២ ។ល។